# ១~ ព្រះថេរិកាថេរីគាថា

(បិដកលេខ ៥៧, ទំព័រ ១៤៤)

**សុខំ សុបាហិ ថេរិកេ កត្វា ចោឡេន បារុតា**
**ឧបសន្តោ ហិ តេ រាគោ សុក្ខឌាកំវ កុម្ភិយំ ។**

ម្នាលថេរី នាងចូរដេកលក់ស្រួល នាងចូរធ្វើ (ចីវរបី) ដោយសំពត់ (បង្សុកូល) ហើយស្លៀកដណ្តប់ចុះ ព្រោះរាគៈរបស់នាងស្ងប់រំងាប់ហើយ ដូចជាបន្លែស្ងួតក្នុងឆ្នាំង ។

## សេចក្តីក្នុងព្រះអដ្ឋកថា

ក្នុងអតីតកាល មានកុលធីតាម្នាក់ នាងមានសេចក្តីជ្រះថ្លាដ៏ក្រៃលែងក្នុងព្រះពុទ្ធសាសនា ក្នុងកាលនៃព្រះដ៏មានព្រះភាគព្រះនាមកោនាគមនោ ។ នាងបានអារាធនាព្រះបរមសាស្តាសម្មាសម្ពុទ្ធ ដើម្បីទទួលបិណ្ឌ-



បាតជាដើមនៅគេហដ្ឋានរបស់នាង ។ នាងចាត់ចែងឱ្យសាងមណ្ឌបមែកឈើ ចាក់ខ្សាច់កៀរឱ្យស្មើខាងក្រោម ចងពិតានខាងលើ បូជាគ្រឿងក្រអូបនិងផ្កាឈើជាដើម ហើយ ឱ្យមនុស្សទៅក្រាបទូលកាលដល់ព្រះដ៏មានព្រះ-ភាគ ។ ព្រះសុគតសាស្តា ស្តេចយាងមកកាន់ទីមណ្ឌបនោះ ព្រះអង្គគង់ប្រថាប់លើអាសនៈដែលបានក្រាលទុក កុលធីតានោះ ក្រាបថ្វាយបង្គំ អង្គាសចង្ហាន់បិណ្ឌបាតយ៉ាងប្រណីត លុះទ្រង់សោយស្រេចហើយ បានថ្វាយត្រៃចីវរដល់ព្រះអង្គ ព្រះបរមសាស្តាបានអនុមោទនាដល់នាងហើយ ទើបស្តេចយាងទៅ ។ កុលធីតានោះធ្វើបុណ្យរហូតដល់អស់អាយុ នាងស្លាប់ទៅកើតក្នុងទេវលោក ស្លាប់កើតៗ ក្នុងសុគតិភូមិទាំងឡាយនោះឯងអស់មួយពុទ្ធន្តរ ។ ក្នុងកាលនៃព្រះពុទ្ធអង្គព្រះនាមកស្សបៈ នាងកើតជាមនុស្សក្នុងត្រកូលគហបតី លុះធំដឹងក្តីមានសេចក្តីសង្វេគក្នុងវដ្តសង្សារ ទើបនាងបានបួសក្នុងព្រះសាសនា ហើយឧបសម្បទាជាភិក្ខុនី នៅរហូត

ដល់ព្រះជន្មាយុពីរម៉ឺនឆ្នាំ អស់ព្រះជន្មទាំងនៅជាបុថុជ្ជន កើតក្នុងទេវលោក សោយសម្បត្តិក្នុងឋានសួគ៌អស់មួយចន្លោះព្រះពុទ្ធទៀត ទើបក្នុងកាលនៃពុទ្ធុប្បាទនេះ នាងច្យុតមកកើតក្នុងត្រកូលក្សត្រមហាសាល នាក្រុងវេសាលី មនុស្សទាំងឡាយហៅនាងថា **ថេរិកា** ព្រោះនាងមានរូបរាងធាត់មាំ ។ ព្រះនាងថេរិកាចម្រើនវ័យឡើង ព្រះ-បិតាព្រះមាតាបានផ្សំផ្គុំព្រះនាង ជាមួយនឹងខត្តិយកុមារដែលមានជាតិត្រកូលស្មើគ្នា ប្រទេសជាមួយគ្នា ។ ព្រះ-នាងគោរពបូជាស្វាមីដូចគោរពទេវតា ហើយព្រះនាងបាននូវសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា គ្រាដែលព្រះ-បរមសាស្តាទ្រង់យាងកាន់ក្រុងវេសាលីនោះឯង ក្រោយមកទៀត ព្រះនាងបានស្តាប់ព្រះធម៌ទេសនាក្នុងសម្នាក់ព្រះមហាបជាបតិគោតមី (នៅកូដាគារសាលានាមហា-វ័នជិតក្រុងវេសាលី) មានព្រះហឫទ័យចង់បួស បានសូមអនុញ្ញាតព្រះស្វាមីថា ខ្ញុំម្ចាស់នឹងបួស ប៉ុន្តែព្រះស្វាមីមិន



អនុញ្ញាតឡើយ ។ ដោយព្រះនាងបានសាងសន្សំនូវបុញ្ញាធិការមក ព្រះនាងពិចារណាធម៌តាមដែលបានស្តាប់ កំណត់រូបធម៌និងអរូបធម៌ ប្រកបវិបស្សនារឿយៗ។

ក្រោយមក ថ្ងៃមួយកាលដែលព្រះនាងកំពុងចម្អិនអាហារ អណ្តាតភ្លើងនោះធ្វើឱ្យភាជន:ទាំងអស់លាន់សូរប្រេះៗ ព្រះនាងទតឃើញដូច្នោះក៏បានកាន់យកសេចក្តីនោះឯងមកជាអារម្មណ៍ ពិចារណាភាពមិនទៀងដែលកំពុងប្រាកដ រួចហើយវិបស្សនាក៏ចម្រើនឡើងឃើញត្រៃលក្ខណ៍ក្នុងសភាវធម៌ ក្នុងទីនោះនិងពេលនោះឯងវិបស្សនាចម្រើនឡើងតាមលំដាប់ ព្រះនាងបានសម្រេចដល់អនាគាមិផល តាមលំដាប់នៃមគ្គ ។ ចាប់តាំងពីពេលនោះមក ព្រះនាងមិនបានប្រើប្រាស់នូវសម្លៀក-បំពាក់ដែលស្រស់ស្អាត និងគ្រឿងប្រដាប់កាយឡើយ កាលដែលព្រះស្វាមីសួរ ក៏បានឆ្លើយថា ខ្ញុំម្ចាស់មិនគួរនៅជាគ្រហស្ថឡើយ ហើយបានសូមអនុញ្ញាតបួស ។ ព្រះស្វាមីបាននាំព្រះនាងទៅកាន់សម្នាក់របស់ព្រះមហា-

បជាបតិគោតមី ដោយបរិវារយ៉ាងគគ្រឹកគគ្រេង ដូច វិសាខឧបាសកនាំព្រះនាងធម្មទិន្នា ចូលកាន់ផ្នួសដូច្នោះឯង លុះទៅដល់ ព្រះស្វាមីបានក្រាបថ្វាយបង្គំហើយពោលថា បពិត្រព្រះម៉ែម្ចាស់ សូមព្រះម៉ែម្ចាស់បំបួសនាងផងចុះ ។ កាលដែលព្រះមហាបជាបតិគោតមីឱ្យព្រះនាងថេរិកាបព្វជ្ជាឧបសម្បទាហើយ បាននាំទៅកាន់ព្រះវិហារថ្វាយបង្គំព្រះបរមសាស្តា ។ ព្រះសុគតសាស្តាទ្រង់ត្រាស់នូវព្រះគាថាដោយបទថា **សុខំ សុបាហិ ថេរិកេ** ជាដើម ដើម្បីធ្វើអារម្មណ៍ដែលព្រះនាងថេរិកាបានឃើញតាមប្រក្រតីនោះឯង ឱ្យបានជាក់ច្បាស់ដល់ព្រះនាងថែមទៀត ។

បណ្តាបទទាំងនោះ បទថា **សុខំ** នេះជាឈ្មោះនៃសភាវៈដែលជាទីប្រាថ្នា ដោយសេចក្តីថា មានសុខប្រាសចាកទុក្ខ ។

បទថា **សុបាហិ** នេះជាពាក្យសម្តែងនូវសេចក្តីសុខសម្រាន្តក្នុងឥរិយាបថ ៤ ដោយសេចក្តីថា ព្រោះដូច្នោះ នាងចូរសម្រេចនូវឥរិយាបថទាំង៤ តាមសប្បាយចុះ គឺចូរនៅយ៉ាងសប្បាយ ។

បទថា **ថេរិកេ** នេះជាបទប្រកាសឈ្មោះព្រះថេរីក៏ពិត ប៉ុន្តែក៏មានសេចក្តីថា ជាអ្នកមាំទាំក្នុងព្រះសាសនា គឺប្រកបដោយគុណធម៌មានសីលជាដើមដ៏មាំទាំ ។

បទថា **កត្វា ចោឡេន បារុតា** ដោយសេចក្តីថា នាងចូរយកសំពត់បង្សុកូលធ្វើចីវរបិទបាំងសរីរៈ គឺស្លៀកនិងដណ្តប់នូវសំពត់នោះ ។

**ហិ** សព្ទក្នុងបទថា **ឧបសន្តោ ហិ តេ រាគោ** មានសេចក្តីថា **ហេតុ** អធិប្បាយថា ព្រោះហេតុកាមរាគៈដែលកើតក្នុងសន្តានរបស់នាង ត្រូវបានដុតឱ្យស្ងប់ហើយដោយភ្លើងគឺអនាគាមិមគ្គញ្ញាណ ឥឡូវនេះ នាងចូរដុតរាគៈដែលនៅសល់នោះ ដោយភ្លើងគឺអរហត្តមគ្គញ្ញាណហើយសម្រាកឱ្យសប្បាយចុះ ។

បទថា **សុក្ខខារកំវ កុម្ភិយំ** ដោយសេចក្ដីថា រមែងស្ងប់ដូចបន្ទែបន្តិចបន្តួចក្នុងឆ្នាំងក្ដៅនោះ ដែលបន្ទែនោះត្រូវខ្លោច ដោយអំណាចភ្លើងមានកម្ដៅខ្លាំងយ៉ាងណាមិញ កាមរាគៈក្នុងសន្តានរបស់នាងស្ងប់ហើយ នាងចូរធ្វើកិលេសដែលនៅសល់ឱ្យស្ងប់អស់ រួចហើយសម្រាកនៅឱ្យសប្បាយចុះ យ៉ាងនោះឯង ។

ព្រះថេរីបានសម្រេចនូវព្រះអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយក្នុងពេលចប់នូវព្រះគាថា ព្រោះឥន្ទ្រិយចាស់ក្លា និងព្រោះព្រះបរមសាស្ដាទេសនាពីរោះហ្នឹងឯង ព្រោះហេតុនោះព្រះថេរីទើបបានពោលទុកក្នុងអបទានថា[១] :

ខ្ញុំបានកសាងមណ្ឌបថ្វាយព្រះពុទ្ធ ព្រះនាមកោនាគមនោ ហើយថ្វាយព្រះស្តូបដ៏ប្រសើរដល់ព្រះពុទ្ធជាផៅពង្សនៃលោកថែមទៀត ។ ខ្ញុំទៅកាន់ជនបទ និគម រាជធានីណាៗ ជាស្ត្រីត្រូវគេបូជាក្នុងទីទាំងពួងនោះៗ

១- បិដកលេខ ៧៦, ទំព័រ ៦ មណ្ឌបទាយិកាថេរិយាបទាន ។



នេះជាផលនៃបុញ្ញកម្ម ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ ខ្ញុំជាស្ត្រីមិនមានអាសវៈ ព្រោះបានកាត់ចំណង ដូចជាមេដំរីកាត់ផ្ដាច់នូវទន្លីង ។ ឱ ! ខ្ញុំមកល្អហើយក្នុងសម្នាក់នៃព្រះពុទ្ធរបស់ខ្ញុំ វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ សាសនារបស់ព្រះពុទ្ធខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឱ្យជាក់ច្បាស់ហើយ ទាំងសាសនានៃព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

កាលដែលព្រះថេរិកាថេរីបានសម្រេចព្រះអរហត្តហើយ ទើបបានបន្លឺឧទាននូវសុភាសិតគាថា មួយគាថានេះ (ទៅតាមឱវាទនៃព្រះពុទ្ធអង្គ ) ព្រោះហេតុនោះព្រះគាថានេះទើបបានជាព្រះគាថារបស់ព្រះថេរីនោះឯង ។

**សូមអនុមោទនា !**

## បទគួរយល់ដឹង

១. ក្នុងលោកនេះ មិនមែនឱ្យយើងចេះតែបានតាមប្រាថ្នាទៅនោះទេ ពីព្រោះសេចក្តីប្រាថ្នារបស់យើងមិនមែនជាហេតុនៃអ្វីដែលយើងចង់បាននោះឯង ។ អ្វីៗសុទ្ធតែពិតនិងត្រឹមត្រូវទៅតាមហេតុទាំងអស់ កាលបើមានស្មារតី ទោះជាមិនបានអ្វីតាមប្រាថ្នា ក៏សុខចិត្តដែរ ព្រោះព្រមតាម ជឿទុកចិត្តនិងប្រាកដច្បាស់ថា មិនមានអ្វីដែលមិនមែនជាការពិតនោះឡើយ ។ សង្ខារធម៌ទាំងអស់ប្រព្រឹត្តទៅតាមហេតុ អ្វីដែលកើតគឺរមែងកើត អ្វីដែលមានគឺរមែងមាន កាលដែលបុគ្គលមានបញ្ញាដឹងដូច្នោះ រមែងមិនឈ្លោះទាស់ទែងគ្នាឡើយ ។

២. លោកនេះ មិនមែនសុទ្ធតែល្អសព្វគ្រប់ទៅទាំងព្រមនោះទេ អ្នកមានបញ្ញាដឹងថា លោកនេះគឺបែបហ្នឹងហើយ រមែងមិនដកដង្ហើមធំឡើយ ពោលគឺមានសេចក្តីអត់ធន់ដោះស្រាយបញ្ហាដោយការស្ងប់ចិត្ត ។



៣. តួធម៌គឺរូបធម៌និងនាមធម៌ មានហើយ គ្រប់អង្គគ្រប់គ្នា គ្រប់ពេលវេលា កាលណាដែលតួធម៌ប្រាកដដល់សតិថ្នាក់សតិប្បដ្ឋាន តួខ្លួនយើងរមែងមិនមាន ។ តួធម៌ទាំងអស់ ទោះជាកុសលក៏ដោយ អកុសលក៏ដោយ អព្យាក្រឹតក៏ដោយ ឱ្យតែប្រាកដជាតួធម៌ដល់សតិប្បដ្ឋានហើយ គឺមិនមានបញ្ហាអ្វីទេ មានតែការអប់រំនូវបញ្ញាប៉ុណ្ណោះ ប៉ុន្តែ បើទិដ្ឋិចេតសិកចាប់យកធម៌ទាំងនោះបានជាអារម្មណ៍វិញ រមែងមានបញ្ហាខ្វាយខ្វល់គឺមានលក្ខណៈខ្វល់នឹងខ្លួនឯង ។ ខ្វល់នឹងខ្លួនឯងកុំឱ្យមានអកុសល ប៉ុន្តែអកុសលកំពុងប្រាកដ អត់ដឹងថាហ្នឹងជាតួធម៌មួយបែបតែប៉ុណ្ណោះ ។ គិតចង់ឱ្យខ្លួនឯងបានកុសល សម្រេចមគ្គ-ផលដល់និព្វាន ប៉ុន្តែអត់មានសតិរលឹកដឹងថា ការគិតចង់បានយ៉ាងនោះៗ គឺជាតួធម៌មួយបែប ដែលមិនមែនជាខ្លួនយើងហើយស្រេច ។ ព្រះពុទ្ធអង្គទ្រង់សម្តែង **កុសលា ធម្មា, អកុសលា ធម្មា, អព្យាកតា ធម្មា** ពោលគឺ មិនមានអ្វីដែលកើតមានក្នុងជីវិតរាល់ថ្ងៃ ថាមិនមែនជា

តួធមិ៌នោះឡើយ តួខ្លួនទើបមិនមាន ។

៤. ព្រះនាងថេរិកា ប្រាថ្នានឹងបួស តែព្រះស្វាមីមិនអនុញ្ញាត ។ ដោយឧបនិស្ស័យមានអំពីអតីតជាតិព្រមដោយការបានស្តាប់ព្រះធម៌ក្នុងបច្ចុប្បន្នជាតិ ធ្វើឱ្យព្រះនាងបានសម្រេចដូចប្រាថ្នា តាមឱកាសដែលមានបច្ច័យគ្រប់គ្រាន់ ។ រឿងខ្លះក៏ត្រូវរង់ចាំឱកាសដែរ យើងមិនត្រូវដោះស្រាយទៅតាមតែចំណង់ ឬតាមតែសេចក្តីក្រោធនោះឡើយ អ្វីដែលជាប្រយោជន៍ក្នុងបច្ចុប្បន្នមានដែរតើ យើងធ្វើទៅ ជាមួយនឹងការអប់រំចិត្ត ។ ចិត្តដែលលុះក្នុងអំណាចកិលេស នាំឱ្យប្រព្រឹត្តអនន្តរិយកម្មជាដើមបាន ប៉ុន្តែចិត្តដែលបានអប់រំក៏អាចឱ្យបុគ្គលសម្រេចជាព្រះអរហន្តមួយអង្គបានដែរ ។

៥. ព្រះពុទ្ធសាសនា អប់រំគំនិតមនុស្ស ជាប្រយោជន៍ឱ្យគំនិតផលិតសេចក្តីសុខផ្តល់ឱ្យជីវិត ដោយមិនចាំបាច់ទាល់តែមានអ្វីៗ ជាខាងក្រៅច្រើនទៅនោះឡើយ ។ មនុស្សយើងច្រើនគ្នាណាស់ ដែលខំចំណាយពេលរាល់ថ្ងៃដើម្បីស្វែងរកសេចក្តីសុខ តាមរយៈទ្រព្យសម្បត្តិ មុខមាត់កិត្តិយស ប៉ុន្តែគួរឱ្យស្តាយត្រង់ដែលមិនបានអប់រំចិត្តគំនិត បែរជាមកអង្គុយគិតឱ្យកើតទុក្ខក្នុងរឿងផ្សេងៗ ដូចជា គិតច្រណែននឹងគេ គិតស្អប់ គិតខឹងជាដើម ឬគិតភ័យព្រួយយ៉ាងនេះ យ៉ាងនោះ គឺវាជាគំនិត ដែលសម្រាប់សាងតែសេចក្តីទុក្ខឱ្យខ្លួនឯង ។ គិតឱ្យកើតទុក្ខបានទុក្ខ គិតឱ្យកើតសុខបានសុខ ដូច្នេះគំនិតពិតជាសំខាន់សម្រាប់ជីវិតខ្លួនឯងណាស់ ការអប់រំហ្វឹកហាត់ចិត្តគំនិតឱ្យចេះគិតត្រូវតាមព្រះធម៌ អាចនាំមកនូវលោកុត្តរសុខបានទៀតផង ។

៦. នៅពេលដែលចិត្តកើតទុក្ខ លោកនេះក៏ប្រាកដទៅជាសោះកក្រោះ ឬប្រាកដនូវភាពគួរឱ្យធុញទ្រាន់ ឬក៏គួរឱ្យភ័យខ្លាច ពុំនោះសោត ប្រាកដនូវភាពគួរឱ្យស្អប់មិនចង់រស់នៅ ។

នៅពេលដែលចិត្តមានសេចក្តីសុខ លោកនេះក៏ប្រាកដនូវភាពស្រស់ថ្លា ស្វាងស្រឡះនិងហាក់ដូចជាមាន

រសជាតិ ។

ចិត្តក្នុងមនុស្សយើងនេះមានឥទ្ធិពលខ្លាំងណាស់ គឺថា បើចិត្តនេះយ៉ាងណា លោកនេះក៏ប្រាកដទៅជាយ៉ាងនោះ ដូច្នេះការរក្សាចិត្តទើបជាកិច្ចយ៉ាងសំខាន់ក្រៃលែង ។

ចិត្តមានអកុសលគឺមានមេរោគ ឬមានជាតិពុល បើចិត្តមានបុណ្យកុសលវិញគឺមានឱសថ ឬមានថ្នាំបន្សាបជាតិពុល ។

ចូរព្យាយាមលះឧបនិស្ស័យអាក្រក់ដោយការសន្សំឧបនិស្ស័យល្អ ពោលគឺប្រព្រឹត្តនូវអ្វីដែលល្អនោះឱ្យតជាប់គ្នា រហូតបានជាទម្លាប់ ។

ទានទាំងឡាយគួរឱ្យ បុណ្យទាំងឡាយគួរធ្វើ នេះជាព្រះពុទ្ធដីកាក្នុងសុមនសូត្របិដកលេខ ៤៤ ។

ព្យាយាមនមស្ការថ្វាយបង្គំព្រះរតនត្រៃ អប់រំមេត្តារក្សាចិត្ត គេចពីបាបមិត្តជិតសប្បុរស យកចិត្តទុកដាក់នឹងព្រះពុទ្ធដីកា មួយបាទ មួយព្រះគាថាកាត់ថ្ងៃ



មិនបាន និងមានសតិថ្នាក់សតិប្បដ្ឋាន ។

ចិត្តដែលអប់រំល្អហើយ លោកនេះក៏ប្រាកដជារមណីយដ្ឋាន ។

## ពាលនិងបណ្ឌិត

(សុភាសិត)

កុំសេពគប់ជនពាល ត្រូវសេពគប់បណ្ឌិត
ប្រយ័ត្នពាលក្នុងចិត្ត ថែបណ្ឌិតក្នុងខ្លួន ។

ប.ស.ទ.

## គួរនិងកុំ

(សុភាសិត)

បុណ្យទាំងឡាយគួរធ្វើ ទានទាំងឡាយគួរឱ្យ
កាមគុណកុំបណ្ដោយ កម្មស្ដាយក្រោយកុំធ្វើ ។

ប.ស.ទ.

## ២~ ព្រះបុណ្ណាថេរីគាថា

( បិដកលេខ ៥៧, ទំព័រ ១៤៥ )

**បុណ្ណេ បូរស្សុ ធម្មេហិ    ចន្ទោ បណ្ណរសេរិវ**
**បរិបុណ្ណាយ បញ្ញាយ    តមោក្ខន្ធំ បទាលយ ។**

ម្នាលនាងបុណ្ណា នាងចូរពេញដោយពោធិបក្ខិយធម៌ទាំងឡាយ ដូចជាព្រះចន្ទក្នុងថ្ងៃ ១៥ កើត នាងចូរទម្លាយនូវគំនរងងឹតគឺមោហៈ ដោយបញ្ញាដ៏បរិបូណ៌ ។

## សេចក្តីក្នុងព្រះអដ្ឋកថា

នាងសិក្ខមានា ឈ្មោះបុណ្ណានេះឯង បានសាងសន្សំនូវបុញ្ញាធិការទុកមក តាំងតែអំពីព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ។ ក្នុងជាតិមួយនោះ នាងកើតជាកិន្នរីនៅនាមាត់ស្ទឹងចន្ទភាគា ថ្ងៃមួយបានជួបព្រះបច្ចេកពុទ្ធមួយព្រះអង្គ



មានចិត្តជ្រះថ្លា បូជាព្រះបច្ចេកពុទ្ធដោយផ្កាបបុស ឈរប្រណម្យដោយការធ្វើអញ្ជលិកម្ម ។ ដោយបុញ្ញកម្មនោះ នាងកើតនៅតែក្នុងសុគតិភពទាំងឡាយប៉ុណ្ណោះ ក្នុងកាលនៃពុទ្ធុប្បាទនេះ នាងកើតក្នុងត្រកូលគហបតីមហាសាលក្នុងក្រុងសាវត្ថី មានឈ្មោះថា **បុណ្ណា** ព្រោះជាស្រ្តីដល់ព្រមដោយឧបនិស្ស័យ ។ កាលដែលនាងមានអាយុ ២០ ឆ្នាំ បានស្តាប់ព្រះធម៌ក្នុងសម្នាក់ព្រះមហាបជាបតិគោតមី មានសទ្ធាសូមបួសជាសិក្ខមានា អប់រំវិបស្សនា។

ព្រះបរមសាស្តាគង់ប្រថាប់នៅឯព្រះគន្ធកុដិនោះឯង ទ្រង់ផ្សាយនូវព្រះរស្មីត្រាស់ព្រះគាថាដល់ព្រះនាងបុណ្ណាសិក្ខមានា ។

បណ្តាបទទាំងនោះ បទថា **បុណ្ណេ** ជាពាក្យហៅព្រះនាងសិក្ខមានានោះឯង ។

បទថា **បូរស្សុ ធម្មេហិ** ដោយសេចក្តីថា ចូរបរិបូណ៌ដោយពោធិបក្ខិយធម៌ ៣៧ ប្រការ ។

បទថា **ចន្ទោ បណ្ណរសោរិវ** គឺដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។

បទថា **បរិបុណ្ណាយ បញ្ញាយ** គឺដោយបញ្ញាដែលប្រកបដោយអរហត្តមគ្គ ឈ្មោះថាបរិបូណ៌ ព្រោះធ្វើកិច្ច ១៦ យ៉ាងឱ្យបរិបូណ៌ ។

បទថា **តមោក្ខន្ធំ បទាលយ** ដោយសេចក្ដីថា ចូរទម្លាយ គឺចូរដកនូវកងមោហៈមិនឱ្យមានសល់ ។ កិលេសទាំងអស់ ក៏បានទម្លាយព្រមជាមួយគ្នានឹងការទម្លាយនូវគំនរមោហៈនោះឯង ។

ព្រះនាងសិក្ខមានាបុណ្ណានោះ បានស្ដាប់នូវព្រះ-គាថានោះហើយ ចម្រើនវិបស្សនាសម្រេចព្រះអរហត្ត ព្រោះហេតុនោះ ព្រះនាងទើបពោលទុកក្នុងអបទានថា[១]

កាលនោះ ខ្ញុំជាកិន្នរីនៅជិតឆ្នេរស្ទឹងចន្ទភាគា បានឃើញព្រះពុទ្ធ ទ្រង់ប្រាសចាកនូវធូលីគឺកិលេស ត្រាស់ដឹងឯង ទ្រង់ឈ្នះកិលេសហើយ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តល្អ កើតសេចក្ដីរីករាយ ធ្វើអញ្ជលី ហើយយកកម្រងផ្កាបបុសបូជាព្រះសយម្ភូ ។ ដោយកុសលកម្មដែលខ្ញុំធ្វើល្អនោះផង ដោយការតម្កល់ចេតនានោះផង លុះខ្ញុំលះបង់រាងកាយជាកិន្នរីហើយ ក៏បានទៅកើតក្នុងឋានត្រៃត្រិង្ស ។ ខ្ញុំបាននូវភាពជាមហេសីនៃទេវរាជ ៣៦ ដង បាននូវភាពជាមហេសីនៃស្ដេចចក្រពត្តិ ១០ ដង ។ ខ្ញុំទទួលរងនូវកុសលបានចូលទៅកាន់ផ្នួស កិលេសទាំង-ឡាយខ្ញុំដុតបំផ្លាញហើយ ភពទាំងអស់ខ្ញុំដកចោលហើយ អាសវៈទាំងពួងអស់ហើយ ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។ ក្នុងកប្បទី ៩៤ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ។ល។ ព្រះពុទ្ធសាសនាខ្ញុំក៏បានប្រតិបត្តិហើយដែរ ។

**សូមអនុមោទនា !**

១- បិដកលេខ ៧៦, ទំព័រ ៨ នឡមាលិកាថេរិយាបទាន ។

## បទគួរយល់ដឹង

១. កាលដែលមានអ្នកដទៃស្រឡាញ់ ចូលចិត្ត រាប់អានហៅរក និង ពោលសរសើរយើង គឺកុំចេះតែសប្បាយចិត្តភ្លេចខ្លួន ត្រូវចាំថា ក្នុងលោកនេះ អ្នកដែលឱ្យយើងទុកចិត្តជាងគេ គឺខ្លួនឯងដែលជាមនុស្សល្អពិត ព្រោះអ្នកក្រៅពីយើង អត់មានអ្នកណាការពារអបាយភូមិឱ្យយើងបានទេ ហើយក៏មិនអាចញុំាងសេចក្តីបរិសុទ្ធឱ្យយើងបានដែរ ។

២. កាលដែលមានអ្នកដទៃស្អប់ ច្រណែនឈ្នានីស និយាយបង្ខូច ឬឈប់រាប់អានជាដើម គឺមិនត្រូវខូចចិត្តឡើយ ឱ្យតែយើងតម្កល់ខ្លួនដោយប្រពៃហើយ មានចាំបាច់អ្នកដទៃមកលើកតម្កើង ឬដាក់ពិន្ទុឱ្យអ្វីទៀត។

៣. រៀនរស់នៅឱ្យជាសុខជាមួយនឹងការពិត អ្វីៗក៏ជាការពិតដែរ មានអ្វីដែលឱ្យយើងទុកចិត្តជាងការពិតទៀត ការពិតប្រាកដច្បាស់ត្រូវអស់ខ្វល់ ។ ការពិត



សម្រេចកិច្ចយ៉ាងត្រឹមត្រូវឱ្យយើងទៅហើយ នៅមិនសុខចិត្តយ៉ាងម៉េចទៀត ។ ការពិត មាននៅគ្រប់រឿងទាំងអស់ ការពិត គឺជាសភាវធម៌ដែលកើតក្នុងលោក ជារបស់លោកនេះ ជាបរមត្ថត្រឹមត្រូវតាមបច្ច័យជាទីបំផុត។ អ្វីដែលកើតរមែងកើត អ្វីដែលមានរមែងមាន អ្វីដែលអត់គឺត្រូវតែអត់ មិនមានសេចក្តីស្ងប់ចិត្តណាឱ្យដូចជាការស្ងប់ចិត្តព្រោះបានដឹងនូវរសនៃសេចក្តីពិតនេះឡើយ ។

៤. ឧបនិស្ស័យក្នុងមនុស្សយើងម្នាក់ៗ គឺជាបរមត្ថធម៌ ធ្វើឱ្យមនុស្សយើងមានចំណូលចិត្តផ្សេងៗគ្នា។ ព្រះនាងបុណ្ណាថេរី កាលដែលមានជាតិជាកិន្នរីក៏មានឧបនិស្ស័យជ្រះថ្លា បានថ្វាយផ្កាដល់ព្រះបច្ចេកពុទ្ធ ទាំងអធ្យាស្រ័យក៏ប្រព្រឹត្តទៅដោយការលះបង់ មាននេក្ខម្មៈសន្សំក្នុងសន្តាន ព្រមទាំងចរិតថ្លៃថ្នូរ ទន់ភ្លន់ រហូតដល់សព្វថ្ងៃមានរូបសំណាកកិន្នរីប្រណម្យអញ្ជលី ដែលបញ្ជាក់ដល់បុញ្ញកម្មមួយ ជាហេតុនាំឱ្យកើតក្នុងត្រកូលខ្ពង់ខ្ពស់ ។

# ប្រវត្តិព្រះបុណ្ណាថេរី

(កំណាព្យពាក្យ ៨)

នាងកិន្នរីមានក្ដីជ្រះថ្លា បានបូជាផ្កាបបុសមាលា
នៅជិតដងស្ទឹងចន្ទភាគា ជ្រះថ្លាវន្ទាធ្វើអញ្ជលី ។
ព្រះសយម្ភូបច្ចេកពុទ្ធ ព្រះអង្គឆ្លងផុតតណ្ហានទី
ហឫទ័យសន្តោសចុះចាកគិរី ប្រោសមាលិនីសត្វញីកិន្នរ ។
តេជះនៃបុណ្យមានគុណឱ្យសុខ ដួងចិត្តស្រណុកសោយសុខត្រេកអរ
កំណើតជាសត្វតែចិត្តបវរ ចាកជាតិកិន្នរបន្តសួគ៌ា ។
បានជាមហេសីនៃទេវរាជ នេះហើយអំណាចពុទ្ធបូជា
បើកើតជាមនុស្សស្រីស្រស់ស្រីង្គា អគ្គជាយារាជចក្រពត្តិ ។
កៅសិបបួនកប្បចាប់ជាតិឧត្តម ជាស្រីស័ក្តិសមចំនារីរ័ត្ន
អគ្គមហេសីសិរីទ្វេងទាត់ មិនដែលភ្លាំងភ្លាត់ព្រាត់ទៅអបាយ ។
នេះជាផលជាក់ពុទ្ធបូជា បបុសមាលាកិន្នរបានថ្វាយ
ព្រមទាំងប្រណម្យបង្គំមិនណាយ សុខចិត្តសុខកាយតម្កល់ចេតនា ។
ចាប់ជាតិចុងក្រោយនៅក្រុងសាវត្ថី កូនគហបតីស្រីឈ្មោះបុណ្ណា
លុះអាយុម្ភៃថ្លៃនេក្ខម្មា បួសក្នុងសាស្នាសិក្សាត្រៃលក្ខណ៍ ។



ឧបនិស្ស័យសិក្ខមានា បរិសុទ្ធថ្លៃថ្លាសាស្តាជ្រាបជាក់
ទ្រង់គង់គន្ធកុដិឱភាសគ្គះ ត្រាស់ពោធិមគ្គបញ្ជាក់គាថា ។
គាថាបួនបាទបទព្រះបាលី អង្គព្រះជិនស្រីត្រាស់ហៅបុណ្ណា
នាងចូរពេញដោយសទ្ធម្មថ្លៃថ្លា ដូចខ្នើតមាសាចន្ទ្រាពេញវង់ ។
នាងចូរទម្លាយគំនរងងឹត គឺមោហៈពិតបិទបាំងឱ្យល្ងង់
ដោយបញ្ញាក្រាស់ជាក់ច្បាស់ទ្រទ្រង់ ដូចចន្ទពេញវង់ត្រចង់ត្រចះ ។
ចប់ធម៌ទេសនាបុណ្ណាភ្លឺស្វាង នេះជាសំណាងដ៏យ៉ាងជាក់ច្បាស់
បុណ្យពីជាតិមុនជាទុនខ្លាំងណាស់ ចិត្តផុតស្រឡះឃើញច្បាស់និព្វាន ។
ប្រវត្តិស្ត្រីថេរីបុណ្ណា សម្ដែងគាថាថេរិយាបទាន
ថាមកល្អហើយសម្អាក់ទ្រង់ញាណ កិលេសដែលមាននិព្វានហ្មត់ហ្មង ។
លះកាត់តណ្ហាពិតថាជាស្រី ដូចមេដំរីកាត់ផ្ដាច់ចំណង
លះបង់ភពបីអស់ក្ដីប៉ុនប៉ង ភពថ្មីស្រីឆ្លងកន្លងហើយណា ។
បុណ្ណាបានលុះតិស្សេវិជ្ជា ឆឡភិញ្ញា សច្ឆិកតា
បញ្ញាបែកធ្លាយមានបួនប្រការ ទាំងវិមោក្ខាប្រការប្រាំបី ។
គុណធម៌ទាំងនេះវិសេសខ្លាំងណាស់ ឧត្តមច្បងច្បាស់ព្រះម្ចាស់ថេរី
គុណធម៌ទ្រទ្រង់មគ្គអង្គប្រាំបី បុណ្ណាថេរីចប់កិច្ចសាស្នា ។

**ប.ស.វ.**

## ៣. ព្រះតិស្សាថេរីគាថា

( បិដកលេខ ៥៧, ទំព័រ ១៤៥ )

**តិស្សេ យុញ្ជស្សុ ធម្មេហិ ខណោ តំ មា ឧបច្ចគា**
**ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។**

ម្នាលនាងតិស្សា ចូរនាងប្រកបដោយធម៌ទាំង-ឡាយ ខណៈកុំកន្លងនាងឡើយ ព្រោះពួកជនដែលខណៈកន្លងហើយ រមែងសោកស្តាយពេញប្រៀបក្នុងនរក ។

## សេចក្តីក្នុងព្រះអដ្ឋកថា

នាងសិក្ខមានា ឈ្មោះតិស្សានេះឯង បានសាងសន្សំនូវបុញ្ញាធិការទុកមក តាំងតែអំពីព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វាន ទុកក្នុងភពនោះៗ ។ ព្រោះកុសលដែលបានរួបរួមសន្សំជាបច្ច័យ ទើបបានកើតក្នុងសក្យរាជត្រកូលក្រុងកបិលពស្តុ ។ ក្នុង



កាលនៃពុទ្ធុប្បាទនេះ ចម្រើនវ័យហើយជាស្នំនៃព្រះ-សិទ្ធត្ថបរមពោធិសត្វ ក្រោយមកក៏បានចេញបួស ព្រមជាមួយនឹងព្រះមហាបជាបតិគោតមី ចម្រើនវិបស្សនា ។ ព្រះបរមសាស្តាទ្រង់ឱភាសនូវព្រះរស្មី ឱ្យប្រាកដព្រះអង្គក្នុងពន្លឺនោះ ត្រាស់សម្តែងព្រះគាថា

បណ្តាបទទាំងនោះ បទថា **យុញ្ជស្សុ ធម្មេហិ** ដោយសេចក្តីថា ចូរប្រកប គឺចូរធ្វើការប្រកបដោយធម៌បានដល់ សមថៈនិងវិបស្សនាទាំងឡាយ ព្រមទាំងពោធិ-បក្ខិយធម៌ទាំងឡាយដ៏ប្រសើរផង ។

បទថា **ខណោ តំ មា ឧបច្ចគា** ដោយសេចក្តីថា ខណៈទាំងឡាយនេះគឺ ខណៈកើតក្នុងប្រទេសដ៏-សមគួរ ខណៈមានអាយតនៈ ៦ គ្រប់គ្រាន់ ខណៈកើតឡើងនៃព្រះពុទ្ធ ខណៈបានសទ្ធា ។ ដែលថាឈានកន្លងព្រោះឈានកន្លងបុគ្គល ដែលមិនអប់រំចម្រើននូវយោគ-ធម៌គឺការប្រកបដោយធម៌ទាំងឡាយនោះឯង ខណៈនោះកុំគប្បីកន្លងនូវនាងទៅឡើយ ។

បទថា **ខណាតីតា** ដោយសេចក្ដីថា ព្រោះបុគ្គលទាំងឡាយណាប្រព្រឹត្តកន្លងនូវខណៈ និង ខណៈនោះប្រព្រឹត្តកន្លងនូវបុគ្គលទាំងឡាយណា បុគ្គលទាំងឡាយនោះ រមែងពេញប្រៀបក្នុងនរកហើយសោកសៅ គឺកើតក្នុងនរកនោះ ហើយសោយទុក្ខធំ ។

ព្រះនាងតិស្សា បានស្ដាប់ព្រះគាថានោះហើយ ក៏បានសម្រេចព្រះអរហត្ត កាត់កិលេស ភពថ្មីមិនមានឡើយ ។

**សូមអនុមោទនា !**

## បទគួរយល់ដឹង

១. នឹងឱ្យអ្វីៗជុំវិញខ្លួនតម្រូវតាមចិត្តយើងចង់មិនបានឡើយ ប៉ុន្តែអ្វីៗដែលកើតសុទ្ធតែត្រឹមត្រូវទៅតាម



ហេតុដែលមាន នេះឯងជាធម៌ពិត ជាអារម្មណ៍ឱ្យស្ងប់ចិត្ត ព្រោះរលត់ចំណង់ខ្លួនឯង ។

២. កើតមកហើយ ថាកុំឱ្យចាស់ កុំឱ្យឈឺ កុំឱ្យស្លាប់ មិនបានឡើយ ទោះជាសម័យណាក៏ដោយ ប៉ុន្តែតាមការត្រាស់ដឹងនៃព្រះពុទ្ធអង្គ គឺកំណត់ដឹងនូវអ្វីដែលកើតនោះជាសង្ខារធម៌ កាលបើសង្ខារធម៌ប្រាកដមិនមែនជាតួខ្លួនហើយ ការចាស់ ឈឺ ស្លាប់ មិនមែនជាបញ្ហាឡើយ ។

៣. ការបដិបត្តិធម៌ មិនមែនដើម្បីគ្រប់គ្រងនូវលោកនេះនោះឡើយ ហើយក៏មិនមែនជាការចាត់ចែងលោកនេះដែរ គ្រាន់តែស្គាល់លោកទៅតាមសេចក្ដីពិតប៉ុណ្ណោះ ឃើញលោកនេះជាទុក្ខ ប៉ុន្តែមិនកើតទុក្ខជាមួយនឹងលោកនេះទេ ។

៤. មានសម្បត្តិខាងក្រៅសន្ធឹកសន្ធាប់ក៏ពិត តែមិនមានតម្លៃស្មើនឹងគុណធម៌ក្នុងចិត្ត ។ មានឋានៈខ្ពង់-ខ្ពស់យ៉ាងណាក៏មិនស្មើនឹងការឃើញទុក្ខតាមពិត ។

សម្បត្តិក្នុងលោក ជារបស់ដែលស្លាប់ហើយយកទៅមិនបាន ជីវិតមានខ្លឹមសារគឺការប្រព្រឹត្តធម៌ បណ្ឌិតឃើញជីវិតជាប្រក្រតីសុទ្ធតែជាតួធម៌បរមត្ថ ព្រោះបានចម្រើនសតិប្បដ្ឋាន អប់រំវិបស្សនា ។

កុំឱ្យខណៈកន្លង គឺកុំឱ្យបាត់បង់នូវឱកាសដែលបានកើតមកជាមនុស្សហើយបានជួបនឹងព្រះពុទ្ធសាសនា ការត្រាស់ដឹងនៃព្រះពុទ្ធហៅពេញសែនក្រ គួរប្រារព្ធសេចក្តីព្យាយាមឱ្យបានដឹងច្បាស់នូវអរិយសច្ចធម៌ ។

កុំប្រព្រឹត្តកន្លងនូវខណៈ គឺកុំប្រមាទ កុំបណ្តែតបណ្តោយពេលវេលា កុំប្រាសចាកសតិក្នុងការរស់នៅ ។ ធម៌ជាប្រក្រតីក្នុងជីវិតសុទ្ធតែជាអារម្មណ៍នៃព្រះកម្មដ្ឋានបានទាំងអស់ ប្រៀបដូចជាទីតាំងនៃកំណប់ទ្រព្យដូច្នោះឯង មិនគប្បីបង្អែបង្អង់ក្នុងការជីកយកកំណប់ទ្រព្យពោលគឺពោធិបក្ខិយធម៌ ៣៧ ប្រការ ដោយការចម្រើនសតិប្បដ្ឋាននោះឡើយ ។ គួរនឹករលឹកឱ្យរឿយៗថា បុគ្គលប្រព្រឹត្តកន្លងនូវខណៈជាអភព្វបុគ្គល មានច្រើន



ណាស់ ដូចជាសត្វក្នុងអបាយភូមិ ឬមនុស្សវិកលចរិតជាដើម ដូច្នេះការដែលបានកើតមកជួបនឹងព្រះពុទ្ធោវាទ ស្តាប់បាន រៀនបាន យល់ដឹងបាន គឺជាកំពូលនៃការបានលាភ ត្រូវតែជាបុគ្គលមានភ័ព្វដោយការទទួលយកធម៌ជាមរតក ជាអនុជាតបុត្ររបស់ព្រះសម្មាសម្ពុទ្ធពិតៗ ។

៥. ទោះជាសត្វលោកផ្សេងគ្នាដោយជាតិ ដោយកំណើត ចរិតអធ្យាស្រ័យ ពាក្យសម្តី រូបរាងយ៉ាងណា ក៏នៅតែដូចគ្នាត្រង់ដែលថានោះជាតួធម៌សុទ្ធៗ ហ្នឹងឯងពោលគឺចិត្ត ចេតសិក រូប ។

## កុំនិងកុំ

(សុភាសិត)

កុំមើលងាយកិលេស កុំថយកម្លាំងចិត្ត
កុំយល់ខុសការពិត កុំប្រឌិតរឿងខ្វល់ ។

ប.ស.ឆ.

## ៤. ព្រះឧត្តរាថេរីគាថា

(បិដកលេខ ៥៧, ទំព័រ ១៤៧)

**កាយេន សំវុតា អាសឹ វាចាយ ឧទ ចេតសា**
**សមូលំ តណ្ហំ អព្វុយ្ហ សីតិភូតម្ហិ និព្វុតា ។**

ខ្ញុំជាអ្នកសង្រួមដោយកាយ ដោយវាចា និង ដោយចិត្ត បានដកតណ្ហាព្រមទាំងឫស ជាបុគ្គលមានចិត្តត្រជាក់ រលត់ទុក្ខហើយ ។

## សេចក្តីក្នុងព្រះអដ្ឋកថា

ព្រះឧត្តរាថេរី ប្រសូតក្នុងសក្យរាជត្រកូលក្រុងកបិលពស្តុ មានប្រវត្តិដូចព្រះតិស្សាថេរីដែរ បានសម្រេចព្រះអរហត្តដោយឱភាសគាថា ហើយបានពោលគាថាជាឧទានដោយខ្លួនឯង ។

បណ្តាបទទាំងនោះ បទថា **កាយេន សំវុតា**



**អាសឹ** ដោយសេចក្តីថា ជាអ្នកសង្រួមហើយដោយការសង្រួមផ្លូវកាយ ។

បទថា **វាចាយ** ប្រកបសេចក្តីថា ជាអ្នកសង្រួមហើយដោយការសង្រួមផ្លូវវាចា ។ ព្រះថេរីពោលដល់សីលសំវរដោយបទទាំងពីរ ។

បទថា **ឧទ** បានដល់ **អថ** ប្រែថា និង ។

បទថា **ចេតសា** គឺ ដោយសមាធិចិត្ត ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ការចម្រើនវិបស្សនា ដោយសមាធិចិត្តនោះឯង ។

បទថា **សមូលំ តណ្ហំ អព្វុយ្ហ** ដោយសេចក្តីថា ដកឡើងនូវតណ្ហាព្រមទាំងឫសឬព្រមដោយអវិជ្ជា ព្រោះថា តណ្ហារមែងកើតឡើងក្នុងភពបី ដោយអវិជ្ជាបិទបាំងទុកនូវទោស ។

ន័យម្យ៉ាងទៀត បទថា **កាយេន សំវុតា** ដោយសេចក្តីថា ជាអ្នកសង្រួមផ្លូវកាយ គឺជាការសង្រួមដោយ

មគ្គ ព្រោះលះមិច្ឆាកម្មន្តៈទាំងអស់ដោយសម្មាកម្មន្តៈ ។

បទថា **ទាចាយ** ដោយសេចក្តីថា ជាអ្នកសង្រួមផ្លូវវាចា គឺជាការសង្រួមដោយមគ្គនោះឯង ព្រោះលះមិច្ឆាវាចាទាំងអស់ ដោយសម្មាវាចា ។

បទថា **ចេតសា** គឺ ដោយសមាធិ ។ នៅក្នុងទីនេះ ពោលដល់សម្មាសមាធិដែលជាចំណុចធំរបស់ចិត្ត អធិប្បាយថា មគ្គធម៌ទាំងឡាយមានសម្មាទិដ្ឋិជាដើម (វៀរសម្មាវាចា ១, សម្មាកម្មន្តៈ ១ និងសម្មាអាជីវៈ ១ ) ដែលមានលក្ខណៈជាអង្គមគ្គ រមែងកាន់យកដោយសព្ទថា សម្មាសមាធិនោះឯង ហើយបានលះនូវអសំវរទាំង-ឡាយមានអភិជ្ឈាជាដើមមិនមានសេសសល់ ជាការសម្តែងដោយមគ្គសំវរ ព្រោះហេតុនោះ ទើបព្រះនាងពោលថា **សម្វុតំ តណ្ហំ អព្វយ្ហ** ។

បទថា **សីតិភូតម្ហិ និព្វុតា** ជាអ្នកដល់ភាពត្រជាក់ ព្រោះមិនមានការក្តៅក្រហាយដោយកិលេសទាំងពួង ជា



បុគ្គលរលត់ដោយអនុបាទិសេសនិព្វានធាតុ ។

**សូមអនុមោទនា !**

# បទគួរយល់ដឹង

១. កុំចេះតែគិតថា អ្នកនេះ អ្នកនោះ អត់បានការ គ្រាន់តែចេះអង្គុយសង្កត់កន្ទេលកុំឱ្យប៉ើងប៉ុណ្ណឹង ក៏ចាត់ទុកថាបានការ មានប្រយោជន៍ដែរ ។

គ្រាន់តែគេជេរយើងប៉ុណ្ណោះ អរគុណគេទៅ ព្រោះគេអត់បានមកដាក់ថ្នាំបំពុលក្នុងពាងទឹកយើង ឬដុតផ្ទះយើង ។

មនុស្សម្នាក់កើតមក គ្រាន់តែមិនបានធ្វើឱ្យអ្នកដទៃក្តៅក្រហាយ ដោយការបៀតបៀនអ្វីមួយ ក៏ឈ្មោះថា ល្អណាស់ហើយ ។

ចូរហ្វឹកហាត់ក្នុងការសម្លឹងមើលលោកនេះ ដោយ

ចិត្តស្អប់ស្អល់ កុំចេះតែគិតថា អ្នកដែលនៅជុំវិញយើង ត្រូវតែសាងប្រយោជន៍ឱ្យយើង យ៉ាងនេះមួយ យ៉ាងនោះមួយ ដូច្នេះឡើយ ។

រៀនអប់រំបញ្ញា សម្លឹងឱ្យបានប្រយោជន៍អំពីអ្វីៗគ្រប់យ៉ាងក្នុងលោក ពោលគឺសម្លឹងដោយការកាន់យកជាអារម្មណ៍នៃការអប់រំចិត្ត ដូច្នេះពិតជាមិនមានអ្វីមួយដែលអាក្រក់សម្រាប់យើងឡើយ ។

បុគ្គលអ្នកមានបញ្ញា រមែងសម្រេចប្រយោជន៍តាមផ្លូវចិត្តបាន សូម្បីតែរឿងនោះបានធ្វើឱ្យបុគ្គលដែលខ្វះបញ្ញាកើតទុក្ខក៏ដោយ ។

សុខភាពផ្លូវចិត្តនៃអ្នកដែលមានបញ្ញា គឺល្អជានិច្ចមានបញ្ញាចំពោះតែផ្លូវកាយប៉ុណ្ណោះ ។

២. អាចតម្កល់ខ្លួនឱ្យប្រពៃក្នុងគុណធម៌ ឋិតថេរទៅបាន ចាំបាច់ត្រូវតែចេះអត់ទ្រាំ គ្របសង្កត់កិលេសគ្រប់ប្រភេទ កុំឱ្យកិលេសច្រានទម្លាក់ជ្រោះ ។

អំណត់មានអំណាច គឺមនុស្សយើងអាចបានជា



មនុស្សល្អដោយខន្តិធម៌ ព្រមទាំងមាននូវអំណាចតេជះខ្លាំងក្លា បីដូចសក្កទេវរាជដែលមានវជិរាវុធក្នុងព្រះហស្តដូច្នោះឯង ។

សេចក្តីអត់ធន់ត្រូវតែប្រកបដោយសតិសម្បជញ្ញៈស្គាល់ជីវិតតាមសេចក្តីពិត ស្គាល់លោកនេះ ជាពិសេសស្គាល់កិលេសពិតប្រាកដ ។

៣. ការព្រមព្រៀងគ្នានាំមកនូវសេចក្តីសុខ ។ កុំគិតកាលវែង គឺកុំចងពៀរ កុំគិតកាលខ្លី គឺកុំប្រញាប់បែកមិត្ត ។ ការបែកបាក់គ្នានាំឱ្យមានចិត្តមិនល្អ និយាយអាក្រក់ពីគេ មានពួកយើង មានពួកគេ ចិត្តក្តៅក្រហាយមិនស្ងប់រហូតនាំទៅដល់សង្គ្រាម ។

កុំសេពគប់ជនពាល ត្រូវសេពគប់បណ្ឌិត
ប្រយ័ត្នពាលក្នុងចិត្ត ថែបណ្ឌិតក្នុងខ្លួន ។

៤. កុំធ្វើឱ្យអ្នកដទៃខ្មាសគេ ព្រោះគេនឹងស្អប់យើងរហូតអស់ជីវិត ។ រឿងណាដែលមិនចង់ឱ្យគេប្រព្រឹត្តមកលើយើង រឿងនោះយើងកុំប្រព្រឹត្តដាក់អ្នក

ដទៃឡើយ ។

មនុស្សទន់ទាប តូចតាចយ៉ាងណាក៏មានបេះដូងដែរ កុំឃើញគេអន់ថយចេះតែមើលងាយ ជិះជាន់សង្កត់សង្កិនគេតាមចិត្តខ្លួននោះ វិបាកកម្មមានពិត បៀតបៀនសត្វស្រមោចក៏មានពៀរដែរ ។

គួរអប់រំមេត្តា ឃើញចិត្តឃើញថ្លើមអ្នកដទៃ អ្នកណាក៏ចង់បានសុខដែរ គប្បីមានខ្លួនឯងជាឧបមា ។

៥. ទាំងយើងទាំងអ្នកដទៃ មិនមានអ្វីក្រៅពីចិត្ត ចេតសិក រូបនោះឡើយ ។ គិតថាយើងគ្រាន់បើ ប៉ុន្តែដោយបរមត្ថ ពិតជាអត់មានយើងឡើយ គិតថាគេអន់តែតាមពិត គេក៏គឺជាចិត្ត ចេតសិក រូបដែរតើ ។

ភារៈធ្ងន់បំផុត គឺបញ្ចក្ខន្ធដែលប្រកាន់ថាជាខ្លួនយើងនេះឯង ទីបំផុតសម្លាប់យើងទៀត ដូច្នេះទើបមិនគួរមានះលើកតម្កើងខ្លួនឯង ហើយមើលងាយអ្នកដទៃនោះឡើយ ព្រោះថាខន្ធ ៥ របស់អ្នកដទៃមិនបានមកសម្លាប់យើងទេ ។



៦. ចង់រួចផុតចាកទុក្ខឆាប់ ត្រូវប្រញាប់កំណត់ដឹងទុក្ខតាមពិត បើគ្រាន់តែចង់ផុតទុក្ខ ប៉ុន្តែមិនស្គាល់ទុក្ខ មុខតែចាញ់បោកតណ្ហា ។

ការកំណត់ដឹងទុក្ខ ដោយអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ទើបបានដកតណ្ហាព្រមទាំងឫសគឺអវិជ្ជា។

អប់រំសតិប្បដ្ឋាន គឺបដិបត្តិកំណត់ដឹងទុក្ខ ។

៧. ផែនដីនេះ មានភ្នំ មានជ្រោះ នឹងឱ្យលោកនេះរាបស្មើបានយ៉ាងដូចម្តេចទៅ ។

ក្នុងលោកនេះ វរវីកដោយរឿងនេះ រឿងនោះអ៊ីចឹងឯង កុំចាំបាច់ឱ្យលោកនេះស្ងប់សិន សឹមយើងរកសុខនោះ ត្រូវអប់រំចិត្តឱ្យសុខស្ងប់ខ្លួនឯង ឥឡូវនេះតែម្តង ដោយការព្រមទទួលសេចក្តីពិត ព្រោះថា អ្វីៗសុទ្ធតែពិតទៅតាមបច្ច័យទាំងអស់ ។

## ៥~ ព្រះធម្មាថេរីគាថា

(បិដកលេខ ៥៧, ទំព័រ ១៤៨)

**បិណ្ឌបាតំ ចរិត្វាន ទណ្ឌមាទាយ ទុព្វលា**
**វេធមានេហិ គត្តេហិ តត្ថេវ និបតឹ ឆមា**
**ទិស្វា អាទីនវំ កាយេ អថ ចិត្តំ វិមុច្ចិ មេ ។**

ខ្ញុំមានកម្លាំងថយ កាន់ឈើច្រត់ដើរទៅបិណ្ឌបាត មានខ្លួនផេងផោង ដួលលើផែនដីក្នុងទីនោះឯង ។ លំដាប់នោះ ចិត្តរបស់ខ្ញុំក៏បានរួចស្រឡះចាកកិលេស ព្រោះឃើញទោសក្នុងកាយ ។

## សេចក្តីក្នុងព្រះអដ្ឋកថា

ព្រះថេរីអង្គនេះ បានបំពេញនូវបុញ្ញាធិការទុកមក តាំងតែអំពីព្រះពុទ្ធអង្គមុនៗ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ បានរួបរួមនូវ



បុញ្ញសម្ភារទុកហើយ លុះដល់កាលនៃពុទ្ធុប្បាទនេះ បានកើតក្នុងត្រកូលក្រុងសាវត្ថី ។ កាលដែលនាងកុលធីតាចម្រើនវ័យហើយ ក៏បានទៅកាន់ត្រកូលខាងស្វាមីដែលសមគួរនឹងគ្នា នាងមានសទ្ធាក្នុងព្រះពុទ្ធសាសនាណាស់ បំណងនឹងបួស តែស្វាមីមិនអនុញ្ញាត ។ ក្រោយមកស្វាមីបានធ្វើមរណកាលទៅ នាងក៏បួសចម្រើនវិបស្សនា ។ ថ្ងៃមួយ ព្រះធម្មាថេរីនិមន្តបិណ្ឌបាត កំពុងនិមន្តមកកាន់វិហារ ក៏បានទន់ជើងដួលចុះ ទើបធ្វើរឿងនោះឯងឱ្យជាអារម្មណ៍ ចម្រើនវិបស្សនាសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ហើយបានពោលនូវព្រះគាថានេះជាឧទាន ។

បណ្តាបទទាំងនោះ បទថា **បិណ្ឌបាតំ ចរិត្វាន ទណ្ឌមាទាយ ទុព្វលា** ដោយសេចក្តីថា ប្រើឈើច្រត់ទប់ខ្លួននិមន្តទៅបិណ្ឌបាតក្នុងក្រុង ។

បទថា **ឆមា** បានដល់ លើផែនដី អធិប្បាយថា ដួលចុះលើផែនដី ព្រោះជើងទាំងពីរមិនមានកម្លាំង ។

បទថា **ទិស្វា អាទីនវំ កាយេ** ដោយសេចក្តីថា ឃើញទោសក្នុងសរីរៈដោយប្រការផ្សេងៗ មានមិនស្អាត មិនទៀង ជាទុក្ខ ជាអនត្តាជាដើម ដោយបញ្ញាចក្ខុ ។

បទថា **អថ ចិត្តំ វិមុច្ចិ មេ** ដោយសេចក្តីថា ចិត្តរបស់ខ្ញុំរួចផុតហើយចាកកិលេសទាំងឡាយ ព្រោះគ្របសង្កត់ទុកដោយនិព្វិទានុបស្សនាជាដើម ដែលមានអាទីនវញ្ញាណប្រព្រឹត្តទៅខាងមុខ ។ ឈ្មោះថារួចផុតហើយ គឺផុតវិសេសហើយដោយប្រការទាំងពួង បានដល់សមុច្ឆេទវិមុត្តិតាមលំដាប់នៃមគ្គ និងដោយបដិបស្សទ្ធិ-វិមុត្តិទៀត អធិប្បាយថា ឥឡូវនេះ អ្វីៗដែលត្រូវរួចផុតទៀត មិនមានដល់ព្រះធម្មាថេរីឡើយ ។

នេះគឺជាការព្យាករព្រះអរហត្តផលនៃព្រះធម្មា-ថេរី ដោយឧទានគាថានេះឯង ។

**សូមអនុមោទនា !**



# បទគួរយល់ដឹង

១. បុគ្គលស្រោចទឹកកូនឈើត្រង់គល់ មិនមែនរង់ចាំឱ្យឫស ឱ្យគល់ បញ្ចេញផលផ្លែផ្កាឱ្យខ្លួននោះទេ ព្រោះផលផ្លែផ្កានៅចុងមែកឯណោះ ពេលដែលដើមវាធំឡើង យ៉ាងណាមិញ បុគ្គលកាលធ្វើល្អឱ្យដល់អ្នកណា មិនគប្បីត្រូវការឱ្យអ្នកនោះតបស្នងមកវិញឡើយ តាមពិតប្រយោជន៍នៃសេចក្តីល្អ សំខាន់បំផុតគឺអភិវឌ្ឍន៍ផ្លូវចិត្តរបស់ខ្លួន យ៉ាងនោះឯង ត្រង់អ្នកដទៃដឹងគុណគឺជាបុណ្យរបស់គេដោយឡែក ។

បុគ្គលដែលមានចិត្តបានអប់រំចម្រើនខ្ពស់ហើយ ឈ្មោះថាបានអ្វីៗគ្រប់យ៉ាងអំពីលោកនេះ មានសេចក្តីសុខស្ងប់ក្នុងលោក ព្រោះអ្វីៗក្នុងលោក ជាបញ្ញត្តិក្តី ជាបរមត្ថក្តី រមែងបានជាអារម្មណ៍នៃកម្មដ្ឋាន ដែលជាការបានខ្ពស់បំផុត ប្រព្រឹត្តទៅរកការអស់នូវអាសវក្កិលេស ដូច្នេះ បុគ្គលដែលមានបញ្ញា ទើបមិនត្រូវការឱ្យអ្នកដែល

ខ្លួនបានជួយហើយនោះ តបស្នងអ្វីមកទៀតឡើយ ។

ផលនៃការលះបង់ គឺលះបង់បានហ្នឹងឯង ។ សេចក្ដីសុខក្នុងចិត្ត មិនអាចរកទិញបានដោយមាសប្រាក់នោះឡើយ ។

២. យើងមិនអាចយកបុណ្យរបស់អ្នកដទៃមកលះបាបរបស់យើងបានឡើយ ហើយក៏មិនអាចលះកិលេសក្នុងចិត្តយើង ដោយបញ្ញារបស់អ្នកដទៃបានដែរ ដូច្នេះបើយើងមិនខំសន្សំបុណ្យខ្លួនឯង និង ស្ដាប់ធម៌អប់រំបញ្ញាទេ តើបានអ្នកណាជួយយើងឱ្យផុតចាកទុក្ខបាន ។ ក្នុងព្រះគាថាធម្មបទ ព្រះពុទ្ធអង្គទ្រង់ត្រាស់ប្រារព្ធសេដ្ឋីជើងឆ្មា អំពីការសន្សំបុណ្យថា

បុគ្គលមិនគួរមើលងាយបុណ្យថា មានប្រមាណតិចនឹងមិនឱ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយតំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណាមិញ អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្ដងៗ គង់ពេញបានដោយបុណ្យ យ៉ាងនោះដែរ ។



ព្រះពុទ្ធអង្គ ទ្រង់ប្រារព្ធការបរិច្ចាគមានប្រមាណតិចរបស់ព្រះអង្គ កាលដែលព្រះអង្គជាសង្ខព្រាហ្មណ៍ បានថែរក្សាព្រះចេតិយនៃព្រះបច្ចេកពុទ្ធ ព្រះនាមសុសិមជាបុត្របង្កើតនៃព្រះអង្គ ត្រាស់ព្រះគាថាធម្មបទក្នុងបកិណ្ណកវគ្គ មានសេចក្ដីថា

បើឃើញសេចក្ដីសុខដ៏ធំទូលាយ ព្រោះលះបង់សុខល្មមប្រមាណ អ្នកមានប្រាជ្ញា កាលឃើញសុខធំទូលាយ គប្បីលះបង់សុខល្មមប្រមាណចេញ ។

ក្នុងអដ្ឋកថាទានសូត្រ អង្គុត្តរនិកាយ សត្តកនិបាត បានសម្ដែងថា ទានដែលជាគ្រឿងប្រដាប់តាក់តែងចិត្តនេះឯង គឺជាទានដែលប្រកបដោយសមថៈនិងវិបស្សនា ដូច្នោះ ទើបញុាំងឈាន និងអរិយមគ្គឱ្យកើតឡើង បដិសន្ធិក្នុងព្រហ្មលោកជាព្រះអនាគាមី នេះជាទានមានផលច្រើន មានអានិសង្សច្រើន ។

# ៦. ព្រះសុមង្គលមាតាថេរីគាថា

( បិដកលេខ ៥៧, ទំព័រ ១៤៩-១៥០ )

សុមុត្តិកេ សុមុត្តិកា សាធុ មុត្តិកម្ហិ មុសលស្ស
អហិរិកោ មេ ឆត្តកំ វាបិ ឧក្ខលិកា មេ ទលិទ្ទតាវាតិ។
រាគញ្ច អហំ ទោសញ្ច វិច្ឆិន្ទន្តី វិហរាមិ
សារុក្ខមូលមុបគម្ម អហោ សុខន្តិ សុខតោ ឈាយាមិ។

ខ្ញុំរួចស្រឡះ ផុតស្រឡះ រួចល្អហើយ ចាក អង្រែ ចាកស្វាមីរបស់ខ្ញុំដែលមិនខ្មើមបាប ចាកឆត្រ ចាកឆ្នាំងបាយរបស់ខ្ញុំ និង រួចចាកភាពជាអ្នកក្រីក្រ ។

ខ្ញុំបានផ្តាច់ផ្តិលរាគៈនិងទោសៈហើយ ខ្ញុំនោះចូលទៅរកគល់ឈើ ហើយចម្រើនឈានមានសេចក្តីសុខថា ឱសុខណាស់ហ្ន៎ !



# សេចក្តីក្នុងព្រះអដ្ឋកថា

ព្រះថេរីអង្គនេះ ក៏បានសាងសន្សំនូវបុញ្ញាធិការទុកមកតាំងតែអំពីព្រះពុទ្ធអង្គមុនៗដែរ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងកាលនៃពុទ្ធុប្បាទនេះ បានកើតក្នុងត្រកូលក្រីក្រក្នុងក្រុងសាវត្ថី លុះចម្រើនវ័យហើយ ឪពុកម្តាយបានលើកកូនឱ្យទៅអ្នកត្បាញឫស្សីធ្វើកញ្ជើធ្វើល្អីម្នាក់ ជាប្តីប្រពន្ធនឹងគ្នា បានកូនប្រុសច្បងឈ្មោះសុមង្គលៈ ។

សុមង្គលៈ ចម្រើនវ័យហើយ ជាអ្នកមាននង្គ័ល មានចប មានកណ្តៀវ ដែលជាសម្បត្តិរបស់មនុស្សគម (ឱនច្រូតស្រូវជាដើម ) ជាបរិក្ខារ ចិញ្ចឹមជីវិតដោយការភ្ជួរស្រែឱ្យគេ ។ ថ្ងៃមួយ កាលដែលព្រះបាទបសេនទិ-កោសលបំពេញមហាទាន ថ្វាយព្រះដ៏មានព្រះភាគនិងព្រះភិក្ខុសង្ឃ សុមង្គលៈបានកាន់ឆ្នាំងទឹកដោះគោជូរ ដើររួមទៅជាមួយនឹងមនុស្សទាំងឡាយ ដែលសុទ្ធតែកាន់

ទេយ្យវត្ថុទាំងអស់គ្នា ។ សុមង្គលៈបានឃើញ **សក្ការៈ-សម្មាន** នៃភិក្ខុទាំងឡាយហើយគិតថា ពួកព្រះសមណ-សក្យបុត្រនេះ ស្លៀកដណ្ដប់សំពត់សាច់ម៉ដ្ដ ឆាន់ចង្ហាន់ល្អៗ ឯសេនាសនៈក៏សមរម្យទៀត ម៉េចបានជាយើងមិនបួស ។ លុះគិតដូច្នេះហើយ ក៏ចូលទៅរកព្រះមហាថេរមួយអង្គ ក្រាបទូលអំពីបំណងរបស់ខ្លួនដែលចង់បួស ។ ព្រះថេរៈអាណិតអាសូរ បានបំបួសឱ្យហើយប្រទានព្រះ-កម្មដ្ឋាន ។

ព្រះសុមង្គលៈ បួសហើយនៅព្រៃមានការអផ្សុកចង់សឹក (លាសិក្ខ) ទើបចូលទៅរកពួកញាតិ បានឃើញអ្នកស្រែស្លៀកពាក់សៅហ្មង រាងកាយប្រឡាក់ទៅដោយភក់ ហាលថ្ងៃហាលខ្យល់ ត្រឡប់បាននូវសេចក្ដីសង្វេគស្លុតចិត្តថា មនុស្សសត្វទាំងនេះសោយទុក្ខខ្លាំងណាស់ហ្ន៎ ព្រោះការចិញ្ចឹមជីវិតជាហេតុ ។ កម្មដ្ឋានដែលលោកបានរៀនមកក៏ប្រាកដក្នុងពេលនោះ ព្រោះញាណចាស់ក្លា លោកត្រឡប់មករកគល់ឈើមួយដើម បាននូវភាព



ស្ងប់ស្ងាត់ មានយោនិសោមនសិការ ចម្រើនវិបស្សនាហើយ សម្រេចព្រះអរហត្តតាមលំដាប់នៃមគ្គ ព្រមដោយបដិសម្ភិទាទាំងឡាយ ។

តាំងអំពីព្រះសុមង្គលៈបានសម្រេចព្រះអរហត្តមកញោមស្រីរបស់លោក គេបានស្គាល់ជាទូទៅថា សុមង្គល-មាតា ប៉ុន្តែ ដោយនាមនិងគោត្ររបស់ខ្លួនមិនប្រាកដទើបក្នុងបិដកដាក់ថា ថេរីភិក្ខុនីមួយរូប មាននាមនិងគោត្រមិនប្រាកដ ។ សុមង្គលមាតា បានចេញចាកផ្ទះមកបួស ចម្រើនវិបស្សនា ព្រមដោយសេចក្ដីសង្វេគចំពោះទុក្ខលំបាកកាលពីខ្លួននៅជាគ្រហស្ថ ។ កាលដែលព្រះសុមង្គលមាតាថេរី ចម្រើនវិបស្សនាបានសម្រេចព្រះអរហត្តហើយ ព្រមទាំងបាននូវបដិសម្ភិទាទាំងឡាយផងនោះ ទើបបានបន្លឺនូវឧទានពីរព្រះគាថានោះឯង ។

បណ្ដាបទទាំងនោះ បទថា **សុមុត្តិកា** ប្រែថា ផុតល្អហើយ ។ ក នេះគ្រាន់តែធ្វើបទឱ្យពេញ ដោយសេចក្ដីថា ផុតហើយដោយល្អហ្ន៎ ។ ព្រះថេរីនោះ ឃើញសម្បត្តិ

ដែលខ្លួនបានក្នុងព្រះសាសនា ទើបពោលដោយសេចក្ដីជ្រះថ្លា ឬដោយការសរសើរនូវសម្បត្តិនោះថា **សុមុត្តិកេ សុមុត្តិកា** ប៉ុន្តែកាលដែលព្រះថេរីសម្ដែងអំពីការរួចផុតចាកអ្វីៗដែលខ្លួនរង្កៀស ជាពិសេសក្នុងពេលដែលនៅជាគ្រហស្ថ ទើបពោលពាក្យជាដើមថា **សាធុ មុត្តិកម្ហិ** ដោយសេចក្ដីថា យើងជាអ្នករួចផុតដោយប្រពៃមែន ។

បទថា **មុសលស្ស** ប្រែថា ចាកអង្រែ ។ ព្រះថេរីអង្គនេះ កាលដែលនៅពីគ្រហស្ថ បុកស្រូវ បុកអង្ករដោយខ្លួនឯង ព្រោះភាពជាអ្នកក្រីក្រ ។

បទថា **អហិរិកោ** មេ ដោយសេចក្ដីថា ប្ដីរបស់យើង ជាមនុស្សមិនមានហិរិ គឺប្រាសចាកការខ្មាសខ្ពើមបាប បន្ថែមពាក្យថា ខ្ញុំមិនពេញចិត្តនឹងគាត់ ។ ព្រះថេរីពោលដោយការរង្កៀសចំពោះបុគ្គល ដែលជ្រមុជជ្រមុលក្នុងកាម ព្រោះព្រះថេរីមានចិត្តប្រាសចាកតម្រេកក្នុងកាមទាំងឡាយហើយជាប្រក្រតី ។

បទថា **ឆត្តកំ វាបិ** ដោយសេចក្ដីថា ទោះជាឆត្រ



ដែលយើងធ្វើជាមុខរបរចិញ្ចឹមជីវិត ក៏យើងមិនពេញចិត្តដែរ ។ **វា** សព្ទនេះមានសេចក្ដីរួមទាំងរបស់អ្វីផ្សេងទៀតដែលមិនបានពោល ដូចជាកញ្ជើ ល្អី ប្រអប់ ហឹបជាដើម ព្រះថេរីពោលដោយក្ដីរង្កៀស ចំពោះជីវិតលំបាកលំបិន ព្រោះត្រូវយកឈើ យកឫស្សីមកធ្វើឆត្រជាដើមរាល់ថ្ងៃ។

បទថា **ឧក្ខលិកា** មេ គឺឆ្នាំងបាយ ឆ្នាំងសម្លរបស់យើង ។

បទថា **ឧលិទ្ធគារាវាតិ** គឺភាពជាអ្នកកម្សត់ក្រីក្រប្រកបសេចក្ដីថា យើងជាអ្នករួចផុតដោយប្រពៃអំពីរឿងចានឆ្នាំងនិងភាពក្រលំបាកនោះៗ ។

បទថា **រាគញ្ច អហំ ទោសញ្ច ចិច្ឆិន្ទន្តី វិហរាមិ** ដោយសេចក្ដីថា យើងកាត់ផ្ដាច់នូវរាគៈនិងទោសៈដែលជាមេនៃកិលេស ហើយសម្រាន្តនៅ គឺជាការកម្ចាត់បង់បានដោយដាច់ខាតព្រមទាំងសំឡេងផង ។ បានស្ដាប់មកថា ព្រះថេរីនោះមានការរង្កៀសចំពោះស្វាមីរបស់ខ្លួន តិះដៀលសំឡេងដែលប្ដីកាត់ ពុះ ច្រៀកនូវដើម

ឬស្សីរាល់ថ្ងៃ ទើបបានពោលអំពីការលះបង់ស្វាមីដូចគ្នា នឹងការលះបង់រាគៈនិងទោសៈ ។

បទថា **សារុក្ខមូលមុបគម្ម** ដោយសេចក្ដីថា យើងគឺសុមង្គលមាតានោះ ចូលទៅកាន់គល់ឈើដែលស្ងាត់។

បទថា **សុខតោ ឈាយាមិ** ដោយសេចក្ដីថា យើងសម្លឹងថាជាសុខ គឺយើងចូលសមាបត្តិតាមកាលដ៏សមគួរ សោយផលសុខនិងនិព្វានសុខ គឺជាការចូលកាន់ផលសមាបត្តិ ។

បទថា **អហោ សុខំ** នេះ ព្រះថេរីពោលដោយអំណាចនៃមនសិការ ដែលប្រព្រឹត្តទៅនៅពេលចេញអំពីសមាបត្តិ ថា ឱសុខណាស់តើ ។

**សូមអនុមោទនា !**



## បទគួរយល់ដឹង

ពួកមាន់ដែលគេចាប់ដាក់ក្នុងទ្រុង បម្រុងនឹងនាំយកទៅសម្លាប់ នៅចឹកគ្នា នៅសម្គាល់ថាខ្លួនធំខ្លាំងក្នុងទ្រុងដ៏តូចនោះ ។ មនុស្សដើរមកឃើញក៏នឹកសង្វេគក្រៃលែង ឱមាន់អើយមាន់ ជិតដល់ពេលគេអារកសម្លាប់ហើយ នៅឈ្លោះវិវាទបៀតបៀនគ្នាឯងទៀត ។

មនុស្សយើងក៏ត្រូវបានក្រុងនៅក្នុងទ្រុងតូចដូចគ្នាដែរ គឺចាប់ពីកើតមកដល់ស្លាប់ ពេលវេលាតិចណាស់ ជរា ព្យាធិ ជំងឺគ្រប់មុខ ។ តាំងពីថ្ងៃបដិសន្ធិមក គឺជាអ្នកទោសឧក្រិដ្ឋស្រេចទៅហើយ ត្រូវកាត់ទោសប្រហារជីវិត មុននឹងសម្លាប់ត្រូវដាក់ទារុណកម្មឱ្យចិញ្ចឹមមើលថែបញ្ចក្ខន្ធដែលជាភារៈធ្ងន់ដ៏ក្រៃលែង ។

លោកនេះគឺជាលានប្រហារជីវិត ទាំងដែលមិនប្រាប់ពេលវេលាជាមុនឡើយ ឯវិធីប្រហារក៏ច្រើនបែបច្រើនយ៉ាង គ្រឿងសម្លាប់រាប់មុខមិនអស់ ។

មនុស្សដែលអត់បញ្ញានៅបៀតបៀនគ្នា ដូចមាន់ក្នុងទ្រុង ទាំងដែលមិនដឹងថាខ្លួនឯងស្លាប់ពេលណាផង។

តាមពិត គួរតែមេត្តាគ្នា ជួយគ្នា មនុស្សយើងខុសពីមាន់ត្រង់ដែលស្ដាប់ធម៌យល់ រកឧបាយឱ្យរួចពីស្លាប់ ។

## ជីវិតព្រះសុមង្គលមាតាថេរី

(កំណាព្យពាក្យ ៨)

សុមង្គលមាតាថេរី ឧបនិស្ស័យថ្លៃថ្លាឱភាស
ទោះក្រលំបាកតោកយ៉ាកនៅផ្ទះ លុះដល់ពេលលះស្រឡះប្រពៃ ។
កើតមកក្រីក្រត្រដររំរស់ រកបាយដាក់ពោះរស់អត់មានន័យ
មិនទាន់ជួបធម៌ម៉ែឪលកលៃ លើកឱ្យមានប្ដីភ័យនៅជាប់តាម ។
អង្រែត្បាល់បុកសម្រុកការងារ មានប្ដីជាគ្នារងារហាម
បម្រើខន្តប្រាំទុក្ខចាំជាប់តាម ប្ដីងប់ក្នុងកាមរហាមភរិយា ។
ក្នុងព្រះគាថាវាចារៀបរាប់ មានគ្រប់មានសព្វហៅសែនកំព្រា
ចិញ្ចឹមជីវិតកាយចិត្តគ្រាំគ្រា រស់ខ្វះធម្មារងាទីពឹង ។
សំណាងបានព្រះត្រាស់ដឹងក្នុងលោក ថែមទាំងជួបជោគកូនបានចេះដឹង
បួសក្នុងសាស្នាប្រាជ្ញារឹងប៉ឹង កូនបានត្រាស់ដឹងជាព្រះអរហន្ត ។



ឧបនិស្ស័យម្ដាយថ្លៃមិនខ្សត់ ក្នុងសង្សារវដ្ដមិនមែនអាប់អន់
បុណ្យបានសន្សំអប់រំគ្រប់គ្រាន់ លែងវង្វេងភាន់រួសរាន់បព្វជ្ជា ។
ម្ដាយបួសតាមបុត្រលះបង់ស្វាមី លះកញ្ជើល្អីលះគ្រប់ការងារ
ជាងមិនទាន់ស្លាប់ក្រឡាប់ខ្លួនភ្ញារ ចូលកាន់បព្វជ្ជាលាចាកលោកិយ ។
បួសហើយខំនឹករលឹកឃើញទុក្ខ រឿងរ៉ាវគ្រប់មុខជាទុក្ខអប្រិយ
រវល់ខ្លាំងណាស់ចោលអស់ក្នុងដី មគ្គអង្គប្រាំបីថេរីយាត្រា ។
ក្រោមម្លប់រុក្ខាកាសាវពស្ត្រ លះកង្វល់អស់ព្រោះវិបស្សនា
ផលសមាបត្តិស្ងប់ស្ងាត់តណ្ហា និព្វានសុខា អហោសុខំ ។
សុមុត្តិកេ សុមុត្តិកា ថេរីគាថាមហាកម្លាំង
កាត់ផ្ដាច់ចំណងកន្លងផុតខ្នាំង ផុតពីទុក្ខចំបាំងឈ្នះសត្រូវ ។
ឱសាធុជនធ្ងន់ក្នុងសាស្នា ជីវិតនេះណាជាការដើរផ្លូវ
ធម៌ជាផែនទីសំភីដើរទៅ ស្រុកមានសត្រូវកុំនៅសម្រាក ។
ជីវិតខ្ពង់ខ្ពស់លាភយសប៉ុនណា ចុងក្រោយមរណាដូចការបិទឆាក
នៅពេលដើរតួរឿងរ៉ាវឥតស្រាក សុខឬលំបាកបិទឆាកសូមលា ។
រូបកាយនៅរស់ស្រស់ស្រាយចរចា ពេលអស់ជីវ៉ាគេថាបូជា
សូន្យទាំងរូបកាយធ្លាប់បាយជុំគ្នា ទោះមិនបូជាក៏លាគ្នាហើយ ។
រាប់អានជួបជុំផ្សំផ្គុំស្នេហា ជាប់ក្នុងលោកាប្រាថ្នាធូរស្បើយ
តែគេចមិនផុតជួបព្រាត់ហ្នឹងហើយ បើចង់ធូរស្បើយរកត្រើយនិព្វាន ។

កុំជាប់លោកិយបីដូចមាយា ចង់បានសុខជាសង្ខារមិនមាន
សុខពិតមានតែក្នុងព្រះនិព្វាន រោគទាំងប៉ុន្មានទុកជូនសង្ខារ ។
ប្រាថ្នាផុតទុក្ខត្រូវផុតលោកិយ ត្រូវដឹងថាអ្វីជាក្តីទុក្ខា
មិនដឹងទុក្ខពិតជាប់ស្អិតតណ្ហា ទាល់តែសិក្សាសតិប្បដ្ឋាន ។
ធ្វើអត្តឃាតឃ្លាតពីធម៌ព្រះ បើបានជាលះកុំលះបង់ប្រាណ
ត្រូវលះប្រកាន់ពីចិត្តសន្តាន ចិត្តពិតក្សេមក្សាន្តបានមួប់ព្រះធម៌ ។
ជួបរឿងមិនស្មោះព្រោះអស់និស្ស័យ កុំឆេវឆាវអីខន្តីទើបល្អ
សិក្សាការពិតជីវិតបវរ ដើរតាមផ្លូវធម៌រឿងល្អទេតើ ។
គ្មានរឿងអ្វីដែលមិនមែនការពិត ដឹងហើយសុខចិត្តបណ្ឌិតសរសើរ
សតិប្បដ្ឋានជាដានដំណើរ និមន្តយាងដើរគ្រប់អង្គទាំងអស់ ។
អត់ឃ្លានមានក្ររបរត្រឹមត្រូវ ជួញដូរក្នុងផ្លូវនៃសប្បុរស
ផ្លូវលោកផ្លូវធម៌កុំឱ្យមានទាស់ ផ្លូវល្អឥតខ្ចោះមគ្គអង្គប្រាំបី ។
និព្វានជាធម៌ប្រាសចាករាគៈ សុមង្គលមាតាថេរី
លះកាត់គ្រឿងចងចំណងលោកិយ ព្រះម្ចាស់ថេរីនិព្វានសុខហោង ។

ប.ស.ទ.



# ៧. ព្រះអភយមាតាថេរីគាថា

(បិដកលេខ ៥៧, ទំព័រ ១៥១)

**ឧទ្ធំ បាទតលា អម្ម អធោ ចេ កេសមត្ថកា**
**បច្ចវេក្ខស្សុមំ កាយំ អសុចឹ បូតិគន្ធិកំ ។**
**ឯវំ វិហារមានាយ សព្វោ រាគោ សមូហតោ**
**បរិឡាហោ សមុច្ឆិន្នោ សីតិភូតម្ហិ និព្វុតា ។**

បពិត្រមាតា សូមមាតាពិចារណានូវរូបកាយនេះ ជារបស់មិនស្អាត មានក្លិនស្អុយ ខាងលើចាប់ពីបាតជើងឡើងទៅ ខាងក្រោមចាប់ពីចុងសក់ចុះមក ។

កាលខ្ញុំប្រព្រឹត្តយ៉ាងនេះ ក៏បានដកនូវរាគៈទាំង-ពួង បានផ្តាច់នូវសេចក្តីក្រវល់ក្រវាយ ជាអ្នកមានចិត្តត្រជាក់ រលត់ទុក្ខហើយ ។

# សេចក្ដីក្នុងព្រះអដ្ឋកថា

ព្រះថេរីដែលជាព្រះមាតារបស់ព្រះអភយត្ថេរ អង្គនេះ ក៏បានសាងសន្សំនូវបុញ្ញាធិការទុកមកតាំងតែអំពីព្រះពុទ្ធអង្គមុនៗដែរ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។

ក្នុងកាលនៃព្រះដ៏មានព្រះភាគ ព្រះនាមតិស្សៈ[១] នាងជាកុលធីតា ថ្ងៃមួយបានឃើញព្រះបរមសាស្ដាស្ដេចយាងបិណ្ឌបាត មានចិត្តជ្រះថ្លា ទទួលបាត្រហើយថ្វាយភិក្ខាមួយវែក ។ ដោយបុញ្ញកម្មនោះ នាងត្រាច់ទៅក្នុងទេវលោកនិងមនុស្សលោក ក្នុងកាលនៃពុទ្ធុប្បាទនេះ នាងជានគរសោភិនី ឈ្មោះថាបទុមវតី ក្នុងក្រុងឧជ្ជេនី ដោយវិបាកនៃកម្ម ។ ព្រះបាទពិម្ពិសារទ្រង់បានស្ដាប់ឮអំពីរូបសម្បត្តិជាដើមរបស់នាងបទុមវតី ទើបត្រាស់ប្រាប់បុរោហិតថា យើងប្រាថ្នានឹងឃើញនាងបទុមវតីនៅនគរឧជ្ជេនី ព្រោះនាងជាស្រីស្អាតប្រចាំនគរ ។ បុរោហិត

១- ព្រះសម្មាសម្ពុទ្ធកាលអំពី ៩២ ផែនដីមុន ។



ក្រាបទូលថា ព្រះករុណាថ្លៃវិសេស ល្អណាស់ ។ បុរោហិតបាននាំយក្សឈ្មោះកុម្ភីរ មកដោយកម្លាំងនៃមន្តហើយប្រើអានុភាពយក្ស នាំព្រះរាជាទៅកាន់នគរឧជ្ជេនីក្នុងខណៈនោះតែម្ដង ។ ព្រះរាជាទ្រង់សម្រេចការនៅរួមជាមួយនឹងនាងបទុមវតីនោះអស់មួយរាត្រី នាងក៏មានគភ៌ដោយព្រះរាជា បានក្រាបទូលព្រះរាជាថា ខ្ញុំម្ចាស់តាំងគភ៌ហើយ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយត្រាស់ថា បើជាកូនប្រុស នាងចូរចិញ្ចឹមឱ្យល្អហើយប្រគល់ឱ្យយើង ទ្រង់បានប្រទាននូវព្រះទម្រង់ចារឹកព្រះនាមហើយស្ដេចយាងត្រឡប់មកព្រះនគរ ។

កន្លងទៅ ១០ ខែ នាងប្រសូតបុត្រ បានតាំងព្រះនាមបុត្រថា អភ័យ លុះបុត្រមានព្រះជន្ម ៧ ព្រះវស្សា នាងបានបញ្ជូនទៅថ្វាយព្រះរាជា ដោយប្រាប់ថា ព្រះបាទពិម្ពិសារមហារាជ ជាព្រះបិតារបស់បុត្រ ។ ព្រះបាទពិម្ពិសារទ្រង់ទតឃើញព្រះឱរសនោះហើយ ក៏បានកើតនូវសេចក្ដីស្រឡាញ់ចំពោះបុត្រ ទ្រង់ឱ្យបុត្រ

ចម្រើនទៅដោយគ្រឿងថែរក្សាសព្វគ្រប់ ។

ប្រវត្តិអភយរាជកុមារ មានក្នុងអភយរាជកុមារសូត្រ បិដកលេខ ២៣, ទំព័រ ១៤៩ ព្រមទាំងអដ្ឋកថា នៅក្នុងព្រះសូត្រនោះ អភយរាជកុមារធ្លាប់រាប់អានពួកនិគ្រន្ថ កាលដែលនិគ្រន្ថចាត់ឱ្យទៅលើកវាទៈព្រះដ៏មានព្រះភាគ បែរត្រឡប់ជាជ្រះថ្លារាប់អានព្រះរតនត្រ័យតាំងពីពេលនោះមក ។ នៅក្នុងអដ្ឋកថាធម្មបទ លោកវគ្គ អភយរាជកុមារបានទទួលរង្វាន់អំពីព្រះបិតា សោយរាជ្យ ៧ ថ្ងៃ ដល់ថ្ងៃទី ៨ ស្រីជាទីស្រឡាញ់ត្រូវខ្យល់ចាប់ស្លាប់ភ្លាមទៅ កើតទុក្ខខ្លាំងនឹករកព្រះពុទ្ធបរមគ្រូ ស្តាប់ព្រះធម៌ទេសនាបានសម្រេចសោតាបត្តិផល ។ នៅក្នុងអដ្ឋកថាថេរគាថា ឯកនិបាត វគ្គទី៣ មានប្រវត្តិលោកបួសក្នុងសាសនានៃព្រះពុទ្ធបទុមុត្តរៈ លោកជាព្រះធម្មកថិកមុននឹងសម្តែងព្រះធម៌ បានពោល ៤ គាថា សរសើរគុណព្រះដ៏មានព្រះភាគ ហើយទើបសម្តែងព្រះធម៌តាមក្រោយ ។ ដោយកម្លាំងនៃបុញ្ញកម្មនោះ លោកមិនមាន



បដិសន្ធិក្នុងអបាយភូមិរហូតដល់ជាតិចុងក្រោយ គឺពេលវេលា ១ សែនមហាកប្ប សមដូចដែលលោកពោលជាគាថាទុកមកថា

**អភិត្ថវិត្វា បទុមុត្តរំ ជិនំ**
**បសន្នចិត្តោ អភយោ សយម្ភុំ**
**ន គច្ឆិ កប្បានិ អបាយភូមឹ**
**សតសហស្សានិ ឧឡារសន្តោតិ ។**

ព្រះអភយត្ថេរ ជាបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលសរសើរព្រះជិនស្រីទ្រង់ព្រះនាមថាបទុមុត្តរៈ ជាព្រះសយម្ភូ លោកជាបុគ្គលមានសទ្ធាដ៏ឧឡារ (ខ្ពង់ខ្ពស់ ថ្លៃឧត្តម) មិនទៅអបាយភូមិរហូតសែនកប្ប ដូច្នេះឯង។

លោកជាបុគ្គលមានអណ្តូងនៃបុណ្យកុសលធំ រកប្រមាណមិនបាន បានជាដូច្នោះ ព្រោះសម្បត្តិមានខេត្តសម្បត្តិជាដើម និង ព្រោះបុព្វចេតនា បច្ឆិមចេតនា ព្រមទាំងសន្និដ្ឋានចេតនា (ចេតនាដែលចុះស៊ប់យល់ជាក់មិនភ្លេច ) របស់លោកមានភាពឧឡារ (ក្នុងពុទ្ធាបទាន

បិដកលេខ ៧២, ទំព័រ ១៥ សម្តែងថាព្រះពុទ្ធទាំងឡាយ ជាអចិន្តិយបុគ្គល គឺបុគ្គលដែលគេមិនគប្បីគិតកើត ធម៌របស់ព្រះពុទ្ធជាអចិន្តិយធម៌ យ៉ាងនេះ កាលបុគ្គលជ្រះថ្លាចំពោះគុណជាអចិន្តិយៈ រមែងបានផលជាអចិន្តិយៈ ) ។

ក្រោយមក កាលដែលព្រះបាទពិម្ពិសារសោយព្រះទិវង្គតហើយ លោកកើតសេចក្តីសង្វេគយ៉ាងខ្លាំង បានចូលកាន់ផ្នួសចម្រើនវិបស្សនាសម្រេចព្រះអរហត្ត ។

នាងបទុមវតី ក្រោយមកបានស្តាប់ធម៌ក្នុងសម្នាក់ព្រះអភយត្ថេរដែលជាបុត្ររបស់ខ្លួន បាននូវសទ្ធាបួសជាភិក្ខុនី ចម្រើនវិបស្សនាមិនជាយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តផល ព្រមដោយបដិសម្ភិទាទាំងឡាយ ព្រោះហេតុនោះ ព្រះនាងទើបបានពោលទុកក្នុងអបទានថា

កាលព្រះសាស្តាព្រះនាមតិស្សៈ ទ្រង់ស្តេចយាងបិណ្ឌបាត ខ្ញុំបានយកចង្ហាន់មួយវែកថ្វាយដល់ព្រះពុទ្ធដ៏ប្រសើរ ។ ព្រះសម្ពុទ្ធព្រះនាមតិស្សៈ ជាសាស្តា ជានាយកដ៏លើសលប់ក្នុងលោក ទ្រង់ទទួលហើយ ទ្រង់គង់នៅក្នុងផ្លូវ ទ្រង់បានអនុមោទនាដល់ខ្ញុំថា នាងប្រគេនចង្ហាន់មួយវែក នឹងបានទៅកើតក្នុងឋានតាវត្តិង្ស នឹងបានជាអគ្គមហេសីនៃស្តេចទេវតា ៣៦ ដង នឹងបានជាអគ្គមហេសីនៃស្តេចចក្រពត្តិ ៥០ ដង នឹងបាននូវសម្បត្តិទាំងពួងដែលនាងប្រាថ្នាហើយ តាមចិត្តប្រាថ្នាក្នុងកាលទាំងពួង ។ នាងនឹងទទួលនូវសម្បត្តិ ជាស្ត្រីមិនមានកង្វល់ នឹងបួសកំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹង បរិនិព្វាន ។ ព្រះសម្ពុទ្ធព្រះនាមតិស្សៈ ជានាយកដ៏លើសលប់ក្នុងលោក ព្រះអង្គជាអ្នកប្រាជ្ញ លុះត្រាស់នូវពាក្យនេះហើយ ក៏ហោះទៅឰដ៏អាកាស ដូចជាស្តេចហង្សហើរទៅក្នុងអាកាស ដូច្នោះឯង ។

**សុទិន្នមេវ មេ ទានំ សុយិដ្ឋា យាគសម្បទា**
**ភដច្ឆុតិក្ខំ ឧត្វាន បត្តាហំ អចលំ បទំ**[1] ។

ទានដែលខ្ញុំបានថ្វាយល្អហើយ យាគសម្បទា (យញ្ញសម្បត្តិ ) ខ្ញុំបានបូជាល្អហើយ ខ្ញុំបានថ្វាយនូវចង្ហាន់

១- បិដកលេខ ៧៦, ទំព័រ ១៣, បន្ទាត់ ៨-៩ ។

មួយវែក ហើយដល់នូវអចលបទ គឺព្រះនិព្វាន ។

ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយទានក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិនេះជាផលនៃការថ្វាយចង្ហាន់ ។ កិលេសទាំងឡាយខ្ញុំបានដុតបំផ្លាញហើយ ភពទាំងពួងខ្ញុំបានដកចោលហើយ ខ្ញុំជាស្រីមិនមានអាសវៈ ។ល។ ព្រះពុទ្ធសាសនា ខ្ញុំបានប្រតិបត្តិហើយ ។

កាលដែលព្រះអភយមាតាថេរី បានសម្រេចនូវព្រះអរហត្តហើយ បានពោលអាងនូវគាថាដែលព្រះ-អភយត្ថេរ ជាបុត្ររបស់ខ្លួនបានសម្តែងជាឱវាទហើយនូវគាថាភាសិតនោះ ទាំងគាថារបស់ខ្លួនផង ជាឧទាន ។

ទាំងពីរគាថានោះ គាថាទីមួយ មានសេចក្តីសង្ខេបដូច្នេះថា បពិត្រម៉ែបទុមវតី ចូរម៉ែពិចារណានូវសរីរៈនេះ ឈ្មោះថាកាយ ព្រោះជាទីរួមនៃរបស់ដែលគួរខ្ពើមទាំងឡាយ ឈ្មោះថាមិនស្អាត ព្រោះពេញដោយរបស់មិនស្អាតមានប្រការផ្សេងៗ ឈ្មោះថាមានក្លិនស្អុយ



ព្រោះក្លិនស្អុយរលួយផ្សាយទៅគ្រប់ពេល ខាងលើចាប់ពីបាតជើងឡើងទៅ ខាងក្រោមចាប់ពីចុងសក់ចុះមក សូមម៉ែពិចារណាដោយញាណចក្ខុ ។ ព្រះថេរីបានស្តាប់នូវគាថាដែលបុត្របានឱ្យឱវាទនោះហើយ សម្រេចព្រះ-អរហត្ត ក៏បានបន្លឺនូវឧទានពោលគាថាទីមួយនោះឯងជាការបូជាអាចារ្យ ។ កាលដែលពោលដល់ការបដិបត្តិរបស់ខ្លួន ទើបពោលគាថាទីពីរថា **ឯទំ វិហារមានាយ** ជាដើម ។

ក្នុងគាថានោះ បទថា **ឯទំ វិហារមានាយ** ដោយសេចក្តីថា កាលដែលយើងតាំងនៅក្នុងឱវាទដែលព្រះ-អភយត្ថេរជាបុត្រឱ្យហើយ ដោយន័យថា **ឧទ្ធំ បាទតលា** ជាដើម ឃើញកាយគ្រប់ផ្នែកថាមិនស្អាត មានចិត្តតាំងមាំកំណត់រូបធម៌ គឺពួកមហាភូតរូបនិងឧបាទាយរូបក្នុងកាយនោះ ព្រមទាំងអរូបធម៌មានវេទនាជាដើមដែលជាប់ទាក់ទងដោយរូបធម៌នោះ លើកឡើងកាន់ត្រៃលក្ខណ៍ពិចារណាដោយអនិច្ចានុបស្សនាញាណជាដើម ក្នុងកាយ

នោះ ។

បទថា **សព្វោ រាគោ សមូហតោ** ដោយសេចក្ដីថា រាគៈទាំងអស់យើងដកឬជីកឡើងហើយដោយអរហត្តមគ្គ តាមលំដាប់នៃមគ្គដែលបន្តដោយមគ្គ ដោយវុដ្ឋានគាមិនីវិបស្សនា ។

បទថា **បរិឡាហោ សមុច្ឆិន្នោ** ដោយសេចក្ដីថា លំដាប់នោះឯង សេចក្ដីក្ដៅក្រហាយគឺកិលេសទាំងអស់យើងកាត់បានដោយប្រពៃហើយ និងព្រោះកាត់សេចក្ដីក្ដៅក្រហាយគឺកិលេសនោះបានហ្នឹងឯង ទើបយើងជាបុគ្គលត្រជាក់ រលត់ដោយសឧបាទិសេសនិព្វានធាតុ ។

**សូមអនុមោទនា !**



# បទគួរយល់ដឹង

ចូរពិសោធមើលខ្លួនឯង ដោយការសាងសេចក្ដីល្អរហូតអស់ជីវិត ដូចពាក្យគេថា ចម្ងាយផ្លូវពិសោធសេះ ពេលវេលាពិសោធមនុស្ស ។

គុណតម្លៃនៃការកើតស្លាប់មួយជាតិ នៅត្រង់ណា បើមិនមែននៅត្រង់ចំណេះដឹងនិងគុណធម៌ទេនោះ ។

ទំនុកបម្រុងរាងកាយប៉ុនណា ក៏ត្រូវចោលក្នុងលោក របស់ជាទីស្រឡាញ់ហួងហែង ស្ងួម្បីបន្តិចបន្តួចក៏មិនបានជាប់តាមទៅស្រុកខ្មោចដែរ បុគ្គលជាទីស្រឡាញ់ស្មើរលេប ក៏មិនចូលក្ដារមឈូសជាមួយនឹងយើងទៀត អ្វីៗនៅស្រុកមនុស្សនេះពេញទៅដោយភាពមាយាឯខ្លឹមពិតប្រាកដគឺគុណធម៌ក្នុងចិត្ត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា កាយនេះមិននៅយូរប៉ុន្មានឡើយ តែវិញ្ញាណទៅប្រាសហើយ នឹងដេកសង្កត់នៅលើផែនដី ដូចអង្កត់អុសរកប្រយោជន៍គ្មានឡើយ ។

តើគួរថៃកាយបណ្ដោយចិត្ត ឬត្រូវប្រើកាយដើម្បីអប់រំចិត្ត ។ មនុស្សល្ងង់បម្រើរូបកាយ ទុករូបកាយជាចៅហ្វាយនាយ ប៉ុន្តែមនុស្សឆ្លាតចិញ្ចឹមរូបកាយ ទុកឱ្យធ្វើជាអ្នកបម្រើ គឺប្រើរូបកាយក្នុងប្រយោជន៍អប់រំចិត្ត ឱ្យចិត្តសម្បូណ៌ទៅដោយចំណេះដឹងនិងគុណធម៌ ព្រោះចិត្តដែលទូន្មានល្អហើយ រមែងនាំមកនូវសេចក្ដីសុខ ។

ត្រូវដាស់តឿនខ្លួនឯងថា ប្រយ័ត្នរស់នៅចោលឥតប្រយោជន៍ គឺត្រូវប្រយ័ត្នគ្រប់ពេល ។

ជីវិតរាល់ថ្ងៃមានធម៌ពិតស្រាប់ហើយ តាមទ្វារទាំង ៦ ស្ដាប់ទៅ រៀនទៅ សិក្សាទៅ រលឹកដឹងទៅ ទើបបានអស់ខ្វល់នឹងខ្លួនឯង ។

## ប្រវត្តិព្រះអភយមាតាថេរី

(កំណាព្យពាក្យ ៨)

ក្រុងឧជ្ជេនីសានជីចេតិយ        គឺជាបុរីនៃព្រះអរហន្ត
កច្ចាយនត្ថេរៈរួសរាន់        ចាកវត្តជេតពននិមន្តចូលស្រុក ។



សម្ដែងព្រះធម៌ថ្វាយព្រះរាជា        ព្រមទាំងមនុស្សម្នាគ្រប់គ្នាបានសុខ
អគ្គមហេសីហឬទ័យស្រណុក        សម្រុកថ្វាយទានមានសីលមានសង្ឃ ។
ស្រីធ្លាប់កាត់សក់លក់ធ្វើចង្ហាន់        និមន្តសង្ឃឆាន់ប្រាំបីព្រះអង្គ
បានជាមហេសីព្រោះស្រីស្មោះត្រង់        សាងវត្តថ្វាយសង្ឃសោយសុខគ្រប់ជាតិ ។
ចណ្ឌបជ្ជោតធម្មរាជា        ស្ដេចមានសទ្ធាធម្មទាយាទ
គ្រងឧជ្ជេនីសំភីខ្ចីឃ្មាត        ថែសង្ឃអាពាធមិនឃ្លាតពីវត្ត ។
បទុមវតីស្រីសោភិនី        បំពេញនាទីតាមកម្មកំណត់
មានបាបមានបុណ្យក្នុងសង្សារវដ្ដ        សត្វលោកប្រាកដប្រព្រឹត្តតាមកម្ម ។
នាងថ្វាយភិក្ខាសម្មាសម្ពុទ្ធ        តិស្សៈវិសុទ្ធព្រះពុទ្ធទ្រង់ផ្ដាំ
ក្នុងអបទានមានន័យគួរចាំ        ព្យាករបុញ្ញកម្មដល់ព្រះនិព្វាន ។
លុះបច្ឆិមជាតិស្រីនាថសោភ័ណ        ទទួលទោសទណ្ឌតាមកម្មដែលមាន
តែកបដោយបុណ្យជាទុននិព្វាន        ទើបនាំឱ្យមានបុត្រព្រះអរហន្ត ។
ចំណែកអភយរាជកុមារ        កើតឋានសុខាកប្បារយពាន់
មួយសែនផែនដីសិរីគ្រប់គ្រាន់        មិនដែលមានភាន់ទៅកាន់អបាយ ។
បុណ្យនមស្ការគាថាបង្គំ        ហត្ថាប្រណម្យផ្គុំដោយចិត្តកាយ
ពោលគុណព្រះពុទ្ធលំអុតថ្វាត់ថ្វាយ        រួចទើបបរិយាយសម្ដែងព្រះធម៌ ។
បុណ្យនេះធំក្រៃប្រពៃគួរគាប់        ទាំងធ្លាប់សាងផ្នូសរស់យ៉ាងបវរ
ជាតិក្រោយបំផុតច្បុតចុះគភ៌        មាតារូបល្អឈាមជ័វរាជា ។

ម៉ែខំថៃថ្នមលៃលាក់អាត្មា ដោយក្ដីមេត្តាបុត្រាស្ងួនភ្ងា
ទាំងតាមបណ្ដាំមគធរាជា រហូតវេលាបុត្រភ្ងាចាកផ្ទៃ ។
បទុមវតីស្រីជាក់ជាម្ដាយ ចិញ្ចឹមរូបកាយបុត្រម្ដាយពូជថ្លៃ
ប្រាំពីរវស្សាកុមារអភ័យ ទើបម្ដាយលកលៃប្រាប់ថ្លៃបិតា ។
បិតានៃបុត្រជាក្សត្រនគរ មគធៈបវរនាមពិម្ពិសារ
ចូរកូនទៅចុះទៅរកបិតា ទម្រង់ក្សត្រាចារនាមព្រះអង្គ ។
ស្រណោះបុត្រថ្លៃមានអីភ្លេចម្ដាយ ប្រាំពីរឆ្នាំប្លាយមានម្ដាយផ្ចិតផ្ចង់
មុខម៉ែស្អាតណាស់ចិត្តម៉ែផូរផង់ ចិត្តកូនស្រយង់រលង់ទឹកភ្នែក ។
រឿងកូនព្រាត់ម៉ែនៅតែស្រណោះ កូននៅតូចសោះអាឡោះពន់ពេក
ឃ្លាតម៉ែទៅឆ្ងាយធ្លាប់ម្ដាយឱ្យដេក ពេលឃ្លានពេលស្រេកមានម៉ែមើលថៃ ។
ចំណែកនៅឯមគធបុរី មានរឿងអប្រិយប្រល័យហួរហែ
ច្រូតកាត់សេចក្ដីអភ័យកូនម៉ែ ស្លុតចិត្តព្រោះតែគេសម្លាប់ឪ ។
ឃើញទោសកិលេសមិនចេះគ្រប់គ្រាន់ ប្រញាប់បន្ទាន់សោយរាជ្យខុសផ្លូវ
កូនសេពគប់ខុសភ្លេចអស់ម៉ែឪ ធ្វើជាសត្រូវនឹងអ្នកមានគុណ ។
ដូច្នោះអភយរាជកុមារ ក្រោយពីបិតារងទុក្ខទារុណ
សោយទិវង្គតស្លុតចិត្តពេកពន់ ប្រញាប់រួសរាន់ចេញសាងព្រះផ្នួស ។
ឧបនិស្ស័យមួយសែនផែនដី ហាក់ដូចថ្មីៗវិស័យធ្លាប់បួស
ជួយឱ្យបានដល់មគ្គផលជាន់ខ្ពស់ កាត់កិលេសអស់រស់ឥតកង្វល់ ។



ពេលអស់កង្វល់នឹកដល់អ្នកម៉ែ យូរយារឆ្នាំខែមិនដែលទៅដល់
វ័យម៉ែចាស់ហើយនៅឡើយកង្វល់ ឱវាទកូនផ្ដល់ម្ដាយយល់ព្រះធម៌ ។
បទុមវតីស្រីចូលកាន់ផ្នួស ម៉ែចាស់ហើយបួសសម្រស់នៅល្អ
កូនលើកអសុភជាទីគោចរ ក្នុងកាយមិនល្អក្លិនស្អុយណាស់ណា ។
ក្នុងព្រះគាថាមានការរៀបរាប់ ពន្យល់គ្រប់សព្វអដ្ឋកថា
ចំពោះជីវិតពិតជាមរណា គួរតែសិក្សាមើលការឱ្យច្បាស់ ។
រង់ចាំឱ្យឃ្លានទើបបានធ្វើស្រែ ពេលស្រេកផងដែរទើបបានធ្វើស្រះ
ដូចពេលមរណាបញ្ហាឃើញច្បាស់ ត្រូវការបុណ្យណាស់ដូចស្រះដូចស្រែ ។
តែទោះយ៉ាងណាធម្មតាលោកិយ រឿងក្នុងភពបីគ្រប់ជាតិហួរហែ
ដូចកលមាយាដូចជាឡប់ឡែ បិទបាំងឱ្យតែរវល់គ្រប់ជាតិ ។
ព្រោះមិនកំណត់ខន្ធប្រាំនេះណា ប្រកាន់អត្តាទុក្ខាមិនឃ្លាត
ចាញ់បោកខ្លួនឯងចំបែងគ្រប់ជាតិ ប្រឹងចិញ្ចឹមធាតុជាតិពស់មានពិស ។
ប៉ុន្តែសំណាងបានសាងកុសល បានស្ដាប់ធម៌យល់បានស្គាល់ធម៌ទិស
ទិសទីដប់មួយមិនព្រួយពស់ពិស បើកទ្វារគន្លឹះទិសដៅនិព្វាន ។
អភយមាតាមហាថេរី បទុមវតីអស់ក្ដីស្រេកឃ្លាន
ស្ដាប់ធម៌ពីរោះនិងព្រោះបុណ្យមាន អស់ក្ដីស្រេកឃ្លាននិព្វានសុខហោង ។

**ប.ស.ទ.**

## ៨. ព្រះអភយាថេរីគាថា

(បិដកលេខ ៥៧, ទំព័រ ១៥១-១៥២)

**អភយេ ភិទុរោ កាយោ យត្ថ សត្តា បុថុជ្ជនា**
**និក្ខិបិស្សាមិមំ ទេហំ សម្បជានា បដិស្សតា ។**
**ពហូហិ ទុក្ខធម្មេហិ អប្បមាទរតាយ មេ**
**តណ្ហក្ខយោ អនុប្បត្តោ កតំ ពុទ្ធស្ស សាសនំ ។**

ម្នាលនាងអភយា ពួកបុថុជ្ជនជាប់ជំពាក់ ក្នុងរាងកាយណា រាងកាយនោះ មានសភាពបែកធ្លាយ អាត្មាអញជាអ្នកដឹងខ្លួន មានស្មារតីតាំងស៊ប់ នឹងដាក់ចុះនូវរាងកាយនេះចោលចេញ ។ អាត្មាអញត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយ ជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ។



## សេចក្តីក្នុងព្រះអដ្ឋកថា

ព្រះអភយាថេរី ក៏បានសាងសន្សំនូវបុញ្ញាធិការទុកមកតាំងតែអំពីព្រះពុទ្ធអង្គមុនៗដែរ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ ។ ក្នុងកាលនៃព្រះដ៏មានព្រះភាគព្រះនាមសិខី[1] ព្រះនាងកើតក្នុងត្រកូលក្សត្រមហាសាល ពេញវ័យហើយ ព្រះនាងបានជាព្រះអគ្គមហេសីនៃព្រះបាទអរុណរាជ ។ ថ្ងៃមួយព្រះបាទអរុណរាជបានប្រទានផ្កាឧប្បលក្រអូប ៧ ភួងដល់ព្រះអគ្គមហេសី ព្រះអគ្គមហេសីទទួលផ្កាឧប្បលទាំងនោះហើយ បានគិតថា យើងប្រដាប់នូវផ្កាទាំងនេះនឹងមានប្រយោជន៍អ្វី បើដូច្នេះ យើងនឹងទុកបូជាដល់ព្រះដ៏មានព្រះភាគវិញ នៅពេលដែលព្រះអង្គទ្រង់យាងមកកាន់ព្រះរាជនិវេសន៍ក្នុងពេលភិក្ខាចារនោះ ។ ព្រះអគ្គមហេសីបានទតឃើញព្រះដ៏មានព្រះភាគហើយ ក៏មានសេចក្តីជ្រះថ្លាទទួលនិងបូជានូវផ្កាទាំងនោះចំពោះព្រះ-

---

១- ព្រះសម្មាសម្ពុទ្ធនៅក្នុង ៣១ ផែនដីមុន ។

អង្គ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ ដោយបុញ្ញកម្មនោះ ព្រះនាងត្រាច់ទៅក្នុងទេវលោកនិងមនុស្សលោក មិនមានទុគ្គតិឡើយ ។ ក្នុងកាលនៃពុទ្ធុប្បាទនេះ ព្រះនាងកើតក្នុងត្រកូលក្រុងឧជ្ជេនី ហើយបានជាសម្លាញ់នឹងនាងបទុមវតីមាតានៃព្រះអភយរាជកុមារ ។ កាលដែលមាតានៃព្រះអភយត្ថេរចេញបួស ព្រះនាងអភយាក៏បានចេញទៅបួសតាម ដោយក្តីស្រឡាញ់ចំពោះព្រះថេរីនៅក្នុងក្រុងរាជគ្រឹះជាមួយនឹងព្រះថេរីនោះឯង ។ ថ្ងៃមួយ ព្រះអភយាថេរីបាននិមន្តទៅកាន់សីតវន័ដើម្បីមើលអសុភ ព្រះបរមសាស្តាទ្រង់ប្រថាប់គង់នៅក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ធ្វើអារម្មណ៍ដែលព្រះអភយាថេរីធ្លាប់ជួបប្រសព្វឱ្យមកប្រាកដចំពោះមុខ ប្រកាសនូវសាកសពដែលហើមប៉ោងជាដើមដល់ព្រះថេរី ។ ព្រះអភយាថេរីឃើញដូច្នោះ ក៏បានឈរមើលទាំងស្លុតចិត្ត ពេលនោះព្រះបរមសាស្តាទ្រង់ផ្សាយនូវព្រះរស្មីសម្តែងព្រះអង្គ ដូចទ្រង់គង់ប្រថាប់ចំពោះមុខ ហើយត្រាស់សម្តែងនូវព្រះ-



គាថា ។ នៅពេលចប់ព្រះគាថា ព្រះអភយាថេរីបានសម្រេចព្រះអរហត្ត ព្រោះហេតុនោះ ទើបព្រះថេរីបានពោលទុកក្នុងអបទានថា

ក្នុងក្រុងអរុណវតី មានក្សត្រមួយព្រះអង្គទ្រង់ព្រះនាមអរុណៈ ខ្ញុំជាអគ្គមហេសីរបស់ស្តេចនោះ បានចាត់ចែងនូវផ្កាដែលមិនទាន់ក្រងទុក ។ ខ្ញុំកាន់យកនូវផ្កាឧប្បល ៧ កម្រងដែលមានក្លិនដូចជាក្លិនទិព្វ អង្គុយលើប្រាសាទដ៏ប្រសើរ គិតយ៉ាងនេះ ក្នុងខណៈនោះថា យើងមានប្រយោជន៍អ្វីដោយកម្រងផ្កានេះ ដែលយើងពាក់លើក្បាលរបស់យើងនោះ បើយើងបូជាចំពោះព្រះញាណនៃព្រះពុទ្ធដ៏ប្រសើរ គឺប្រសើរជាង ។ ជនទាំងឡាយតែងរាប់អាននូវព្រះសម្ពុទ្ធ យើងអង្គុយនៅជិតទ្វារកាលណា ព្រះសម្ពុទ្ធទ្រង់ត្រាស់ហៅថា នាងចូរមក កាលនោះយើងនឹងបូជានូវព្រះមហាមុនី ។

ព្រះជិនស្រីប្រកបដោយភិក្ខុសង្ឃ ស្តេចយាងមកតាមផ្លូវថ្នល់ ទ្រង់ល្វាសល្វន់ដូចជាដើមថ្នាន់ត្រូវខ្យល់ ឬ

ដូចជាកេសររាជសីហ៍ជាស្តេចម្រឹគ ។ ខ្ញុំមានចិត្តរីករាយ លុះឃើញរស្មីនៃព្រះពុទ្ធ ក៏មានចិត្តសង្វេគ មិនទាន់ដល់ទ្វារផងក៏បូជាចំពោះព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំបានធ្វើផ្កាឧប្បល ៧ កម្រង ត្រដាងពួដ៏អាកាស ផ្កាទាំងនោះ ក៏បាំងខាងលើព្រះសីសៈនៃព្រះពុទ្ធអង្គ ។ ខ្ញុំមានចិត្តខ្ពស់ត្រដែតឡើង មានចិត្តរីករាយ មានចិត្តត្រេកអរ ធ្វើអញ្ជលី ហើយញ៉ាំងចិត្តឱ្យជ្រះថ្លាក្នុងព្រះពុទ្ធនោះ ក៏បានទៅកើតក្នុងឋានតាវត្តិង្ស ។ ផ្កាទាំងឡាយបាំងធ្វើជាដំបូលនៃរោងធំខាងលើក្បាលខ្ញុំ ក្លិនជាទិព្វក៏បានផ្សាយទៅ នេះជាផលនៃផ្កាឧប្បល ៧ កម្រង ។ កាលពួកញាតិនាំខ្ញុំទៅ ក្នុងកាលម្តងៗ បរិស័ទរបស់ខ្ញុំមានចំនួនត្រឹមណា ផ្កាទាំងឡាយក៏បាំងជារោង មានចំនួនត្រឹមនោះ ។

ខ្ញុំបានជាមហេសីនៃទេវរាជ ៧០ ដង ខ្ញុំអន្ទោលទៅក្នុងភពតូចភពធំ រមែងបានជាធំក្នុងទីទាំងពួង ។ ខ្ញុំបានជាមហេសីនៃស្តេចចក្រពត្តិ ៦៣ ដង ជនទាំងពួង



តែងប្រព្រឹត្តតាមខ្ញុំ ខ្ញុំមានពាក្យត្រូវអ្នកផងជឿកាន់តាម។ ពណ៌សម្បុរនិងក្លិនរបស់ខ្ញុំតែងផ្សាយទៅ ដូចជាក្លិននៃផ្កាឧប្បល ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

**ឥទ្ធិបាទេសុ កុសលា ពោជ្ឈង្គភាវនារតា**
**អភិញ្ញាបារមិប្បត្តា ពុទ្ធបូជាយិទំ ផលំ** [១] ។

ខ្ញុំជាស្រីឈ្លាសក្នុងឥទ្ធិបាទ ត្រេកអរក្នុងការចម្រើនពោជ្ឈង្គ ដល់នូវអភិញ្ញាបារមី នេះជាផលនៃពុទ្ធបូជា ។

**សតិប្បដ្ឋានកុសលា សមាធិឈានគោចរា**
**សម្មប្បធានមនុយុត្តា ពុទ្ធបូជាយិទំ ផលំ** [២] ។

ខ្ញុំជាស្រីឈ្លាសក្នុងសតិប្បដ្ឋាន មានសមាធិជ្ឈានជាគោចរ ប្រកបរឿយៗនូវសម្មប្បធាន នេះជាផលនៃពុទ្ធបូជា ។

សេចក្តីព្យាយាមរបស់ខ្ញុំ ជាគ្រឿងនាំទៅនូវធុរៈ នាំមកនូវធម៌ដ៏ក្សេមចាកយោគ ខ្ញុំមានអាសវៈអស់ហើយ

---

១- ២- ក្នុងបិដកលេខ ៧៦, ទំព័រ ១៦ ។

ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាផ្កា ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។

កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ។ល។ ព្រះពុទ្ធសាសនា ខ្ញុំបានប្រតិបត្តិហើយ ។

កាលដែលបានសម្រេចព្រះអរហត្តហើយ ព្រះអភយាថេរីបានជូរផ្លាស់នូវព្រះគាថាទាំងនោះឯង ពោលជាឧទានវិញ ។

បណ្តាបទទាំងនោះ ព្រះអភយាថេរីហៅខ្លួនឯងដោយបទថា **អភយេ** ។

បទថា **ភិទុរោ** ប្រែថា មានសភាពបែកធ្លាយ ដោយសេចក្តីថា មិនទៀង ។

បទថា **យត្ថ សត្តា បុថុជ្ជនា** ដោយសេចក្តីថា អន្ធបុថុជ្ជនទាំងនេះ ជាប់ជំពាក់នៅហើយក្នុងកាយណា កាយនោះ មានពេលបែកធ្លាយជាប្រក្រតី ព្រោះសភាវៈមិនស្អាត មានក្លិនស្អុយ គួរខ្ពើម ជារបស់បដិកូល ។



បទថា **និក្ខិបិស្សាមិមំ ទេហំ** ដោយសេចក្តីថា យើងមិនសម្លឹងដោយការប្រកាន់ទៀតទេ យើងនឹងលះបង់ចោលនូវរាងកាយដែលស្អុយរលួយនេះ ។ ក្នុងព្រះគាថានោះ ព្រះថេរីពោលនូវហេតុនៃការលះបង់ ដោយបទថា **សម្បជានា បតិស្សតា**[១] ។

បទថា **ពហូហិ ទុក្ខធម្មេហិ** អធិប្បាយថា សេចក្តីទុក្ខមិនតិចឡើយ មានជាតិនិងជរាជាដើមពាល់ត្រូវហើយ ។

បទថា **អប្បមាទរតាយ** ដោយសេចក្តីថា ត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ ពោលគឺការមិននៅប្រាសចាកសតិ ព្រោះបាននូវសេចក្តីស្លុតចិត្ត ដោយភាពជាអ្នកធ្លាប់ចុះកាន់ទុក្ខនោះៗឯង ។

បទដែលនៅសល់ មានន័យដូចដែលធ្លាប់បានពោលហើយ ។ ក្នុងព្រះគាថានេះ មានបាឋៈដោយទំនងដែលព្រះបរមសាស្តាត្រាស់ថា

១- ក្នុងបាលីបិដក **បដិស្សតា** ។

**និក្ខិបាហិ ឥមំ ទេហំ     អប្បមាទរតាយ តេ**

**តណ្ហក្ខយំ បាបុណាហិ     ករោហិ ពុទ្ធសាសនន្តិ ។**

នាងគប្បីត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូរដាក់ចុះនូវកាយនេះ ចូរដល់នូវការអស់តណ្ហា ចូរបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងព្រះគាថានេះ ព្រះសង្គីតិកាចារ្យលើកឡើងកាន់សង្គាយនា ទៅតាមទំនងដែលព្រះថេរីពោលហើយនោះឯង ។

បទថា **អប្បមាទរតាយ តេ** ដោយសេចក្តីថា នាងគប្បីជាអ្នកត្រេកអរហើយក្នុងសេចក្តីមិនប្រមាទ ។

**សូមអនុមោទនា !**



## បទគួរយល់ដឹង

មានអ្នកណាដែលអត់មានរឿងអ្វីឱ្យទាស់ចិត្តទេ ? នេះគ្រាន់តែជាសំណួរសម្រាប់ឱ្យអប់រំចិត្តដោយបញ្ញានៅពេលដែលជួបប្រទះបញ្ហាផ្សេងៗ ក្នុងជីវិតតែប៉ុណ្ណោះ ។ យើងមិនអាចបានការមិនទាស់ចិត្តអំពីលោកនេះ គ្រប់រឿងទៅនោះទេ គឺមិនអាចបានឯងៗឡើយ ទាល់តែមានការអប់រំចិត្ត ទើបបាននូវការមិនទាស់ចិត្តនោះ ។

យើងត្រូវចាំថា ក្នុងលោកនេះ មិនមានរឿងអ្វីមកតម្រូវឬបង្ខំឱ្យយើងត្រូវតែទាស់ចិត្ត ខឹងក្រោធទៅនោះទេ វាដូចជាដុំភ្លើងអីចឹង មានមកឱ្យរលាកដល់អ្នកមិនចាប់ឯណា អាចយកមកប្រើបានជាប្រយោជន៍ទៀតផង ។

ដូចជា ពាក្យសម្តីមិនល្អនៃអ្នកដែលស្អប់យើងក្តី ច្រណែនក្តីជាដើម តើគួរឱ្យខ្លាចឬ ? គួរឱ្យខឹងឬ ? ពុំនោះសោត មានរឿងខ្លះយើងគិតថា អយុត្តិធម៌ តើ

យើងត្រូវតែកើតទុក្ខឬ ? តាមពិតរឿងទាំងអស់ហ្នឹង សុទ្ធតែជារឿងសម្រាប់ឱ្យយើងរៀនអប់រំចិត្តទេតើ ។

ការទាស់ចិត្ត មនុស្សយើងគេចមិនផុតទេ មានតែព្រះអនាគាមិបុគ្គលឡើងទៅ ទើបបានរួចផុតហើយ ។ រឿងចាស់ រឿងឈឺ រឿងស្លាប់ តើយើងត្រូវទាស់ចិត្តជាមួយនឹងអ្នកណា ? អ្នកណាធ្វើឱ្យ ? មានរឿងច្រើនទៀត ដែលសម្រាប់ឱ្យយើងទាស់ចិត្ត តាំងពីកណ្ដុរ មូសរុយក្នុងផ្ទះជាដើម តើយើងត្រូវតែសម្លាប់សត្វទាំងអស់នោះឬ ? បើយើងមិនខ្លាចបាបទេ យើងអាចសម្លាប់បាន ប៉ុន្តែចំពោះអកុសលវិបាកក្នុងជីវិតវិញ តើយើងរារាំងយ៉ាងម៉េចបាន ?

យើងសម្លាប់កណ្ដុរ មូសអស់ពីផ្ទះ តើយើងពិតជាអស់បញ្ហាឬ ? ក្រិនថ្លើម ភ្លើងឆេះផ្ទះ ប្រព្រឹត្តខុសច្បាប់ ត្រូវអស់លាភយស ជាប់គុក ។ល។ សុទ្ធតែរឿងធំដុំធ្ងន់ធ្ងររាប់មុខមិនអស់ ដូច្នេះកុំធ្វើបាបល្អជាង ។

កើតមកហើយក្នុងភព គេចមិនរួចពីរឿងរ៉ាវ



ផ្សេងៗទេ ។ ត្រូវយកព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធមកធ្វើជាសរណៈ សិក្សាអប់រំចិត្ត ចម្រើនបញ្ញា កំណត់ការពិត ព្រោះមិនមានអ្វីដែលមិនមែនជាការពិតនោះឡើយ។

ចូរហ្វឹកហាត់កម្ចាត់ការទាស់ចិត្តជាមួយនឹងរឿង-រ៉ាវបន្តិចបន្តួច តូចតាច ឥឡូវនេះឯង បើយើងមិនហ្វឹក-ហាត់ទេ តើនឹងត្រូវទប់ទល់ជាមួយនឹងរឿងធំៗបានយ៉ាងដូចម្ដេចទៅ ។

គេស្លាប់អស់ទៅហើយ យើងបាននៅរស់សិនប៉ុណ្ណឹងហើយ គួរតែចេះស្កប់ស្កល់ ។

យើងទាមទារអ្វីបានពីលោកនេះ ឥឡូវនេះ បើថាយើងគ្រាន់បើ កុំឈឺបានទេ ?

សិក្សាឱ្យដឹងការពិតល្អជាង គឺល្អណាស់ ។

ចាស់ឈឺស្លាប់នៅខាងមុខយើង មើលឃើញទេ ដឹងទេ មានត្រៀមទប់ទល់ទេ មានយកធម៌មកពិភាក្សាទេ មានសមថៈទេ មានវិបស្សនាទេ ? ឬម៉ែនិងកូនស្រី ឪនិងកូនប្រុស ប្ដីនិងប្រពន្ធ មិត្តនិងមិត្ត កំពុងឈ្លោះគ្នា ?

ស្នូម្បីតែអ្នកនៅក្នុងវត្តអារាម យ៉ាងម៉េចដែរ ?

ការព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ យើងនឹងមានឱកាសបានជួបពុំខាន ។ សំណាងណាស់ ដែលក្នុងលោកនេះមានការឱ្យទានប្រកបដោយសីល ។

អ្នកដែលយើងស្រឡាញ់ស្ទើរលេបនោះ ឥឡូវនេះយើងមានគិតយ៉ាងម៉េចទេ ដូចជាត្រូវលង់ទឹកស្លាប់ ឬគ្រោះថ្នាក់អ្វីផ្សេងទៀតនោះ ? ឬមួយក៏ខំគិតថា អត់អីទេៗ អីចឹងឬ ? សំណាងណាស់ ដែលក្នុងលោកនេះមានការពិចារណាគិតទុកមុនឱ្យបានរឿយៗ អំពីការព្រាត់ប្រាស ឬមានមរណស្សតិភាវនា ព្រមទាំងមានការធ្វើអំពើល្អដល់គ្នា មេត្តាករុណា កាត់បន្ថយការជាប់ជំពាក់ខ្លាំង ។

បើយើងវេរនូវកឋិនចីវរណាថ្វាយសង្ឃហើយ កឋិនចីវរនោះ គឺឈប់ជារបស់យើងហើយ យ៉ាងណាមិញ បើយើងមានបញ្ញាកំណត់ដឹងរូបធម៌និងនាមធម៌ ឃើញអនិច្ចំ ទុក្ខំ អនត្តាតាមពិតហើយ ក៏ឈ្មោះថា យើង



បានប្រគល់ជីវិតនេះឱ្យចាស់ឈីស្លាប់ហើយដែរ ដូច្នោះ ជីវិតនេះក៏ឈប់ជារបស់យើងរហូតតទៅ ការមិនប្រកាន់ក្នុងនាមនិងរូបគឺអស់ខ្វល់ នេះជាព្រះនិព្វាន ។

រឿងដែលយើងទាស់ចិត្តក្នុងផ្ទះក្ដី ក្រៅផ្ទះក្ដី តាមពិត រឿងទាំងនោះ គ្មានអ្វីធំដុំទេ មកពីយើងមិនបានអប់រំចិត្តទេតើ មានរឿងខ្លះក្រោយមកទៅជាល្អសម្រាប់យើងទៅវិញក៏មានដែរ ។ ក្នុងលោកនេះ មានរឿងទុក្ខលំបាកច្រើនណាស់ តម្រូវឱ្យយើងអប់រំចិត្តខ្លួនឯង មិនមែនសម្រាប់ឱ្យយើងទាមទាររឿងស្រួលៗនោះទេ។ ភ័យក្នុងអនាគតធំដុំណាស់ ដោយសារការនៅប្រកាន់ក្នុងបញ្ចក្ខន្ធហ្នឹងឯង ជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ ផលវិបាកនៃបាបកម្ម អបាយភូមិ វដ្តទុក្ខដ៏សែនវែងឆ្ងាយ ឈឺចាប់ព្រោះកិលេសខ្លួនឯងផ្សំគ្នានឹងកិលេសអ្នកដទៃ ទុក្ខទាំងអស់ ព្រោះមិនទាន់បានដឹងច្បាស់នូវអរិយសច្ចធម៌ដោយបញ្ញាដ៏ប្រពៃ ។

ក្រពើចាប់យើងលេប វាជារឿងតូចតាចទេ វដ្តៈ

លេបយើងបាន ទើបវាជារឿងអាណោចអាធម្ម គួរឱ្យតក់ស្លុតមែនទែន ដូច្នេះ ចូរកុំយកការសប្បាយរីករាយដោយរាគៈ កាមគុណ មកបន្លប់ខ្លួនឯងឱ្យភ្លេចទុក្ខនោះឡើយ ទុក្ខមិនភ្លេចយើងងាយៗទេ ។ កុំច្រឡំថាកិលេសណាមួយជាមិត្តនឹងយើងឱ្យសោះ វាសុទ្ធតែជាសេនាដ៏ស្មោះជាមួយនឹងមច្ចុរាជ ត្រូវឆ្ងាយពីកិលេសដោយការរលឹកដឹងថាជាតួសភាវធម៌មួយបែប មិនមានយើងក្នុងលោក ៦ នេះ ។

កុំមើលងាយកិលេសទាំងឡាយ ហើយក៏កុំថយកម្លាំងចិត្តក្នុងការហ្វឹកហាត់អប់រំសតិប្បដ្ឋានដែរ អត់ធន់សិក្សាសភាវធម៌ជាប្រក្រតី កុំវង្វេងតាមលោភៈ ។

កិលេសនៅមានព្រោះមិនទាន់បានលះ កើតឡើងឃើញច្បាស់ថាជាកិលេស វាយមួយដំបងសតិប្បដ្ឋាន គឺត្រង់ដែលរលឹកដឹង ឃើញថាមិនមែនជាយើង មិនមែនសត្វបុគ្គល គ្រាន់តែជាតួសភាវធម៌សុទ្ធៗប៉ុណ្ណោះ ។

កុំប្រមាទក្នុងកុសលធម៌ទាំងឡាយ ។ បុណ្យតិច-



តួចតួចតាចយ៉ាងម៉េចក៏ដោយ សន្សំទៅ ព្រោះយើងត្រូវការប្រមូលកម្លាំងច្បាំងនឹងកិលេសក្នុងខ្លួន ។

ត្រូវសិក្សាសច្ចៈដែលកំពុងប្រាកដ ដោយមិនមានអាល័យអតីតកាល ។ ត្រូវចាំថា យើងមិនមែនចេះតែនឹងបាននូវអ្វីៗត្រូវចិត្តជានិច្ចនោះឡើយ បើយើងចេះតែស្វែងរកការពេញចិត្តអំពីលោកនេះ ការទាស់ចិត្តនឹងតាមយើងជានិច្ច ដូច្នេះឧបាយមានតែម្យ៉ាងគត់ គឺសិក្សាសច្ចៈដែលបានមកដល់ជីវិតគ្រប់ពេលវេលាហ្នឹងឯង ត្រូវសិក្សារហូតទាល់តែចេះសុខជាមួយនឹងការពិតគ្រប់យ៉ាង ។

## ទ្រាំនិងត្រូវ

(សុភាសិត)

ទ្រាំនឹងសេចក្តីទុក្ខ ត្រូវលះសេចក្តីក្រោធ
ត្រូវប្រយ័ត្នល្ងង់ឆោត ទ្រាំផ្តោតការសិក្សា ។

ច.ស.ទ.

## ៩. ព្រះសាមាថេរីគាថា

(បិដកលេខ ៥៧, ទំព័រ ១៥២)

ចតុក្ខត្តុំ បញ្ចក្ខត្តុំ វិហារា ឧបនិក្ខមឹ
អលទ្ធា ចេតសោ សន្តឹ ចិត្តេ អវសវត្តិនិ ។
តស្សា មេ អដ្ឋមី រត្តិ យតោ តណ្ហា សមូហតា
ពហូហិ ទុក្ខធម្មេហិ អប្បមាទរតាយ មេ
តណ្ហក្ខយោ អនុប្បត្តោ កតំ ពុទ្ធស្ស សាសនំ ។

អាត្មាអញ មិនទាន់បានសេចក្តីស្ងប់រំងាប់នៃចិត្ត មិនលុះក្នុងអំណាចនៃភាវនាចិត្ត បានចេញទៅខាងក្រៅអំពីវិហារ ៤ ដង, ៥ដង ។ អាត្មាអញនោះ ត្រូវទុក្ខធម៌ជាច្រើនពាល់ត្រូវហើយ បានដកតណ្ហាហើយក្នុងរាត្រីទី៨ អាត្មាអញ ជាអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ បានសម្រេចនូវការអស់ទៅនៃតណ្ហា សាសនារបស់ព្រះពុទ្ធ អាត្មាអញបានធ្វើហើយ ។



## សេចក្តីក្នុងព្រះអដ្ឋកថា

ព្រះសាមាថេរី ក៏បានសាងសន្សំនូវបុញ្ញាធិការទុកមកតាំងតែអំពីព្រះពុទ្ធអង្គមុនៗដូចគ្នាដែរ សន្សំកុសលដែលជាឧបនិស្ស័យនៃព្រះនិព្វានទុកក្នុងភពនោះៗ។ ព្រះនាងត្រាច់ទៅក្នុងសុគតិភពទាំងឡាយនោះឯង ក្នុងកាលនៃពុទ្ធុប្បាទនេះ កើតក្នុងត្រកូលគហបតីមហាសាលក្នុងក្រុងកោសម្ពី មាននាមថា សាមា ។ នាងសាមាធំឡើងបានជាមិត្តសម្លាញ់នឹងព្រះនាងសាមាវតី កាលដែលព្រះនាងសាមាវតីត្រូវបាត់បង់ជីវិត ក៏កើតសេចក្តីសង្វេគហើយចូលកាន់ផ្នួស ។ លុះបួសរួចហើយមិនអាចគ្រប់សង្កត់សេចក្តីសោកបាន ចេះតែនឹកដល់មិត្តសម្លាញ់ ភាពសោកសៅមិនបានធូរស្រាលឡើយ ព្រោះហេតុដូច្នេះ ទើបមិនអាចបានសម្រេចនូវអរិយមគ្គ ។

ក្រោយមក ព្រះនាងសាមាបានស្តាប់ឱវាទរបស់ព្រះអានន្ទត្ថេរ ចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត

ព្រមដោយបដិសម្ភិទាទាំងឡាយ ។ កាលបានសម្រេចព្រះអរហត្តហើយ ពិចារណាការបដិបត្តិរបស់ខ្លួន បានពោលគាថាជាឧទាន ប្រកាសនូវការបដិបត្តិនោះ ។

បណ្ដាបទទាំងនោះ បទថា **ចតុក្ខត្តុំ បញ្ចក្ខត្តុំ វិហារា ឧបនិក្ខមឹ** ដោយសេចក្ដីថា យើងអង្គុយមនសិការចម្រើនវិបស្សនាក្នុងវិហារដែលជាទីនៅរបស់យើង មិនអាចធ្វើសមណកិច្ចឱ្យដល់ទីបំផុតទៅបាន ទើបគិតថា វិបស្សនារបស់យើង មិនអាចបន្តឡើងដល់មគ្គទៅបាន ព្រោះមិនមានឧតុជាទីសប្បាយឬហ្ន៎ បានចេញក្រៅវិហារ ៤ ដង ,៥ ដង រួមបានជា ៩ ដង ព្រោះហេតុនោះ ទើបព្រះថេរីពោលថា **អលទ្ធា ចេតសោ សន្តឹ ចិត្តេ អវសវត្តិនិ** ដូច្នេះ ។

បទថា **ចេតសោ សន្តឹ** ក្នុងគាថានេះ ព្រះថេរីពោលសំដៅយក អរិយមគ្គសមាធិ ។

បទថា **ចិត្តេ អវសវត្តិនិ** ដោយសេចក្ដីថា ធ្វើភាវនាចិត្តរបស់យើង ឱ្យប្រព្រឹត្តទៅក្នុងអំណាចមិនបាន



ព្រោះមិនមានសេចក្ដីព្យាយាមឱ្យស្មើជាកណ្ដាល ។ បានស្ដាប់មកថា ព្រះសាមាថេរីនោះ ប្រឹងប្រែងព្យាយាមខ្លាំងហួសពេក ។

បទថា **តស្សា មេ អដ្ឋមី រត្តិ** ដោយសេចក្ដីថា ព្រះថេរីមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ ចម្រើនវិបស្សនាតាំងតែពីបានទទួលឱវាទក្នុងសម្នាក់នៃព្រះអានន្ទត្ថេរមក បានចេញក្រៅវិហារក្នុងមួយយប់ ៤ ដង, ៥ ដង នៅមិនបានសម្រេចគុណវិសេស ដោយមនសិការដែលប្រព្រឹត្តទៅនោះ ទាល់តែក្នុងរាត្រីទី ៨ ទើបបាននូវសេចក្ដីព្យាយាមស្មើល្អ ហើយធ្វើកិលេសទាំងឡាយឱ្យអស់ទៅតាមលំដាប់នៃមគ្គ ព្រោះហេតុនោះ ទើបព្រះថេរីពោលថា **តស្សា មេ អដ្ឋមី រត្តិ យតោ តណ្ហា សមូហតា** ដូច្នោះឯង ។

ពាក្យដែលនៅសល់ មានន័យដូចដែលបានពោលហើយ ។

**សូមអនុមោទនា !**

# បទគួរយល់ដឹង

១. នៅក្នុងព្រះអដ្ឋកថា ព្រហ្មជាលសូត្រ ត្រង់ពុទ្ធកិច្ច ៥ ប្រការ បានចែកពុទ្ធកិច្ចក្នុងបច្ឆិមយាមនៃរាត្រីជាបីចំណែក គឺចំណែកទីមួយ ទ្រង់ស្ដេចយាងចង្ក្រមដើម្បីសម្រួលឥរិយាបថ ។ ក្នុងចំណែកទីពីរ ទ្រង់យាងចូលកាន់ព្រះគន្ធកុដិ ទ្រង់មានព្រះសតិសម្បជញ្ញៈសម្រេចសីហសេយ្យាសន៍ដោយផ្អៀងទៅខាងស្ដាំ ។ ក្នុងចំណែកទីបី មានបាលីថា **តតិយកោដ្ឋាសេ បច្ចុដ្ឋាយ និសីទិត្វា បុរិមពុទ្ធានំ សន្តិកេ ទានសីលាទិវសេន កតាធិការបុគ្គលទស្សនត្ថំ ពុទ្ធចក្ខុនា លោកំ វោលោកេតិ** ប្រែថា ក្នុងចំណែកទីបី (នៃបច្ឆិមយាម) ព្រះអង្គទ្រង់ក្រោកឡើងប្រថាប់គង់អង្គុយ ហើយព្រះអង្គទ្រង់ប្រមើល គឺត្រួតមើលសត្វលោកដោយពុទ្ធចក្ខុ ជាប្រយោជន៍ដើម្បីបានឃើញបុគ្គល ដែលជាអ្នកសាងសន្សំនូវបុញ្ញាធិការទុកមកដោយអំណាចទាននិងសីលជាដើម ក្នុងសម្នាក់នៃព្រះពុទ្ធ



អង្គមុនៗ ។ នេះជាពុទ្ធកិច្ចក្នុងបច្ឆិមយាម ។

២. ក្នុងអដ្ឋកថា អម្ពដ្ឋសូត្រ ទីឃនិកាយ

ក្នុងកាលនោះ ព្រះដ៏មានព្រះភាគទ្រង់ផ្សាយសំណាញ់ព្រះញាណទៅក្នុងម៉ឺនលោកធាតុ ទ្រង់ឃើញពូកសត្វដែលជាអ្នកមានពូជ គួរនឹងត្រាស់ដឹងបាន ។ ព្រាហ្មណ៍ឈ្មោះបោក្ខរសាតិចូលទៅក្នុងសព្វញ្ញុតញ្ញាណ ព្រះដ៏មានព្រះភាគទ្រង់ពិចារណាមើលថា ព្រាហ្មណ៍នេះប្រាកដក្នុងសំណាញ់ញាណរបស់យើង តើគេមានឧបនិស្ស័យដែរទេហ្ន៎ ទ្រង់ទតព្រះនេត្រឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គ ។

៣. ក្នុងព្រះអដ្ឋកថា សុត្តនិបាត កសិភារទ្វាជសូត្រ បានចែកបច្ឆិមយាមនៃរាត្រីជា ៤ ចំណែក ចំណែកទី ១ ទ្រង់អធិដ្ឋានចង្ក្រម ចំណែក ទី ២ ស្ដេចចូលកាន់ព្រះគន្ធកុដិ ទ្រង់មានព្រះសតិសម្បជញ្ញៈសម្រេចសីហសេយ្យាសន៍ដោយផ្អៀងទៅខាងស្ដាំ ចំណែកទី ៣ ទ្រង់ញ៉ាំងពេលឱ្យកន្លងទៅដោយផលសមាបត្តិ ចំណែកទី ៤

ទ្រង់ចូលមហាករុណាសមាបត្តិ ត្រួតមើលសត្វលោក ដោយពុទ្ធចក្ខុ ដែលមានធូលីតិចក្នុងភ្នែក ឬមានធូលីច្រើនក្នុងភ្នែក ។ (ក្នុងអដ្ឋកថាព្រហ្មជាលសូត្រ ទំនងជាគួបផលសមាបត្តិចូលក្នុងចំណែកទី ៤ ទើបសម្តែងតែ ៣ ចំណែក)។

**ឯវមិមស្ស បច្ឆាភត្តកិច្ចស្ស លោកវោលោកន-សង្ខាតេ ចតុត្ថភាគាវសានេ ពុទ្ធធម្មសង្ឃេសុ ទាន-សីលឧបោសថកម្មាទីសុ ច អកតាធិការេ ច កតាធិការេ ច អនុបនិស្សយសម្បន្នេ ច ឧបនិស្សយសម្បន្នេ ច អរហត្តូបនិស្សយសម្បន្នេ ច សត្តេ បស្សិតុំ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ កសិភារទ្វាជំ ព្រាហ្មណំ អរហត្តូ-បនិស្សយសម្បន្នំ ទិស្វា ។**

ក្នុងទីបំផុតនៃចំណែកទី ៤ ពោលគឺការពិចារណាត្រួតមើលលោកនៃបច្ឆាភត្តកិច្ចនេះ យ៉ាងនេះហើយ ទ្រង់ត្រួតមើលសត្វលោកដោយពុទ្ធចក្ខុ ដើម្បីទ្រង់ឃើញសត្វទាំងឡាយដែលនៅមិនទាន់បានធ្វើអធិការ ( គឺមិនទាន់



បានសាងសន្សំនូវបុញ្ញាធិការ ) និងបានធ្វើអធិការ ក្នុងព្រះពុទ្ធជាម្ចាស់ ព្រះធម៌ ព្រះសង្ឃ ក្នុងទាន សីល ឧបោសថកម្មជាដើម ទាំងដែលជាបុគ្គលមិនបានដល់ព្រមដោយឧបនិស្ស័យផង បុគ្គលដល់ព្រមដោយឧបនិស្ស័យផង និង បុគ្គលដែលដល់ព្រមដោយឧបនិស្ស័យនៃព្រះ-អរហត្តផង ។ ទ្រង់ទតឃើញកសិភារទ្វាជព្រាហ្មណ៍ គឺជាអ្នកដល់ព្រមដោយឧបនិស្ស័យនៃព្រះអរហត្ត ។

៤. ក្នុងបិដកលេខ ៨៣, ទំព័រ ២៣៥

**កតមោ ច បុគ្គលោ អភព្វាគមនោ** បុគ្គលជាអភព្វាគមនៈ តើដូចម្តេច ។ (**អភព្វាគមនោ** គឺបុគ្គលដែលមិនគួរដល់ការបានសម្រេចមគ្គផល ) ។

**យេ តេ បុគ្គលា កម្មាវរណេន សមន្នាគតា** បុគ្គលណា ប្រកបដោយគ្រឿងរារាំងគឺកម្ម ។

**កិលេសាវរណេន សមន្នាគតា** ប្រកបដោយគ្រឿងរារាំងគឺកិលេស ។

**វិបាកាវរណេន សមន្នាគតា** ប្រកបដោយគ្រឿង

រារាំងគឺវិបាក ។

**អស្សទ្ធា** ជាអ្នកមិនមានសទ្ធា ។

**អច្ឆន្ទិកា** មិនមានឆន្ទៈ ។

**ទុប្បញ្ញា ជឡា** មានបញ្ញាអាប់អន់ ល្ងង់ខ្លៅ ។

**អភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ** គឺ មិនគួរឈានចុះកាន់សម្មត្តនិយាមក្នុងធម៌ជាកុសលទាំងឡាយ ។

**ឥមេ វុច្ចន្តិ បុគ្គលា អភព្វាគមនា** បុគ្គលទាំងនេះ ហៅថា អភព្វាគមនបុគ្គល ។

**ព្រះអដ្ឋកថា** ពន្យល់សេចក្ដីដូចតទៅ :

វិនិច្ឆ័យក្នុងនិទ្ទេសនៃ **អភព្វាគមនបុគ្គល** បុគ្គលណាមិនគួរដើម្បីនឹងសម្រេចនូវសម្មត្តនិយាម (អរិយមគ្គ) ហេតុនោះ បុគ្គលនោះទើបឈ្មោះថា អភព្វាគមនបុគ្គល។

បទថា **កម្មាវរណេន** ប្រែថា ដោយកម្មដែលជា



គ្រឿងរារាំង បានដល់អនន្តរិយកម្ម ៥ យ៉ាង ។

បទថា **កិលេសាវរណេន** ប្រែថា ដោយកិលេសជាគ្រឿងរារាំង បានដល់ និយតមិច្ឆាទិដ្ឋិ ។

បទថា **វិបាកាវរណេន** ប្រែថា ដោយវិបាកជាគ្រឿងរារាំង បានដល់ បដិសន្ធិដោយអហេតុកៈ និងទុហេតុកចិត្ត ។

បទថា **អស្សទ្ធា** ប្រែថា បុគ្គលមិនមានសទ្ធា បានដល់ បុគ្គលដែលវៀរចាកការជឿក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។

បទថា **អច្ឆន្ទិកា** ប្រែថា បុគ្គលមិនមានឆន្ទៈ បានដល់ បុគ្គលដែលវៀរចាកការពេញចិត្តក្នុងកត្តុកម្យតាកុសល (មិនមានបំណងប្រាថ្នានឹងធ្វើនូវកុសល ) ។ វៀរជនក្នុងជម្ពូទ្វីបចេញហើយ បុគ្គលទាំងនោះដែលនៅក្នុងទ្វីប ៣ ទៀត គឺជាពួកមនុស្សដែលឈ្មោះថា ចូលដល់ ភាពជាបុគ្គលមិនមានឆន្ទៈ ។

បទថា **ទុប្បញ្ញា** ប្រែថា មានបញ្ញាអាប់អន់ បាន

ដល់វៀរចាកភវង្គប្បញ្ញា ។

បទថា **ជឡា** ប្រែថា ល្ងង់ខ្លៅ (អដ្ឋកថាអត់បានពន្យល់ទេ) ។

បទថា **អភព្វា** ប្រែថា បុគ្គលមិនគួរ បានដល់មិនបានឧបនិស្ស័យនៃមគ្គនិងផល ។

បទថា **និយាមំ** បានដល់ មគ្គនិយាម ។

បទថា **ឱក្កមិតុំ** ដោយសេចក្តីថា មិនគួរដើម្បីនឹងឈានចុះ គឺឈានចុះទៅកាន់និយាម ពោលគឺ សម្មត្តៈក្នុងធម៌ទាំងឡាយដែលជាកុសលដើម្បីនឹងតាំងមាំក្នុងមគ្គផលនោះបាន ។ (**ឱក្កមិតុំ** ប្រែថា ឈានចុះ) ។

និទ្ទេសនៃ ភព្វាគមនបុគ្គល បណ្ឌិតគប្បីជ្រាបដោយន័យបដិបក្ខអំពីពាក្យដែលពោលហើយ ។ ព្រះដ៏-មានព្រះភាគទ្រង់ត្រាស់ទុកក្នុងទុកៈនេះ យ៉ាងនេះថា

បុគ្គលណា ធ្វើបញ្ចានន្តរិយកម្ម ១ ជាបុគ្គលនិយតមិច្ឆាទិដ្ឋិ ១ បុគ្គលបដិសន្ធិដោយអហេតុកៈនិងទុហេតុកចិត្ត ១ បុគ្គលមិនជឿព្រះរតនត្រ័យមានព្រះ-



ពុទ្ធរតនៈជាដើម ១ ការពេញចិត្តដើម្បីនឹងធ្វើនូវកុសលនៃបុគ្គលណាមិនមាន ១ បុគ្គលមានភវង្គប្បញ្ញាមិនបរិបូណ៌ ១ ឧបនិស្ស័យមគ្គផលនៃបុគ្គលណាមិនមាន ១ បុគ្គលទាំងនោះ សូម្បីទាំងអស់ជាបុគ្គលមានភព្វវិបរិតមិនគប្បីឈានចុះកាន់សម្មត្តនិយាមធម៌[១] ឡើយ ដូច្នេះឯង ។

៥. ពេលមួយ ព្រះតថាគតស្តេចយាងពីក្រុងសាវត្ថីទៅក្រុងពារាណសី ព្រមដោយភិក្ខុសង្ឃដ៏ច្រើន ។ នៅរវាងផ្លូវ ព្រះអង្គទ្រង់ឈប់នៅជិតទេវស្ថានមួយទ្រង់ព្រះញញឹម ។ ព្រះតថាគតទ្រង់សម្តែងឃដិការសូត្រក្នុងមជ្ឈិមនិកាយ ព្រះអង្គត្រាស់ថា ទីនេះធ្លាប់មានវត្តមួយដែលព្រះសម្មាសម្ពុទ្ធកស្សបទសពលធ្លាប់គង់នៅ ហើយព្រះអង្គក្នុងកាលនោះ ជាជោតិបាលមាណព បួសក្នុងវត្តនោះឯង ចំពោះព្រះភក្ត្រនៃព្រះកស្សបសម្មាសម្ពុទ្ធ ។

---

១- **សម្មត្តនិយតា ធម្មា** = ពួកធម៌មានសភាពត្រូវហើយទៀងបានដល់ លោកុត្តរកុសលចិត្ត ២០ ដួង ចេតសិក ៣៦ ។

មានព្រាហ្មណ៍ម្នាក់ បានមកថ្វាយបង្គំនូវទេវស្ថាន ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកសម្គាល់ទីនេះថាជាអ្វី ? ព្រាហ្មណ៍ទើបក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គថ្វាយបង្គំដោយតាំងចិត្តថា ទីនេះជាចេតិយស្ថានតាមប្រពៃណីរបស់ពួកខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ឱ្យព្រាហ្មណ៍រីករាយសប្បាយចិត្តថា ម្នាលព្រាហ្មណ៍ អ្នកថ្វាយបង្គំស្ថានទីនេះ ជាអំពើល្អហើយ ។

ព្រះដ៏មានព្រះភាគ ទ្រង់និម្មិតនូវព្រះចេតិយមាសរបស់ព្រះកស្សបទសពល កម្ពស់មួយយោជន៍នៅក្នុងអាកាស ទ្រង់សម្ដែងឱ្យមហាជនឃើញហើយត្រាស់ថា ម្នាលព្រាហ្មណ៍ ការបូជានូវបុគ្គលគួរបូជាបែបនេះ រមែងសមគួរជាង ដោយពិត ។ ព្រះអង្គទ្រង់ត្រាស់ព្រះគាថា[១]

**បូជារហេ បូជយតោ ពុទ្ធេ យទិ ច សាវកេ**
**បបញ្ចសមតិក្កន្តេ តិណ្ណសោកបរិទ្ទវេ**

១- បិដកលេខ ៥២, ទំព័រ ៦២ ពីរព្រះគាថាក្រោយគេ ។



**តេ តាទិសេ បូជយតោ និព្វុតេ អកុតោភយេ**
**ន សក្កា បុញ្ញំ សង្ខាតុំ ឥមេត្តមបិ កេនចិ ។**

កាលបុគ្គលបូជា ដល់បូជារហបុគ្គល គឺបុគ្គលដែលគួរបូជា បានដល់ព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធដែលកន្លងផុតបបញ្ចធម៌ (គឺធម៌ធ្វើឱ្យវដ្តៈយឺតយូរ បានដល់តណ្ហា មានះ ទិដ្ឋិ ) ទាំងដែលកន្លងផុតនូវសេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួលបានហើយ ឬ បុគ្គលកាលបូជាដល់បុគ្គលដែលគួរបូជាទាំងនោះ ជាបុគ្គលប្រកបដោយតាទិគុណ[១] មិនមានភ័យអំពីទីណា។ សូម្បីនិព្វានទៅហើយ បុគ្គលណាមួយ មិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណេះ បានឡើយ ។

អដ្ឋកថាពន្យល់សេចក្ដីថា បុណ្យរបស់បុគ្គលដែលជាអ្នកបូជានូវព្រះសម្មាសម្ពុទ្ធជាដើម កាលដែលព្រះអង្គគង់ព្រះជន្មនៅក្ដី និង កាលដែលព្រះអង្គទ្រង់និព្វានទៅហើយ ដោយខន្ធបរិនិព្វានក្ដី អ្នកណា។ ក៏មិនអាចរាប់

១- តាទិគុណ = គុណកន្លងផុតបបញ្ចធម៌និងកន្លងសោកបរិទេវៈ។

បាន ។ សក្កទេវរាជ បានអះអាងក្នុងសេចក្ដីនេះថា ព្រោះសេចក្ដីជ្រះថ្លានៃចិត្តស្មើគ្នា ។

នៅពេលចប់ព្រះធម៌ទេសនា ព្រាហ្មណ៍ដែលបានថ្វាយបង្គំនូវទេវស្ថាននោះ ក៏សម្រេចនូវសោតាបត្តិផល។ ព្រះចេតិយមាសកម្ពស់មួយយោជន៍ បានតាំងនៅក្នុងអាកាសនោះរហូត ៧ ថ្ងៃ ពួកមនុស្សយ៉ាងច្រើនបានបូជាព្រះចេតិយ ដោយប្រការផ្សេងៗ រហូត ៧ ថ្ងៃនោះឯង ។ កាលដែលព្រះចេតិយនិម្មិតនោះបាត់ទៅ ក៏មានព្រះចេតិយសិលាមួយដ៏ធំ បានកើតមានឡើងក្នុងទីនោះ (កន្លែងព្រះអង្គត្រាស់សម្ដែងឃដិការសូត្រ)។ប្រជាសត្វ ៨៤000 បានលុះធម្មាភិសម័យ សម្រេចមគ្គផលក្នុងទីនោះដែរ ។

**សូមអនុមោទនា !**

**(ចប់ព្រះថេរីគាថា ភាគទី ១)**






## ១~ ត្រៀមឡើងយន្តហោះ

ចំណូលចិត្តផ្សងចំណងបាច់ផ្កា     រៀបថ្វាយទេវតារក្សាពាក្យពិត
ទេវតាកំណើតបង្កើតជីវិត     នៅឆ្ងាយឬជិតដិតដោយមេត្តា ។
រលកដួងចិត្តដិតដោយសទ្ធា     ទោះក្ដៅរងាឈឺជាម្ដេចម្ដា
រង់ចាំថ្ងៃខែដែលប៉ងប្រាថ្នា     ធ្វើធម្មយាត្រានាដែនដីព្រះ ។
ថ្ងៃចេញទៅពិតជិតចូលមកដល់     រៀបចំភោគផលតម្កល់ក្នុងផ្ទះ
វ៉ាលិសសោចាក់ទុកដាក់ប្រាក់មាស     ដែលមាន ខ្លះៗ សម្រាប់បូជា ។
ព្រលឹមជិតភ្លឺឮសូរសំឡេង     ការងារផ្សេងៗលើកលែងមួយគ្រា
រៀបចេញដំណើរទៅដើរជុំគ្នា     នៅលើទីធ្លានាវាលយន្តហោះ ។
ទាំងបងប្អូនពិតទាំងមិត្តជិតឆ្ងាយ     ចូលរួមសប្បាយជូនដោយចិត្តស្មោះ
បុណ្យជួយរុញច្រានបានជួបភ្នែកស្រស់     បានឡើងយន្តហោះដូចចិត្តដែលចង់ ។
ធ្លាប់ឃើញសត្វស្លាបហើរឆាបរកស៊ី     ហើរដោយស្លាបពីរជើងរួញក្រញង់
បក្សីស្លាបបួនខ្លួនដែកមានកង់     ងើបក្បាលឆ្ពោះត្រង់តម្រង់វេហា ។
ហោះឡើងខ្យល់បឺតភើតពោះកន្លង     ភ័យផងអរផងចងជាប់ជើងម៉ា
ត្រចៀកឡើងហ៊ឹងតឹងខុសធម្មតា     ខះ ក រកថា យ៉ាងណាពុំត្រូវ ។
ខ្លួនធំជាងផ្ទះអាចហោះឡើងបាន     នាំមនុស្សប៉ុន្មានបានហោះឡើងទៅ
ខ្ពស់ហួសពពកយកមេឃជាផ្លូវ     ក្នុងអាកាសជ្រៅពុំឃើញដីឡើយ ។
រំលងព្រៃធំភ្នំខ្ពស់បំផុត     ទាំងមហាសមុទ្រឆ្លងផុតឃើញត្រើយ
បន្ទាបខ្លួនចុះភើតពោះទៀតហើយ     ដល់ដីទើបស្បើយរហើយចិន្ដា ។

ទីដែលប៉ុនប៉ងបានឆ្លងមកដល់ សន្សំកុសលយល់ហើយជ្រះថ្លា
មកដល់ពុទ្ធស្ថានបានដូចប្រាថ្នា ធ្វើធម្មយាត្រាមកថ្វាយបង្គំ ។
ទេវតាទាំងឡាយសូមជួយរក្សា ក្រុមធម្មយាត្រានៃពួកយើងខ្ញុំ
ឱ្យបានសុខសាន្តហើយបានសន្សំ កុសលបុណ្យធំឧត្តមថ្លៃថ្លា ។
ឧបសគ្គទាំងឡាយចៀសឱ្យឆ្ងាយទៅ កុំមកឆាឆៅក្រុមធម្មយាត្រា
បុណ្យថ្នាក់សីលទានបានជួយរក្សា បរិស័ទគ្រប់គ្នាជ្រះថ្លាកន្លង ។
សូមឧទ្ទិសផលដល់ញាតកា មាតាបិតាគ្រួសារប្អូនបង
សូមសុខសប្បាយកុំឱ្យមានហ្មង សូមបុណ្យចម្លងឆ្លងផុតទុក្ខភ័យ ។

ដោយឧបាសក **គុយ សុធន**

## ២. ធម្មយាត្រានាភ្នំកុក្កុដបាទ

ឡានតូចមួយខ្សែបើកដង្ហែទៅ ឡានធំទុកនៅព្រោះទៅពុំបាន
ដល់ភូមិមួយជ្រៅត្រូវអស់ផ្លូវឡាន ស្តាយបាយឱ្យបានទឹកមានគ្រប់ដៃ ។
ដើរកាត់ផ្លូវដែកបំបែកគ្នាឆ្លង លើកជើងមួយម្តងកន្លងដែករ៉ៃ
ត្បុលក្រោមរថភ្លើងញាប់ជើងញាប់ដៃ សន្សំសំចៃទឹកលៃឱ្យហើយ ។
កណ្តាលថ្ងៃក្តៅដើរទៅឡើងភ្នំ ពុំមានជំរំឈើធំជ្រកឡើយ
ភ្នំកុក្កុដបាទដង្ហោយហៅហើយ ព្ទសូរល្ហើយៗញោមអើយខំឡើង ។
ដង្ហើមតាមមាត់ហត់ខុសធម្មតា ញើសជោកកាយាផ្សាភ្នែកចុកជើង
ឡើងឈរឡើងឈប់ម្លប់ឈើរើុងៗ អ្នកដឹកនាំយើងឡើងចាំការពារ ។



មានទង់សាសនាកម្លាដួងចិត្ត ឡើងមុនក្រោយពិតឆ្ងាយជិតចាំគ្នា
យូរៗ ឮសូរ អនុមោទនា សាធុ តគ្នា ពិតជាជ្រះថ្លា ។
ថ្មធំនៅពាំងរាំងផ្លូវទាំងអស់ ច្រកមួយប្រឡោះចន្លោះថ្មដា
ច្រកដូចជញ្ជាំងពីរផ្ទាំងសិលា ប្រឡោះប៉ុនស្មាស្រវាឡើងទៅ ។
ថ្មភ្នំរហែកបំបែកជាបី ផុសផុតពីដីបីដូចលំនៅ
ព្រះមហាកស្សបៈមុននិព្វានទៅ អធិដ្ឋាននៅកណ្តាលភ្នំបី ។
ឱ្យភ្នំបីក្តោបស្រោបរូបព្រះអង្គ ទាំងចីវរស្បង់សន្ធប់ក្នុងដី
រហូតដល់ព្រះសិអារ្យមេត្រីយ ព្រះពុទ្ធត្រាស់ថ្មីព្រះប្រទានភ្លើង ។
ក្រុមធម្មយាត្រាឡើងដល់លើភ្នំ មកប្រមូលផ្តុំបាយជុំក្រុមយើង
បាយទឹកមានស្រេចមិនបាច់មានភ្លើង បាយហើយពួកយើងបូជាចាប់ផ្តើម ។
សូមថ្វាយបង្គំឧត្តមស្មោះស្ម័គ្រ ព្រះមហាកស្សបៈសាវ័កដ៏ឆ្នើម
ទោះកាយនៅពិត តែឥតដង្ហើម ស្ថិតក្រៀមឬហើមស្ងួតសើមម្តេចម្ដា ។
យើងខ្ញុំពុំអាចឃើញព្រះអង្គឡើយ បានឡើងដល់ហើយគួរឱ្យជ្រះថ្លា
លើភ្នំថ្មពាំងក្រោមផ្ទាំងថ្មដា ស្តាប់ធម៌ទេសនាបូជាចេតិយ ។
សូមលំឱនកាយថ្វាយបង្គំលា ខុសឆ្គងម្តេចម្តាសូមត្រាប្រណី
ក្រែងលោយើងខ្ញុំឡើងលើភ្នំបី លើព្រះអង្គក្តីសូមខមាទោស ។
សូមលាព្រៃភ្នំប្រជុំភ្នំបី សូមសុខសិរីដោយក្តីសន្តោស
ភ្នំកុក្កុដបាទសង្ឃាតផុលផុស សាងផ្លូវឡើងចុះបណ្តុះសទ្ធា ។
សូមសុខសួស្តីសិរីថ្កើងថ្កាន ដល់ញាតិសន្តានឱ្យបានគ្រប់គ្នា

ផលឡើងភ្នំហត់កម្សត់មួយគ្រា    សូមសុខគ្រប់គ្នាលុះគ្រាអវសាន ។

ដោយឧបាសក **គុយ សុធន**

## ៣~ ធម្មយាត្រានាភ្នំគិជ្ឈកូដ

លើកទង់គ្រីចុះពីរថយន្ត    នេត្រាគយគន់បន្ទាន់ឡើងទៅ
លើភ្នំគិជ្ឈកូដរូតរះរកផ្លូវ    ទាន់ពេលឥឡូវមិនសូវមានគ្នា ។
ឥតនៅបង្អង់តម្រង់ជួរចូល    របងបង្គោលដែកមូលព័ទ្ធពារ
ដល់មុខទ្វារកិលបង្វិលដែកទ្វារ    ឡើងជិះតគ្នាដូចជាហ៊ឺហា ។
ក្រឹកក្រាក់ៗ ដាក់មនុស្សទៅដល់    ថ្វាយបង្គំគាល់ដល់ព្រះសាស្ដា
ចេតិយជប៉ុនដឹងគុណសាសនា    សាងដោយថ្មដានៅនាខ្នងភ្នំ ។
បន្តដំណើរដើរដោយថ្មើរជើង    ចុះកាត់ព្រៃស្តើងឡើងទៅជួបជុំ
នៅព្រះគន្ធកុដិបរិសុទ្ធមនោរម្យ    ក្រាបថ្វាយបង្គំសូត្រធម៌នមស្ការ ។
ដើរប្រទក្សិណព្រះគន្ធកុដិ    នៅទីបំផុតស្តាប់ធម៌ទេសនា
កុដិព្រះអានន្ទជិតព្រះសាស្ដា    សល់តែថ្មដានៅទីបំផុត ។
ចុះមកគឺល្អាងសូករខាតា    ល្អាងផ្ទាំងសិលាព្រះសារីបុត្ត
ទ្រង់គង់នៅបានជាឋានបរិសុទ្ធ    បញ្ញាមោះមុតជាទីជ្រះថ្លា ។
គុហាថ្មដាព្រះមហាមោគ្គល្លាន    ឫទ្ធិព្រះអង្គមានឈានដ៏អស្ចារ្យ
ឯទេវទត្តក្បត់ព្រះសាស្ដា    គាស់ដុំសិលាប្រាថ្នាឱ្យពារ ។



ប៉ងធ្វើគុតព្រះគាស់ថ្មធ្លាក់លើ    ព្រោះចង់ឡើងធ្វើជាព្រះភគវា
កម្ទេចខ្ទាតទៅត្រូវព្រះបាទា    ក៏នៅជិតគ្នាគុហានោះដែរ ។
ជិតល្អាងថ្មដាព្រះមហាមោគ្គល្លាន    បន្តិចមកមានស្ពានឈើនៅក្បែរ
ជ្រោះទម្លាក់ចោរនៅទីនោះដែរ    មានរឿងហូរហែដែលគួរសង្វេគ ។
បុណ្យជួយរុញច្រានឱ្យបានមកដល់    បានដឹងបានស្គាល់ឃើញផ្ទាល់នឹងភ្នែក
គួរឱ្យអស្ចារ្យជ្រះថ្លាពន់ពេក    សូមមារកុំជ្រែកបំបែកបុណ្យនេះ ។

ដោយឧបាសក **គុយ សុធន**

## ៤~ ធម្មយាត្រាទស្សនាស្ទឹងអចិរវតី

ក្រុមធម្មយាត្រាជ្រះថ្លាសាធ្វី    ដល់ក្រុងសាវត្ថីហឫទ័យសប្បាយ
ប៉ងប្រាថ្នាទៅទោះនៅជិតឆ្ងាយ    ពុទ្ធស្ថានទាំងឡាយក្លាយជាមនោរម្យ ។
ព្រះសង្ឃចាត់ចែងកន្លែងត្រូវទៅ    ឡានតូចនាំផ្លូវទៅតាមផ្លូវលំ
វាំងគេចផ្លូវខូចដូចរន្ធបាយខុំ    រថយន្តធំៗ ពុំអាចទៅបាន ។
ស្ទឹងមានជម្រៅរាក់ជ្រៅយ៉ាងណា    ធ្លាប់ស្ដាប់ទេសនាសាស្ត្រាធ្លាប់អាន
ចង់ទៅមើលស្ទឹងត្រូវពឹងកូនឡាន    ប្រវត្តិស្ទឹងបាននិទានមកថា ។
នាងបដាចារកូនមហាសេដ្ឋី    រត់តាមស្វាមីដោយក្តីស្នេហា
ចាកចេញចោលញាតិមាតាបិតា    ពូជពង្សាវតារអ្នកក្រុងសាវត្ថី ។
នាងមានប្រវត្តិកម្សត់អស្ចារ្យ    បែកក្រុមគ្រួសារហើយស្លាប់ស្វាមី
កូនស្លាប់នៅស្ទឹងអចិរវតី    កូនបងលង់ក្ស័យកូនខ្ចីសត្វខ្វាំ ។

គួរឱ្យស្រណោះរស់ជាតិជាស្រី ស្លាប់កូនស្លាប់ប្ដីស្មារតីនៅចាំ
ប្ដីស្លាប់ក្នុងព្រៃរាត្រីពស់ខាំ កូនពីរជួបកម្មស្លាប់ពេលតែមួយ ។
គួរឱ្យអាណោចអាណិតនាងណាស់ ប្រាថ្នាទៅផ្ទះក្រែងមានញាតិជួយ
តែបែរទៅជាត្រូវថែមទុក្ខព្រួយ ម៉ែឪបងមួយស្លាប់យ៉ាងខ្លោចផ្សា ។
ព្យុះភ្លៀងបោកបាចកាចឥតប្រណី ក្នុងពេលរាត្រីប្រល័យសង្ខារ
បាក់ផ្ទះកម្សត់សង្កត់មរណា បងប្រុសមាតាបិតាជុំគ្នា ។
ដំណឹងចុងក្រោយនាំឱ្យចិត្តស្រី វង្វេងស្មារតីស្រីឆ្កួតលីលា
របូតអស់គ្រឿងបិទបាំងនានា ក្មេងៗ នាំគ្នាគប់នាងនឹងដី ។
តែបុណ្យមិនខ្សត់កំណត់ដំណើរ នាំជើងនាងដើរឆ្ពោះក្រុងសាវត្ថី
ដល់វត្តជេតពនជួបព្រះជិនស្រី ប្រោសឱ្យស្មារតីស្រីមានឡើងវិញ ។
មានរឿងចត់ជូរវិឌូឌភៈ ខឹងពួកសក្យៈ ចាំជាក់ម្នោម្នេញ
សម្លាប់សក្យៈ ហើយត្រឡប់វិញ ដេកពេញមាត់ស្ទឹងក្នុងពេលរាត្រី ។
ស្រមោចបែងចែកបំបែកទីតាំង បាបតិចបាបខ្លាំងស្ទឹងតាំងកាត់ក្ដី
ទឹកកួចចូលស្ទឹងអចិរវតី អ្នកចិត្តអប្រិយក្ស័យក្នុងគង្គា ។
ឥឡូវពេលនេះក្រុមធម្មយាត្រា បានមកទស្សនាស្ទឹងនោះគ្រប់គ្នា
ស្ទឹងមានប្រវត្តិកត់រឿងនានា កាលព្រះភគវាគង់ធម្មានៅ ។
ទស្សនាដងស្ទឹងអចិរវតី ឆ្លងស្ពានឫស្សីក្រាលចំបើងទៅ
ស្ទឹងឈ្មោះដដែលនៅដល់ឥឡូវ បរិស័ទតែងទៅនឹករឿងបដាចារ ។

ដោយឧបាសក **គុយ សុធន**



## ៥. ធម្មយាត្រាទទួលព្រះសារីរិកធាតុ

ពន្លឺរស្មីនៃដួងសុរិយា រះឡើងកាលណាភ្លឺអស្ចារ្យក្រៃ
រហូតបានងារថាជាពេលថ្ងៃ ពេលអស់រស្មីឱ្យន័យថាយប់ ។
សុរិយាពិតណាស់ភ្លឺច្បាស់ពេកក្រៃ តែបានត្រឹមថ្ងៃដល់ជិតព្រលប់
ព្រះធម៌ថ្លៃថ្លាបញ្ញាមានគ្រប់ ដោះស្រាយថ្ងៃយប់ឆ្លងភពជាយាន ។
ព្រះពុទ្ធជាម្ចាស់ត្រាស់ក្នុងលោកា អង្គព្រះសាស្ដាទេសនាទូន្មាន
ព្រះធម៌ផ្ទួរផង់ព្រះអង្គប្រទាន ព្រះសង្ឃកើតមានប្រធានសាសនា ។
បរិស័ទទាំងឡាយសប្បាយបូជា អ្នកមានសទ្ធាបើកទ្វារបញ្ញា
ជួបព្រះអង្គពិតកើតចិត្តជ្រះថ្លា ស្ដាប់ធម៌ទេសនាសម្រេចមគ្គផល ។
យើងខ្ញុំទាំងឡាយសប្បាយកន្លង បានជិះហោះឆ្លងរំលងមកដល់
ធ្វើធម្មយាត្រាប្រាថ្នាកុសល ចង់ជួបចង់ស្គាល់ចង់គាល់ព្រះអង្គ ។
ចំណង់តតន័យចង់អ្វីដែលអត់ ចង់ហួសកំណត់ហាត់ព្រោះចំណង់
ធ្វើម្ដេចជួបជាក់ព្រះភក្ត្រព្រះអង្គ ត្បិតព្រះពុទ្ធទ្រង់និព្វានយូរហើយ ។
តែទោះយ៉ាងណាចាត់ថាសំណាង ព្រោះបានភស្ដុតាងអាងសម្រាប់ឆ្លើយ
ថាព្រះពុទ្ធមាននិព្វានមែនហើយ ព្រះធាតុនៅឡើយរហូតឥឡូវ ។
ព្រះធាតុព្រះអង្គព្រះសង្ឃប្រទាន ព្រះអង្គនិព្វានមានព្រះធាតុនៅ
អារាធនាទ្រង់ព្រះអង្គយាងទៅ ជាមួយកូនចៅទៅកម្ពុជា ។
ព្រលឹមឡើងរះដួងព្រះសុរិយា ក្រុមធម្មយាត្រាសន្យាវេលា
តុបតែងរាងកាយស្រស់ស្រាយគ្រប់គ្នា កាន់ភួងមាលាចាំបូជាថ្វាយ ។

មនោរម្យជុំជាតិព្រះធាតុយាងដល់ បានជួបឃើញផ្ទាល់រីករាយសប្បាយ
បានបូជាផងមើលផងឥតណាយ ទោះនៅជិតឆ្ងាយរៀងរាយជួរគ្នា ។
បូជាបានស្រេចសម្រេចបំណង ដង្ហែចម្លងរំលងគង្គា
មហាសមុទ្ទធំធេងមហិមា មកកម្ពុជានាពេលឥឡូវ ។
ព្រះមហាគន្ធកុដិបន្សុទ្ធសទ្ធា សាងអារាធនាយាងព្រះធាតុទៅ
គោរពបូជាតម្កល់ទុកនៅ ទុកឱ្យកូនចៅ នៅជិតសាស្តា ។
យើងខ្ញុំគ្រប់ប្រាណដែលបានរៀបចំ បុណ្យដ៏ឧត្តមនៃធម្មយាត្រា
សូមជូនបុណ្យញាតិជូនជាតិខេមរា អ្នកដែលជ្រះថ្លាប្រាថ្នាសុខសាន្ត ។
ព្រះធាតុយាងដល់តម្កល់បុស្បុក សូមឱ្យបានសុខកុំរឱិស្ធាន
ត្រជាក់ត្រជុំឧត្តមថ្កើងថ្កាន ចម្រើនមានបានសុខសាន្តតទៅ ។

ដោយឧបាសក **គុយ សុធន**

## ៦. ធម្មយាត្រានាភ្នំសុមនកូដ

សុមនកូដាមហាគីរី ភ្នំខ្ពស់ទីពីរនៅស្រីលង្កា
ទោះបីភ្នំខ្ពស់ជ្រោះជ្រៅយ៉ាងណា ប្រាថ្នាទៅតាមរកស្នាមព្រះអង្គ ។
មេឃមីរស្រទំភ្នំបាំងសុរិយា ផ្លូវស្រៀវអស្ចារ្យមាគ៌ាខ្សៀនខ្ចង់
វិលឡើងវិលចុះខុសពីផ្លូវត្រង់ ពេលឡានវិលកង់ចង់ក្អួតចង់ភ័យ ។
ចម្ការតូចធំលើភ្នំទាបខ្ពស់ គយគន់សម្រស់ទេសភាពព្រឹក្សព្រៃ
ឮតែសំឡេងបក្សាបក្សី ផ្ទះសំណាក់ថ្មីចំណីទេសចរ ។



មើលចម្ការតែហូរហែតាមភ្នំ ទឹកជ្រោះតូចធំរណ្ដំនឹងថ្ម
តាមចង្កេះភ្នំផ្លូវលំបន្ត ផ្កាឈើគ្រប់ពណ៌លម្អធម្មជាតិ ។
រំលងច្រើនជ្រោះឡើងចុះច្រើនភ្នំ បានឈប់ជួបជុំម្ដុំផ្សារជុំញាតិ
មានលក់ទំនិញចុះទិញព្រោងព្រាត សម្ពាយហួសមាឌឆ្អៀតជួលគេសែង ។
ឡើងតាមដំណើរថ្មើរជើងរហូត ភ្នំសុមនកូដខ្ពស់គួរស្ញប់ស្ញែង
ដល់ចង្កេះភ្នំពពកបែកផ្សេង មានគេមានឯងចម្រុះជាតិសាសន៍ ។
ប្រឹងឡើងអស់ជើងយើងយកដៃជួយ ថែមឈើច្រត់មួយជួយដោលបានខ្លះ
ជួលអ្នកជួយចាប់សម្រាប់ប្ដូរផ្លាស់ ជួយដល់ចាស់ៗខ្លះសែងខ្លះគ្រាហ៏ ។
ហត់ហេវខ្សេវខ្សោះអស់កម្លាំងកាយ តែចិត្តសប្បាយព្រមដោយសទ្ធា
ដើរជែងឡើងចាំចំណាំមើលគ្នា ក្រែងមានឈឺជាជួយគ្រាហ៏គ្នាទៅ ។
ដល់ថ្វាយបង្គំស្នាមព្រះបាទា នៃព្រះភគវានាពេលយប់ជ្រៅ
ត្រជាក់យ៉ាងណាជ្រះថ្លានឹងនៅ តើអាចបានទៅក្រោយទៀតដែរឬ ។
ភ្នំសុមនកូដរហូតសព្វថ្ងៃ បរិស័ទច្រើនក្រៃឡើងចុះទល់ភ្លឺ
ខ្លះឡើងពេលយប់សូត្រធម៌ ឮៗ បង្គំជិតភ្លឺហើយមើលថ្ងៃរះ ។
សម្រាកលើភ្នំជុំគ្នាទាំងអស់ គ្មានសល់ចន្លោះជ្រៀតគ្នាពេញពាស
យប់ត្រជាក់ខ្លាំងស្ទើរគាំងចង់ស្ទះ មុនពេលថ្ងៃរះថ្វាយព្រះម្ដងទៀត ។
ពុទ្ធបរិស័ទយើងព្រឹកឡើងចុះវិញ ដួងចិត្តទន្ទេញយកបុណ្យជូនញាតិ
ចុះមកក្រុមយើងរឹងជើងថែមទៀត ដំណើរត្បិតត្បៀតអស់ពីរបីថ្ងៃ ។
តែទោះយ៉ាងណាជ្រះថ្លាជានិច្ច ចងចាំឥតភ្លេចធ្មេចភ្នែកស្រមៃ

ឃើញស្រមោលភ្នំផ្ដុំល្អពេកក្រៃ ជះជាប់លើផ្ទៃពពកសែនស្អាត ។

លាសិនហើយអ្នកសុមនកូដា លាទាំងទេវតាសេនាអាមាត្យ

សូមថ្វាយបង្គំលាស្នាមព្រះបាទ ក្នុងកូនប្រាសាទប្រតិស្ឋាននៅ ។

លាតំបន់ភ្នំតូចធំវិលវិញ រថយន្តទន្ទេញទន្ទឹងមើលផ្លូវ

លាចម្ការតែលាទាំងជ្រោះជ្រៅ លាយកបុណ្យទៅនៅក្រុងវិញហើយ ។

ដោយឧបាសក **គុយ សុធន**

## ៧. ធម្មយាត្រាត្រឡប់វិញ

ខ្យល់បក់រំភើយរហើយកាយា នាំចិត្តជ្រះថ្លាប្រាថ្នាបូជា

ខែក្ដៅខ្យល់បក់ពីទិសនានា ដល់ខែរងាខ្យល់បក់ពីជើង ។

គ្មានអ្វីប្រសើរស្មើមានបញ្ញា ទ្រព្យក្នុងលោកាគេលើកតម្កើង

តែត្រូវវិនាសដោយទឹកនិងភ្លើង ភ្ញាក់រលឹកឡើងពុទ្ធបរិស័ទអើយ ។

កន្លងថ្ងៃយប់គោរពបូជា ដល់ពេលវេលាត្រឡប់វិញហើយ

លង្កាតណ្ហាជិតគ្នាបង្កើយ សូមលាសិនហើយទៅកម្ពុជា ។

ព្រៃភ្នំខៀវស្រស់សម្រស់លង្កា ជាកោះយក្សាកណ្ដាលគង្គា

ព្រះអង្គធ្លាប់ប្រោសនាគក្ខួយនាគមា ចាំរឿងតគ្នាទល់គ្រាឥឡូវ ។

អស់យក្សយូរទៅនៅតែមនុស្សា យាងព្រះទន្តធ្លាចង្អុមកែវទៅ

គោរពរក្សាសាសនាគង់នៅ បរិស័ទតែងទៅគោរពបូជា ។

ឥណ្ឌាលង្កាយាត្រាតែម្ដង ធម្មយាត្រាឆ្លងនេប៉ាល់រួមគ្នា



ទោះយប់ងងឹតឬក្ដៅរងា ដោយមានសទ្ធាពុះពារទៅបាន ។

ក្នុងចិត្តរំភើបទើបតែមកដល់ បានជួបឃើញផ្ទាល់ហួសពីការស្មាន

អស់យក្សលង្កាសាសនាថ្កើងថ្កាន លង្កាមានដានស្នាមព្រះបាទា ។

ឥណ្ឌាដីធំប្រជុំច្រើនរដ្ឋ មានពុទ្ធប្រវត្តិពុទ្ធស្ថាននានា

នេប៉ាល់ប្រសូតអង្គព្រះភគវា សល់គោលថ្មជាភស្តុតាងនៅឡើយ ។

បរិស័ទទាំងឡាយរីករាយជ្រះថ្លា ធ្វើធម្មយាត្រាចប់ការងារហើយ

កប់ទុកក្នុងចិត្តពិតឥតបាត់ឡើយ តម្រង់រកត្រើយកុំឱ្យម្នោម្នេញ ។

អាកាសយានដ្ឋានបានរង់ចាំហើយ ជាថ្ងៃចុងក្រោយត្រូវត្រឡប់វិញ

លាទាំងពុទ្ធស្ថានដែលបានបំពេញ ទន្ទេញជាប់នៅទៅតាមផ្លូវធម៌ ។

ឱមាតុភូមិអើយទៅហើយនឹកណាស់ ធ្លាប់នៅដឹងច្បាស់ក្មេងចាស់គាំទ្រ

ភ្នំពេញវិលវិញវាលអាកាសចរណ៍ រួចទើបបន្តទៅលំនៅស្ថាន ។

ដួងចិត្តជិតជាប់គ្រប់សព្វនៅឡើយ សូមលាសិនហើយណាមិត្តកល្យាណ

ធ្លាប់រស់ជុំជាតិដូចញាតិសន្ដាន ថ្ងៃក្រោយគង់បានរាប់អានជាគ្នា ។

សូមបុណ្យកុសលផលដែលយើងបាន ធ្វើទាំងប៉ុន្មានទាំងបានបូជា

ជួយយើងខ្ញុំទៀតជួយញាតិគ្រប់គ្នា ឱ្យបានសុខជាលុះគ្រាអវសាន ។

សូមបុណ្យដែលខំធ្វើធម្មយាត្រា ជួយកាប់ជួយឆ្ការបន្លាឱ្យបាន

ឆ្ពោះតម្រង់ផ្លូវទៅត្រើយនិព្វាន ជួបតែសុខសាន្តរៀងរហូតទៅ ។

ដោយឧបាសក **គុយ សុធន**

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការងារធម្មទាន

| | |
|---|---|
| ១. លោកគ្រូ រស់ សូផាត | ២. ឧបាសក យន្ត សួន |
| ៣. ឧបាសក គួង លាងផេង | ៤. ឧបាសក មួង យេន |
| ៥. ឧបាសក សោម រតនៈ | ៦. ឧបាសក អ៊ិត ប្រាំង |
| ៧. ឧបាសិកា ជា សុណារី | ៨. ឧបាសិកា ប៊ុត ម៉ាលី |
| ៩. ឧបាសក គុយ សុធន | ១០. ឧបាសក វ៉ាន់ ខុនណា |
| ១១. ឧបាសក ជឹម ជំនិត | ១២. ឧបាសក ជឹង វ៉េងអ៊ាវ |
| ១៣. ឧបាសក ង៉ូវ គា | ១៤. ឧបាសក ហាយ ចំរើន |
| ១៥. ឧបាសក ច័ន្ទ សុខុម | ១៦. ឧបាសក ទូច គីមស្រ៊ាង |
| ១៧. ឧបាសក ម៉ៅ ម៉ន | ១៨. ឧបាសក ម៉ៅ ផុន |
| ១៩. ឧបាសិកា ហួនចាន់បូជា | ២០. ឧបាសិកា ហាយច័ន្ទធីរី |
| ២១. ឧបាសក អ៊ឹម វ៉ៃយ៉ា | ២២. ឧបាសក ហាន សីហៈ |



## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១- លោក កេត សេរីភ័ត្រ និង អ្នកស្រី ប៉ុល ហត្ថា +បុត្រ ..... ស.រ.អ.
២- ឧ.សិ.កេតុ ថូរ និង ឧ.សិ.ស្វាយ សិត ព្រមទាំងបុត្រធីតា ... ស.រ.អ.
៣- ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ ព្រមទាំងបុត្រ+ចៅ ស.រ.អ.
៤- ឧ.សិ.គុជ ឡាំងអេង និង អ្នកស្រី សេង យុវផា + កូនចៅ .. ស.រ.អ.
៥- ឧ.ស.គៀង សេរីគង់ និង ឧ.សិ.តាន់ វ៉ានី ព្រមទាំងកូនចៅ . ស.រ.អ.
៦- ឧ.សិ.ង៉ែត លេន ព្រមទាំងបុត្រ និងចៅ ...................... ស.រ.អ.
៧- លោក ចាន់ ម៉ល់ និង អ្នកស្រី ជា សុផា ព្រមទាំងបុត្រ...... ស.រ.អ.
៨- ឧ.សិ.ចាន់ នារីសុខ និងក្រុមគ្រួសារ .......................... ស.រ.អ.
៩- ឧ.សិ.ឆាន់ ហៃគីង ព្រមទាំងបុត្រ និង ចៅ .................... ស.រ.អ.
១០- ឧ.ស.ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គីមសែ + បុត្រ ........ ស.រ.អ.
១១- ឧ.ស.ជា ស៊ុវត្ថានា និង ឧ.សិ.ឃុន សូនីម៉ា ព្រមទាំងបុត្រ .. ស.រ.អ.
១២- ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ +ចៅ ..... ស.រ.អ.
១៣- ឧ.សិ.ជុំ ឆដា ( ហៅ លាភ )....................................... ស.រ.អ.
១៤- ឧ.សិ.ឈ គីមហោ ព្រមទាំងបុត្រ និងចៅ .................... ស.រ.អ.
១៥- ឧ.ស.ឈូ គីមសួ និង ឧ.សិ.ឡឿ សុភា ព្រមទាំងបុត្រ ........ ស.រ.អ.
១៦- ឧ.ស.ឈួន ផារិន និង ឧ.សិ.ព្រំ ប្រណីត ...................... ស.រ.អ.
១៧- ភិក្ខុ ឈួម បូ ( វត្តពន្លឺពុទ្ធចក្រ លោវែល ) .................... ស.រ.អ.

១៨- ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ ............. ស.រ.អ.

១៩- ឧ.ស.តាន់ តារាវង្ស និង ឧ.សិ.ជួប វុឌ្ឍី ព្រមទាំងកូនចៅ ... ស.រ.អ.

២០- ឧ.សិ.តូច ចានយ៉ា .................................................... ស.រ.អ.

២១- ឧ.សិ.តាំង លេខគៀវ ( ហៅ តាំងហ៊ាង ) ព្រមទាំងកូនចៅ . ស.រ.អ.

២២- ឧ.ស.តែ ប៊ុនគង់ និង ឧ.សិ.ថោង បូនី ព្រមទាំងបុត្រ+ចៅ ស.រ.អ.

២៣- ឧ.សិ.តែ សាយជូ ព្រមទាំងបុត្រ និងចៅ ...................... ស.រ.អ.

២៤- ឧ.សិ.ទីន ឈីវ ព្រមទាំងបុត្រ និងចៅ ......................... ស.រ.អ.

២៥- ឧ.សិ.ទូច ផានី និង ស្វាមី Leslie Mael ព្រមទាំងបុត្រ . ស.រ.អ.

២៦- ឧ.សិ.នួន ប៊ិច និង ឧ.សិ.រស់ សុផល ព្រមទាំងបុត្រ+ចៅ... ស.រ.អ.

២៧- ឧ.ស.ប៊ន់ ហោម៉េង និង ឧ.សិ.ប៊ន់ ស៊ុនអាន+កូនចៅ ...... ស.រ.អ.

២៨- ឧ.សិ.ប៉ាន់ ពិណ្ណារី និង ស្វាមី ព្រមទាំងបុត្រ និងចៅ ........ ស.រ.អ.

២៩- ឧ.សិ.ប៊ិត ថងខាំ និង ឧ.សិ.សាន ផល្លីនព្រមទាំងបុត្រ+ចៅ. ស.រ.អ.

៣០- ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹង វិទ្ធារី ព្រមទាំងបុត្រ ...... ស.រ.អ.

៣១- លោកយាយ ពិន សាត ព្រមទាំងបុត្រ និងចៅ............... ស.រ.អ.

៣២- ឧ.ស.ពឹង សេងគី និង ឧ.សិ.អ៊ឹង ធឿម ព្រមទាំងបុត្រ+ចៅ ស.រ.អ.

៣៣- លោក ពេជ្រ សីហា និង អ្នកស្រី ថាប់ សុរត្ន័ ................ ស.រ.អ.

៣៤- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងកូនចៅ ...... ស.រ.អ.

៣៥- ឧ.ស.ម៉ៃ គួលអេង និង ឧ.សិ.រស់ កល្យាណ ................... ស.រ.អ.

៣៦- ឧ.ស.យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម + បុត្រ .......... ស.រ.អ.

៣៧- ឧ.សិ.រស់ លីណា និង ឧ.សិ.នឹម វណ្ណី ព្រមទាំងកូនចៅ .... ស.រ.អ.

៣៨- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ ............................................. ស.រ.អ.



៣៩- ឧ.សិ.លឹម ស៊ាងអ៊ិម និង ឧ.សិ.អេង គីមតិច ................. ស.រ.អ.

៤០- ឧ.ស.វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ+ចៅ . ស.រ.អ.

៤១- ឧ.ស.វ៉ាង សារ៉ុថ និង ឧ.សិ.គង់ ស៊ីណាត ព្រមទាំងបុត្រ .. ស.រ.អ.

៤២- ឧ.សិ.ស៊ីវ យក់លុយ ព្រមទាំងបុត្រ និងចៅ .................. ស.រ.អ.

៤៣- ឧ.សិ.សុខ យ៉ាន .................................................... ស.រ.អ.

៤៤- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ព្រមទាំងបុត្រ .......... ស.រ.អ.

៤៥- ឧ.ស.ស៊ូ ហុកឡុង និង ឧ.សិ.តាន់ ឈីវហា ព្រមទាំងបុត្រ. ស.រ.អ.

៤៦- ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ... ស.រ.អ.

៤៧- ឧ.ស.សំណាង យឹម និង ឧ.សិ.ឡូរ៉ា យឹម ព្រមទាំងបុត្រ ... ស.រ.អ.

៤៨- ឧ.សិ.ស្រង់ អៃ និង ឧ.សិ.ស្រង់ ឡេង ព្រមទាំងបុត្រ+ចៅ ស.រ.អ.

៤៩- ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា ព្រមទាំងបុត្រ ស.រ.អ.

៥០- ឧ.សិ.ហេង លាភ ព្រមទាំងបុត្រ និង ចៅ ...................... ស.រ.អ.

៥១- ឧ.ស.ហោ លាន និង ភរិយា ...................................... ស.រ.អ.

៥២- ឧ.សិ.ហ្វាន់ នី និង ស្វាមី ព្រមទាំងបុត្រ ......................... ស.រ.អ.

៥៣- ឧ.ស.ឡឹម ក្រហម និង ឧ.សិ.តាំង ធីយន ព្រមទាំងបុត្រ ... ស.រ.អ.

៥៤- ឧ.សិ.ឡុង អ៊ីម ព្រមទាំងបុត្រ និងចៅ ....................... ស.រ.អ.

៥៥- ឧ.ស.ឡេង កុយ និង ឧ.សិ.ឈឹម សេន ........................ ស.រ.អ.

៥៦- ឧ.សិ.ឡាំង គីមឆេង ព្រមទាំងបុត្រ ........................... ស.រ.អ.

៥៧- ឧ.ស.អ៊ាបហៃសាន+ឧ.សិ.ឡឹកពេញចិត្ត+ឧ.ស.ឡឹកច័ន្ទដេត ស.រ.អ.

៥៨- ឧ.សិ.អ៊ឹង ស៊ីវន ព្រមទាំងបុត្រ និងចៅ ........................ ស.រ.អ.

៥៩- ឧ.ស.អ៊ុក សាមឿន និង ឧ.សិ.វ៉ូច អ៊ីម ព្រមទាំងកូនចៅ .. ស.រ.អ.

| | | |
|---|---|---|
| ៦០- | ឧ.ស.អ៊ុន ឆៃត្រី និង ភរិយា ព្រមទាំងបុត្រ .................. | ស.រ.អ. |
| ៦១- | ឧ.សិ.អ៊ួន សាម៉ន ព្រមទាំងកូនចៅ .............................. | ស.រ.អ. |
| ៦២- | លោកគ្រូធម្មបណ្ឌិត អឿ សៅ .................................. | ស.រ.អ. |
| ៦៣- | ឧ.ស.អៀង ឆាយ និង ឧ.សិ. អៀ កេសរ ព្រមទាំងបុត្រ . | ស.រ.អ. |
| ៦៤- | ឧ.សិ.អ៊ុំ ស៊ុននី និង កូនចៅ ...................................... | ស.រ.អ. |
| ៦៥- | ឧ.ស.កាំង ប៉េងជីវ និង ឧ.សិ.លឹម អ៊ីហ៊ាម + កូនចៅ ..... | អូស្ត្រាលី |
| ៦៦- | ឧ.ស.គង់ វុធ និង ឧ.សិ.ជ័យ សារឹម ព្រមទាំងកូនចៅ ....... | អូស្ត្រាលី |
| ៦៧- | កញ្ញា គា ដារ៉ា ( ហៅ ស្រីណេ ) .............................. | អូស្ត្រាលី |
| ៦៨- | ឧ.ស.ង៉ូវ ឈីវ និង ឧ.សិ.ហេង ពាស៊ីម ព្រមទាំងបុត្រ+ចៅ | អូស្ត្រាលី |
| ៦៩- | ឧ.សិ.ឆេង លុន ព្រមទាំងបុត្រ និងចៅ ....................... | អូស្ត្រាលី |
| ៧០- | ឧ.សិ.ជូ រ៉េន ........................................................ | អូស្ត្រាលី |
| ៧១- | ឧ.សិ.ឈ គឹមស៊ីន និង ក្រុមគ្រួសារកូនចៅ .................. | អូស្ត្រាលី |
| ៧២- | ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ.... | អូស្ត្រាលី |
| ៧៣- | លោក ញាន ហេងម៉ូវ និង អ្នកស្រី ស៊ា ចន្ថា ព្រមទាំងបុត្រ | អូស្ត្រាលី |
| ៧៤- | ឧ.ស.ដែន គង់ហួត និង ឧ.សិ.កាំង គឹមស៊ុន ព្រមទាំងបុត្រ | អូស្ត្រាលី |
| ៧៥- | ឧ.ស.តូ សាវ៉ឺន និង ឧ.សិ.មាន សុវត្ថិ ព្រមទាំងបុត្រ ........ | អូស្ត្រាលី |
| ៧៦- | ឧ.សិ.តាំង សៀកហៀង ព្រមទាំងកូនចៅ ..................... | អូស្ត្រាលី |
| ៧៧- | ឧ.ស.ទា សុង និង ឧ.សិ.ង៉ោ ចាន់ខេង ព្រមទាំងកូនចៅ .. | អូស្ត្រាលី |
| ៧៨- | ឧ.សិ.បាក់ លីឡេងហ៊ាង ព្រមទាំងកូនចៅ ..................... | អូស្ត្រាលី |
| ៧៩- | ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ .......... | អូស្ត្រាលី |
| ៨០- | ឧ.សិ.ប៊ុក យ៉ារ៉ាត និង ស្វាមី+បុត្រ+លឹម ស៊ុនហេង+បុត្រ.. | អូស្ត្រាលី |



| | | |
|---|---|---|
| ៨១- | ឧ.ស.ប៉ុច រឿត និង ឧ.សិ.ញូង ស៊ាងម៉េង ព្រមទាំងបុត្រ.. | អូស្ត្រាលី |
| ៨២- | លោកយាយ ប្រាក់ខាត់+ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ | អូស្ត្រាលី |
| ៨៣- | ឧ.សិ.ម៉េង ប៊ុន្នារី ( ហៅស្រីពៅ )និងស្វាមី ព្រមទាំងបុត្រ. | អូស្ត្រាលី |
| ៨៤- | ឧ.ស.យ៉ង់ សិន និង ឧ.សិ.នន់ ហេង ព្រមទាំងបុត្រ+ចៅ. | អូស្ត្រាលី |
| ៨៥- | ឧ.សិ.យិន មួយឡាង និង ស្វាមី ព្រមទាំងបុត្រ .............. | អូស្ត្រាលី |
| ៨៦- | លោក យឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ....... | អូស្ត្រាលី |
| ៨៧- | ឧ.សិ.រត្ន័ គឹមសាន .................................................. | អូស្ត្រាលី |
| ៨៨- | ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង ព្រមទាំងបុត្រ . | អូស្ត្រាលី |
| ៨៩- | ឧ.ស.រាជ ស៊ាង និង ឧ.សិ.វង់ រិទ្ធ ព្រមទាំងបុត្រ ........... | អូស្ត្រាលី |
| ៩០- | ឧ.សិ.លឹម ស៊ូឆេង ព្រមទាំងកូនចៅ .......................... | អូស្ត្រាលី |
| ៩១- | ឧ.ស.លឹម ហុងលី និង ឧ.សិ.ស៊ឹម តេងគី ព្រមទាំងបុត្រ... | អូស្ត្រាលី |
| ៩២- | ឧ.សិ.ស៊ន លន់អេង ................................................ | អូស្ត្រាលី |
| ៩៣- | ឧ.ស.សរ ប៊ុនធៀង ព្រមទាំងបុត្រ និងចៅ.................. | អូស្ត្រាលី |
| ៩៤- | ឧ.ស.ស៊ីវ សៀងថៃ និង ឧ.សិ.ឯក សុកហាក់ +បុត្រ ...... | អូស្ត្រាលី |
| ៩៥- | ឧ.ស.ស៊ីវ មាស និង ឧ.សិ.លាង ណាំសួរ ព្រមទាំងកូនចៅ.. | អូស្ត្រាលី |
| ៩៦- | ឧ.សិ.ស៊ុយ គឹមស៊ាន និងកូនស្រី សេង ផល្លា ............... | អូស្ត្រាលី |
| ៩៧- | កញ្ញា ស៊ុយ ដាណែត ............................................ | អូស្ត្រាលី |
| ៩៨- | ឧ.ស.ស៊ូ ឃីម និង ឧ.សិ.សៀង តិច ព្រមទាំងបុត្រ+ចៅ.. | អូស្ត្រាលី |
| ៩៩- | ឧ.សិ.សូយ មួយ .................................................... | អូស្ត្រាលី |
| ១០០- | ឧ.សិ.សៀ ចន្ថា ................................................... | អូស្ត្រាលី |
| ១០១- | ឧ.សិ.សៀង វួច ព្រមទាំងកូនចៅ .............................. | អូស្ត្រាលី |

| | | |
|---|---|---|
| ១០២- | ឧ.សិ.សេង សៀងឈុន ព្រមទាំងបុត្រ និងចៅ ............. | អូស្ត្រាលី |
| ១០៣- | ព្រឹទ្ធាចារ្យ សេង ទូច ព្រមទាំងបុត្រ និងចៅ ................ | អូស្ត្រាលី |
| ១០៤- | ឧ.សិ.សិរិត ស៊ីវន ព្រមទាំងបុត្រ និងចៅ .................... | អូស្ត្រាលី |
| ១០៥- | ឧ.ស.សំ សុខគុណ និង ឧ.សិ.លី សៀមហៀង + បុត្រ ... | អូស្ត្រាលី |
| ១០៦- | កុង ហេង ឡេងថៃ និង ម៉ា អ៊ា គីមទាង+ចៅថៃ ឃីអ៊ុយ | អូស្ត្រាលី |
| ១០៧- | ឧ.សិ.ហេង តាំងហុង ព្រមទាំងកូនចៅ ......................... | អូស្ត្រាលី |
| ១០៨- | ឧ.ស.ឡុង ហ៊ន និង ឧ.សិ.លិម យូអេង ..................... | អូស្ត្រាលី |
| ១០៩- | លោកម្ចាស់ ឡូញ ផល្លី ........................................... | អូស្ត្រាលី |
| ១១០- | ឧ.ស.ឡៅ គីមងួន និង ឧ.សិ.ដួង លី ព្រមទាំងបុត្រ ........ | អូស្ត្រាលី |
| ១១១- | ឧ.សិ.អ៊ន ម៉ា ព្រមទាំងកូនចៅ ................................... | អូស្ត្រាលី |
| ១១២- | ឧ.ស.អ៊ា សេង និង ឧ.សិ.គីម ខេង ព្រមទាំងកូនចៅ ...... | អូស្ត្រាលី |
| ១១៣- | ឧ.ស.អ៊ឹង ឈាងហេង និង ឧ.សិ.សំ ពៅនារី +បុត្រ ......... | អូស្ត្រាលី |
| ១១៤- | ឧ.សិ. អ៊ុក ណារី ព្រមទាំងបុត្រ ................................. | អូស្ត្រាលី |
| ១១៥- | ឧ.សិ.អ៊ុច សុផល្លី ព្រមទាំងកូនចៅ .............................. | អូស្ត្រាលី |
| ១១៦- | ឧ.សិ.ឱម លក្ខណា ព្រមទាំងបុត្រធីតា ....................... | អូស្ត្រាលី |
| ១១៧- | HENG Srey Chea+H.Srey Chan+H.Srey Neang. | អូស្ត្រាលី |
| ១១៨- | Mr BOON Leang Chaing+Mrs Nary SOK... | អូស្ត្រាលី |
| ១១៩- | ឧ.សិ.គី អ៊ីភីង ........................................................ | បារាំង |
| ១២០- | ឧ.សិ.គីម ហួយ ព្រមទាំងបុត្រ និងចៅ .................... | បារាំង |
| ១២១- | ឧ.ស.ង៉ូវ ជួនណារេត ឧ.សិ.ង៉ូវ សោភ័ណ ព្រមទាំងបុត្រ... | បារាំង |
| ១២២- | ឧ.សិ.ង៉ែត យ៉េន ព្រមទាំងបុត្រ និងចៅ .................. | បារាំង |



| | | |
|---|---|---|
| ១២៣- | ឧ.ស.ជីន ជុង និងភរិយា........................................ | បារាំង |
| ១២៤- | ឧ.ស.ឈឹម ហុកអ៊ាន ព្រមទាំងបុត្រ និងចៅ .............. | បារាំង |
| ១២៥- | ឧ.សិ.ទាវ គីមហ៊ួន ព្រមទាំងកូនចៅ ........................ | បារាំង |
| ១២៦- | ឧ.ស.បាន ណារិន និង ឧ.សិ.ហោ ចន្ធូ ព្រមទាំងបុត្រ .... | បារាំង |
| ១២៧- | ឧ.ស.ប៊ុន ឈឹម និង ឧ.សិ.គី គីមលាង ព្រមទាំងបុត្រ .. | បារាំង |
| ១២៨- | ឧ.សិ.យុក ជា ព្រមទាំងបុត្រ .................................... | បារាំង |
| ១២៩- | លោក យូណូស អាស៊ីស និង អ្នកស្រី ហុក ណារី+បុត្រ ... | បារាំង |
| ១៣០- | ឧ.សិ.ហែម ពៅ ព្រមទាំងបុត្រ ............................. | បារាំង |
| ១៣១- | ឧ.ស.ហ្វាន់ វ៉ាន់ហួ និង ឧ.សិ.ហ្វាន់ យូលាង ព្រមទាំងបុត្រ | បារាំង |
| ១៣២- | ឧ.ស.ឡុក ប៊ុនអ៊ីវ និង ឧ.សិ.តាន់ ស៊ីវឡាង+បុត្រ.......... | បារាំង |
| ១៣៣- | ឧ.ស.ឡោ សេងជ្រុន និង ឧ.សិ.ផាំង លី កូនចៅ .......... | បារាំង |
| ១៣៤- | ឧ.សិ.អ៊ឹង ហ្គេចតេង ព្រមទាំងបុត្រ ....................... | បារាំង |
| ១៣៥- | ឧ.សិ.អ៊ឹង យ៉េកសាង ព្រមទាំងបុត្រ ....................... | បារាំង |
| ១៣៦- | ឧ.ស.អេងឃី លាបឆាយ និង ឧ.សិ.ហែម ពៅ +បុត្រ ...... | បារាំង |
| ១៣៧- | Mme LAK KIM LEANG ............................. | បារាំង |
| ១៣៨- | ឧ.សិ.ចំណាន ព្រមទាំងក្រុមគ្រួសារ ........................ | កាណាដា |
